ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## បូកសរុបសកម្មភាព និងលទ្ធផលការងារ

## ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និង ទិសដៅ ឆ្នាំ២០១៧

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

# សារជូនពរ

សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនជនរួមជាតិ ជាទីគោរពរាប់អាន

ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំមានមោទនភាពក្រៃលែង និងសូមសម្តែងនូវការកោតសរសើរ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់ របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងគណៈកម្មាធិការជាតិ ជាពិសេស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលបានសហការគ្នាប្រមូលផ្តុំនូវកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ចូលរួមយ៉ាងទូលំទូលាយ តាំងពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជាមួយអន្តរជាតិយ៉ាងល្អប្រសើរ។ នេះគឺជាថាមពលដ៏មានសក្តានុពល សម្រាប់ដោះស្រាយបញ្ហាសង្គម ដែលមានភាពប្រទាក់ក្រឡា ស្មុគស្មាញ ដូចអំពើជួញដូរមនុស្សនេះ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគណៈកម្មាធិការជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដែលបានឆ្លុះបញ្ចាំងក្នុងរបាយការណ៍ឆ្នាំនេះ ថាពិតជាមានភាពល្អប្រសើរ និងកាន់តែទូលំទូលាយ ក្រោបបានទិន្នន័យ និងបញ្ហាចំចំណុច ព្រមទាំងលើកទិសដៅដើម្បីអនុវត្តជាក់លាក់នៅឆ្នាំ២០១៧បន្តទៀត ។ ម្យ៉ាងវិញទៀត ខ្ញុំសូមថ្លែងអំណរគុណ ដល់ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី និងឯកឧត្តមនាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ ដែលជាប្រធានក្រុមការងារអន្តរក្រសួងទាំងប្រាំមួយ និងសមាជិក ព្រមទាំងកម្លាំងសមត្ថកិច្ចទាំងអស់នៅតាមបណ្តាអង្គភាពឈរជើង និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលបានប្រឹងប្រែងក្នុងការការពារសុវត្ថិភាព និងបង្ក្រាបបទល្មើសតាំង និងរួមគ្នាបង្ការ ទប់ស្កាត់ពីតាមបណ្តាច្រកព្រំដែន រហូតដល់តាមបណ្តាសហគមន៍ក្នុងប្រទេស យ៉ាងទូលំទូលាយ ។

ខ្ញុំក៏សូមឆ្លៀតឱកាសនេះដើម្បី ថ្លែងអំណរគុណផងដែរ ដល់គ្រប់ការចូលរួមសហការ និងគាំទ្រដល់ដំណើរការនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅគ្រប់កម្រិត គ្រប់សកម្មភាព ដែលក្នុងនោះមានទាំង អង្គការUSAID តាមរយៈអង្គការវិនរ៉ក់អន្តរជាតិ អង្គការ UN-ACT អង្គការ Cambodia Acts អង្គការ Terre des Hommes ហុល្លង់ អង្គការ IJM អង្គការ IOM អង្គការ APLE អង្គការចាប់ដៃ អង្គការ LSCW អង្គការCWCC អង្គការវឌ្ឍនៈ អង្គការSamaritan's Purse, អង្គការGVC ព្រមទាំងបណ្តាអង្គការដៃគូជាតិនិងអន្តរជាតិជាច្រើនទៀត ដែលតែងតែគាំទ្រ និងសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិ និងគណៈកម្មាធិការរាជធានី ខេត្ត ក្នុងការបង្កើតផែនការសកម្មភាពជាតិ គោលការណ៍ណែនាំ កិច្ចព្រមព្រៀង ទ្វេភាគី ពហុភាគី ផែនការតាមដានត្រួតពិនិត្យ និងបានចូលរួម

អនុវត្តសកម្មភាពជាច្រើន នៅតាមបណ្ដាខេត្ត និងតាមគោលដៅនានា ក្នុងភូមិ ឃុំ សង្កាត់ ឬតាមបណ្ដោយព្រំដែនកម្ពុជា រហូតដល់ជាមួយបណ្ដាប្រទេសគោលដៅពាក់ព័ន្ធ សំដៅរួមគ្នាប្រយុទ្ធប្រឆាំង ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព និងលើកកម្ពស់សន្តិសុខសុវត្ថិភាពមនុស្សជាតិ ទាំងទារក កុមារ យុវវ័យ មនុស្សចាស់ប្រុសស្រី ឲ្យរស់នៅមានភាពសុខុដុមរមនា និងទទួលបានការគោរពសិទ្ធិ និងសេចក្ដីថ្លៃថ្នូរ។

ខ្ញុំសង្ឃឹមថា ឆ្នាំ២០១៧ នឹងនាំមកនូវកិច្ចសហប្រតិបត្តិការប្រកបដោយជោគជ័យថ្មីៗបន្ថែមទៀត និងបានរួមគ្នាបង្កើតនូវប្រព័ន្ធសុវត្ថិភាព និងអនុវត្តច្បាប់កាន់តែរឹងមាំ សម្រាប់ការពារប្រជាពលរដ្ឋយើង ឲ្យរួចផុតពីទុក្ខភ័យ ហើយនាំគ្នាពង្រឹង និងពង្រីកខឿនសេដ្ឋកិច្ចដ៏ល្អប្រសើរ ដែលកំពុងតែបោះជំហានទៅមុខ ឥតឈប់ឈរ ឆ្ពោះទៅកាន់ចក្ខុវិស័យរួម គឺ «កម្ពុជាព្រះរាជាណាចក្រ អច្ឆរិយៈ» ។

ខ្ញុំសូមឧទ្ទិសដល់គុណបុណ្យព្រះរតនត្រ័យ និងបារមីវត្ថុសក្ដិសិទ្ធិ និងទេវតាឆ្នាំថ្មី សូមមេត្តាប្រទានពរជ័យ និងប្រោះព្រំ ផ្ដល់នូវភាពត្រជាក់ត្រជុំ សុខុដុមរមនា ដល់ប្រជាជនកម្ពុជាគ្រប់រូប ឲ្យចម្រើនដោយក្ដីសុខ ផ្លូវកាយ ផ្លូវចិត្ត គ្មានគ្រោះភ័យ និងរោគា បរិបូណ៌ដោយទ្រព្យា និងជោគជ័យ សិរីមង្គល វិបុលសុខ គ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ**

**សម្ដេចក្រឡាហោម ស ខេង**

# មាតិកា


**I. ស្ថានភាពទូទៅ** ............................................................ ១

**II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៦** ............................................................ ២

**ការអនុវត្តយុទ្ធសាស្រ្តទាំង៤**

ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ ............................................................ ២

ក.១- ការកសាងច្បាប់ និងគោលនយោបាយ ............................................................ ២

*ក.១.១- កិច្ចការច្បាប់* ............................................................ ៣

*ក.១.២- គោលនយោបាយជាតិ* ............................................................ ៣

*ក.១.៣- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ* ............................................................ ៤

ក.២- កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអនុវត្តច្បាប់ និងគោលនយោបាយ ............................................................ ៥

*ក.២.១- កិច្ចព្រមព្រៀង-សន្ធិសញ្ញា នៃការជួយគ្នាទៅវិញទៅមក* ............................................................ ៥

*ក.១.២- អនុស្សារណៈនៃការយោគយល់គ្នា* ............................................................ ៥

ខ. លើកកម្ពស់ការបង្ការទប់ស្កាត់ ............................................................ ៧

ខ.១- ការប្រជុំអប់រំផ្សព្វផ្សាយ ............................................................ ៨

ខ.២- វេទិកាសាធារណៈ ............................................................ ៨

ខ.៣- យុទ្ធនាការ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ............................................................ ១០

ខ.៤- ការផលិត និងចែកផ្សាយសម្ភារៈផ្សព្វផ្សាយ ............................................................ ១០

ខ.៥- ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន ............................................................ ១១

ខ.៦- ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ............................................................ ១២

*ខ.៦.១- ការគ្រប់គ្រងស្ថិតិចំណាកស្រុករបស់ពលរដ្ឋខ្មែរតាមខែនីមួយៗ* ............................................................ ១២

*ខ.៦.២- ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសឯកជន* ............................................................ ១៣

*ខ.៦.៣- ស្ថានភាពលំហូរជនទេសន្តរប្រវេសន៍* ............................................................ ១៥

*ខ.៦.៤- ស្ថិតិពលករដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេស តាមច្រកព្រំដែន* ១៦

ខ.៧- ការផ្តល់ភាពស្របច្បាប់ដល់ពលករនៅក្រៅប្រទេស ............................................................ ១៦

ខ.៨- វិធានការគ្រប់គ្រងជំនាញ ............................................................ ១៦

*ខ.៨.១- ការងារបង្កាទប់ស្កាត់តាមវិធានការជំនាញ* ............................................................ ១៦

*ខ.៨.២- ការបង្កាទប់ស្កាត់ភាពរងគ្រោះតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស* ............................................................ ១៨

*ខ.៨.៣- លទ្ធផលនៃកិច្ចសម្ភាសន៍ពលករ ដែលអាជ្ញាធរបរទេសបញ្ជូនត្រលប់* ....... ១៨

គ. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ............................................................ ២០

គ.១- ការងារអនុវត្តច្បាប់ ............................................................ ២០

*គ.១.១- ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ* ............................................................ ២០

*១. ករណីអំពើជួញដូរមនុស្ស* ............................................................ ២១

*២. អំពើធ្វើអាជីវកម្មផ្លូវភេទ ..................................................................... ២២*
*៣. ករណីប្រព្រឹត្តអំពើអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ ........................... ២២*
*គ.១.២- ការកសាងសំណុំរឿង បណ្តឹងជនសង្ស័យរងគ្រោះ បញ្ជូនទៅតុលាការ ... ២៣*
*គ.១.៣- ដំណោះស្រាយផ្លូវច្បាប់សម្រាប់ជនរងគ្រោះនៅក្រៅប្រទេស .................. ២៤*
គ.២- កិច្ចការយុត្តិធម៌................................................................................ ២៤
*គ.២.១- លទ្ធផលចំណាត់ការផ្តន្ទាទោស................................................... ២៤*
*គ.២.២- ចំណាត់ការរបស់អយ្យការរាជធានី-ខេត្ត ............................................ ២៤*
*គ.២.៣ ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ............ ២៥*
*គ.២.៤ ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ ................................................... ២៥*
*គ.២.៥ សម្របសម្រួលការអនុវត្តប្រព័ន្ធយុត្តិធម៌ ............................................ ២៦*
ឃ. កិច្ចការពារជនរងគ្រោះ ព្រមទាំងសវាគាំទ្រ ................................................ ២៦
ឃ.១- ការទទួលជនសង្ស័យរងគ្រោះ .................................................................. ២៦
ឃ.២- កិច្ចការពារកុមារ ................................................................................. ២៧
ឃ.៣- ការគ្រប់គ្រងជនរងគ្រោះក្នុងមណ្ឌល ...................................................... ២៨
ឃ.៤- សេវាជួយជនរងគ្រោះដែលបានផ្តល់ ...................................................... ២៨
ឃ.៥- សមាហរណកម្មជនរងគ្រោះ .................................................................. ២៨
**III. ការលើកកម្ពស់សមត្ថភាព** ............................................................................. ២៩
ក. ក្នុងប្រទេស ......................................................................................... ២៩
ក.១- បណ្តុះបណ្តាល ................................................................................... ២៩
ក.២- សិក្ខាសាលា ...................................................................................... ២៩
ក.៣- ការសម្របសម្រួលកិច្ចប្រជុំ ................................................................... ៣១
ខ. ក្រៅប្រទេស ......................................................................................... ៣២
ខ.១- ការចូលរួមកិច្ចប្រជុំ ............................................................................. ៣២
ខ.២- ការចូលរួមសិក្ខាសាលាអន្តរជាតិ ............................................................ ៣៥
ខ.៣ ការចូលរួមបណ្តុះបណ្តាលនៅក្រៅប្រទេស ................................................ ៣៥
**IV. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ** ............................................................ ៣៦
**V. សន្និដ្ឋាន និងវាយតម្លៃ** .................................................................................. ៣៦
ក. ចំណុចខ្លាំង ........................................................................................... ៣៦
ខ. ចំណុចសេសសល់ និងបញ្ហាប្រឈម ........................................................... ៣៨
**VI. ទិសដៅ ឆ្នាំ២០១៧** ....................................................................................... ៤០
**ឧបសម្ព័ន្ធ**........................................................................................................ ៤៥ -៧៩
**វចនាសម្ព័ន្ធ** ..................................................................................................... ៨០
**កម្រងរូបភាព** ..................................................................................................... ៨៣

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១៦ និងទិសដៅ ឆ្នាំ ២០១៧

( គិតចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ )

## I. ស្ថានភាពទូទៅ

ស្ថានភាពសេដ្ឋកិច្ច នយោបាយ និងសន្តិសុខសង្គមនៅប្រទេសមួយចំនួន នៅក្នុងតំបន់មជ្ឈឹមបូព៌ា សហភាពអឺរ៉ុប តំបន់អាស៊ី និងសហរដ្ឋអាមេរិក បានប្រែប្រួលគួរឲ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ និងជះឥទ្ធិពលទៅលើបណ្តាប្រទេសផ្សេងៗទៀត ឲ្យទទួលរងនូវផលប៉ះពាល់ដោយសារទំហំនៃចំណាកស្រុក ដើម្បីស្វែងរកការតាំងទីលំនៅ និងការរស់នៅរបស់មនុស្សរាប់សិបលាននាក់ ។

ដោយឡែក រាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១៦នេះ បានខិតខំរក្សាស្ថេរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧%ក្នុងមួយឆ្នាំ និងផ្តោតការយកចិត្តទុកដាក់ខ្ពស់ចំពោះការថែរក្សាសន្តិសុខ សុវត្ថិភាពសង្គមនៅទូទាំងប្រទេស ដែលអាចធានាដល់ស្ថេរភាពនយោបាយ ការលើកកម្ពស់ជីវភាពមន្ត្រីរាជការ កម្មករ កសិករ ប្រជាពលរដ្ឋទូទៅ ព្រមទាំងសុវត្ថិភាពភ្ញៀវទេសចរ និងអ្នកវិនិយោគបរទេសបានយ៉ាងល្អប្រសើរ។

រីឯការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជា គឺក្នុងគោលដៅតែមួយគត់ នោះគឺការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរស់នៅ ក្នុងបរិបទនៃកំណើនសេដ្ឋកិច្ច គួបផ្សំនឹងទំនើបភាវូបនីយកម្មនៃបច្ចេកវិទ្យា និងសម្ភារៈប្រើប្រាស់ ដែលគ្រួសារនីមួយៗត្រូវការជាចាំបាច់ ។ រាជរដ្ឋាភិបាលបានបើកទូលាយទីផ្សារទំនិញ និងទីផ្សារការងារទាំងនៅក្នុងស្រុក ទាំងនៅក្រៅប្រទេស ដើម្បីផ្តល់ការងារជូនប្រជាពលរដ្ឋកម្ពុជា ។ ជាក់ស្តែងប្រជាពលរដ្ឋរាប់លាននាក់មានការងារធ្វើនិងបានប្រកបមុខរបររកប្រាក់ចំណូលយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជា លើវិស័យកសិកម្ម សំណង់ហេដ្ឋារចនាសម្ព័ន្ធ សហគ្រាសពាណិជ្ជកម្ម សិប្បកម្ម ឧស្សាហកម្ម វិស័យអចលនទ្រព្យ និងសេវាកម្មសម្រាប់បម្រើឲ្យវិស័យសេដ្ឋកិច្ច ជាពិសេសវិស័យទេសចរណ៍ និងវិនិយោគជាដើម ។ រីឯប្រជាជនប្រមាណមួយលាននាក់ទៀត បានជ្រើសរើសយកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ការងារទៅក្រៅប្រទេស ដោយរំពឹងថាទទួលបានការងារល្អ ប្រាក់ចំណូលខ្ពស់ និងស្ថានភាពជីវភាពប្រសើរជាងមុន ។

ពិតមែនហើយថាប្រជាជនមួយចំនួនទទួលបានផលប្រយោជន៍ពីការធ្វើទេសន្តរប្រវេសន៍ ជាពិសេសតាមផ្លូវច្បាប់ តែក៏នៅមានប្រជាពលរដ្ឋមួយចំនួនទៀត ដែលព្យាយាមស្វែងរកការងារធ្វើនៅក្រៅប្រទេស ដោយប្រថុយប្រថានមិនតាមប្រព័ន្ធរៀបរយតាមផ្លូវច្បាប់ តែងតែប្រឈមនឹងហានិភ័យខ្ពស់ ដោយភាពរងគ្រោះជាច្រើនរូបភាពរាប់ទាំងការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរ ឬរំលោភបំពានផ្លូវភេទ ការជួញដូរសរីរាង្គ អំពើហិង្សា ការប្រើប្រាស់និងជួញដូរគ្រឿងញៀន ឬបទល្មើសផ្សេងៗទៀត ដែលបង្កឲ្យមានជនរងគ្រោះជាបុរស ស្ត្រី និងកុមារកាន់តែច្រើនឡើង ។ ទាំងអស់នេះ បានក្លាយជាបន្ទុកបន្ថែមលើគ្រួសារ និងសង្គមឲ្យកាន់តែមានមានភាពប្រឈមច្រើនឡើង លើបញ្ហាសុខភាព ការអប់រំ បញ្ហាសេដ្ឋកិច្ច បញ្ហាសង្គម រួមទាំងការជ្រៀតចូលនូវបទល្មើសផ្សេងៗ ។

ថ្មីៗនេះ ក៏មានលេចចេញនូវសកម្មភាពជួញដូរសរីរាង្គ និងសកម្មភាពជួលពពោះជំនួស ដើម្បីនាំយកទារកចេញទៅក្រៅប្រទេសថែមទៀត ដែលនេះជាសញ្ញាណមួយថ្មីអាចពាក់ព័ន្ធនឹងបទល្មើស រត់ពន្ធ ឬជួញដូរទារកឆ្លងដែន ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ ដោះស្រាយ និងបង្ការទប់ស្កាត់ ជាបន្ទាន់ ហើយត្រូវកសាងច្បាប់ដើម្បីគ្រប់គ្រងកម្មភាពពពោះជំនួសឲ្យបានឆាប់ ។

ឆ្លើយតបទៅនឹងបញ្ហានេះ សម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវអនុសាសន៍ជាគន្លឹះសំខាន់ៗ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជម្រុញឲ្យគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ថ្នាក់ ខិតខំរួមគ្នាអនុវត្តការងារឲ្យបានសកម្ម សហការគ្នាឲ្យកាន់តែខ្លាំងក្លារវាងបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាលជាដៃគូជាតិ និងអន្តរជាតិនានា ព្រមទាំងជម្រុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដើម្បីលុបបំបាត់អំពើជួញដូរមនុស្សឲ្យបានជាស្ថាពរ ។

ក្នុងឆ្នាំ២០១៦នេះ សកម្មភាពបង្ក្រាប កិច្ចការពារជនរងគ្រោះ ការផ្តន្ទាទោស និងសកម្មភាពបង្ការទប់ស្កាត់ ត្រូវបានធ្វើឡើងព្រមៗគ្នា នៅគ្រប់មុខសញ្ញា ដោយផ្តោតការយកចិត្តទុកដាក់កាន់តែខ្ពស់ លើស្ត្រី និងកុមារ ។ កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងពង្រីកកាន់តែទូលំទូលាយ ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានបានសហការជាមួយអង្គការដៃគូ ដើម្បីបង្កើតជាការសិក្សាស្រាវជ្រាវស្តីពីទីផ្សារការងារក្នុងស្រុកដើម្បីផ្តល់ជម្រើសជូនប្រជាពលរដ្ឋ ជាពិសេសយុវវ័យដែលត្រូវការប្រាក់ចំណូលលើកកម្ពស់ជីវភាព តាមរយៈការងារ ឬមុខរបរ ។ ការវាយតម្លៃផែនការសកម្មភាពពាក់កណ្តាលអណត្តិ ក៏ត្រូវបានធ្វើឡើងដោយអ្នកវាយតម្លៃឯករាជ ដើម្បីពិនិត្យលើចំណុចខ្លាំង ចំណុចខ្សោយនៃការអនុវត្ត និងរៀបចំកែសម្រួលសកម្ម សម្រាប់ឆ្នាំ២០១៧ និង ២០១៨ ។

***ជាលទ្ធផលនៃការអនុវត្តសកម្មភាពរបស់គ្រប់ថ្នាក់នៃរចនាសម្ព័ន្ធគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆ្នាំ ២០១៦ ខាងក្រោមនេះ គឺជាការបូកសរុបរបាយការណ៍ ដែលទទួលបានពីក្រុមការងារក្រសួងចំនួន០៦ អង្គភាពស្ថាប័នចំនួន២២ រាជធានីខេត្ត២៥ អង្គការដៃគូចំនួន២៤ គួបផ្សំនឹងព័ត៌មានជាតិ និងអន្តរជាតិសំខាន់ៗ មួយចំនួនទៀត*** ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៦

### ❖ ការអនុវត្តយុទ្ធសាស្ត្រទាំង៤

### ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

#### ក.១-ការកសាងច្បាប់ និងគោលនយោបាយ

ដើម្បីជាបង្អែកក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិ គ.ជ.ប.ជ និងក្រសួង អង្គភាពពាក់ព័ន្ធមួយចំនួន បានដាក់ចេញនូវសេចក្តីសម្រេច គោលការណ៍ វិធានការមួយចំនួន ដូចខាងក្រោម៖

### ក.១.១-កិច្ចការច្បាប់

#### ❖ ច្បាប់ និងលិខិតបទដ្ឋានដែលបានដាក់ឲ្យប្រើប្រាស់

- ច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស ត្រូវបានប្រកាសឲ្យប្រើតាម **ព្រះរាជក្រមលេខ** នស/រកម/០៨១៦ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ។
- **ច្បាប់ស្តីពីយុត្តិធម៌អនីតិជន** ត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខន.សរកម/០៧១៦/០០៩ (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦) ។
- ប្រកាសលេខ១៣៣/១២ប្រ.ក ស្តីពីការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប "ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា" ចេញដោយ**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ។

#### ❖ លិខិតបទដ្ឋានដែលកំពុងរៀបចំ

-សេចក្តីព្រាងច្បាប់ ស្តីពី "ការគ្រប់គ្រងការពពោះជំនួស" (ក្រសួងកិច្ចការនារី)

-សេចក្តីព្រាងច្បាប់ ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស" (ក្រសួងយុត្តិធម៌)

-សេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពី"**បញ្ជូនទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស (ក្រសួងយុត្តិធម៌)

-សេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពី"**បញ្ជូនទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ (ក្រសួងយុត្តិធម៌)

-សេចក្តីព្រាងសារាចរណែនាំ ស្តីពី "លក្ខណៈការងារសម្រាប់កម្មករការងារផ្ទះ"(ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

-សេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការពារកុមារតាមសាលារៀន" (ក្រសួងអប់រំ យុវជន និងកីឡា)។

### ក.១.២-គោលនយោបាយជាតិ

- **សិក្សាវាយតម្លៃពាក់កណ្តាលអណត្តិ** នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៤-២០១៨ ដើម្បីរៀបចំកែសម្រួលសកម្មភាពសម្រាប់អនុវត្តបន្ត ទៅឆ្នាំ២០១៧-២០១៨ (គាំទ្រដោយអង្គការវិនរ៉ក់អន្តរជាតិ ក្រោមជំនួយឧបត្ថម្ភរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក)។
- **(បន្តអនុវត្ត) គោលនយោបាយជាតិ** ស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ របស់រាជរដ្ឋាភិបាល បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ក្នុងគោលបំណង **(១)**.បង្កើនឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ **(២)**.ការលើកកម្ពស់ការអភិវឌ្ឍជំនាញ និងធនធានមនុស្ស **(៣)**.ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ ដោយដាក់

បញ្ចូលគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារកម្ពុជា ជាគន្លឹះនៃការកសាងការងារក្នុងស្រុក ដើម្បីជាជម្រើសជូនប្រជាជនកម្ពុជា កាត់បន្ថយការឆ្លងដែនធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ដែលនាំឲ្យប្រឈមនឹងអំពើជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។

### ក.១.៣ លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ

- **គ.ជ.ប.ជ** បានកែសម្រួលសមាសភាពក្រុមការងារអនុវត្តច្បាប់ ដោយបានចេញសេចក្តីសម្រេច លេខ១៦៦/១៦ស.ស.រ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការតែងតាំងសមាសភាពក្រុមការងារការងារអនុវត្តន៍ច្បាប់ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- **ក្រសួងយុត្តិធម៌**
    - ចេញលិខិតស្តីពី "ការណែនាំដល់គ្រប់ស្ថាប័នតុលាការ និងអយ្យការគ្រប់រាជធានី-ខេត្ត"ឲ្យយកចិត្តទុកដាក់លើរឿងក្តីនៃអំពើជួញដូរមនុស្ស ។
    - ចេញលិខិតស្តីពី "ការណែនាំ ដល់គ្រប់ស្ថាប័នតុលាការ និងអយ្យការគ្រប់រាជធានី-ខេត្ត"ឲ្យយកចិត្តទុកដាក់ក្នុងការស្រង់ទិន្នន័យសំណុំរឿងក្តីនៃអំពើជួញដូរមនុស្សឲ្យបានទៀងទាត់ បញ្ជូនមកក្រសួងយុត្តិធម៌ ដើម្បីធ្វើការបូកសរុបទិន្នន័យរឿងក្តីនៃអំពើជួញដូរមនុស្សពីបណ្តារាជធានី-ខេត្ត និងធ្វើរបាយការណ៍ផ្ញើជូនក្រុមការងារថ្នាក់ជាតិឲ្យបានទាន់ពេលវេលា ។
- **ក្រសួងសុខាភិបាល** ចេញប្រកាសលេខ៦៧៩ ប្រក/សនក ស្តីពី «ការគ្រប់គ្រងឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស» ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (ជំពូកទី៣ ផ្នែកទី២ ប្រការ១២៖ «រាល់ការពរពោះជំនួស ដែលជាសេវាមួយនៃកញ្ចប់សេវានានាក្នុងការជួយឲ្យមានកូន តាមបែបបច្ចេកទេសវិទ្យាសាស្ត្រ Assisted Reproductive Technology ត្រូវហាមឃាត់ដាច់ខ» និង ផ្នែកទី៣ ប្រការ១៧៖«មិនអនុញ្ញាតឲ្យបង្កើតអំព្រីយ៉ុង សម្រាប់គោលបំណងពាណិជ្ជកម្ម ឬគោលបំណងអ្វីផ្សេងពីការបង្កើតអំព្រីយ៉ុង សម្រាប់ជួយគូស្វាមីភរិយា ស្របច្បាប់ឲ្យមានកូនឡើយ») ។
- **គ.ខ.ប.ជ** ចំនួន០៦គឺ៖ ខេត្តស្ទឹងត្រែង, ព្រៃវែង, បន្ទាយមានជ័យ, បាត់ដំបង, កំពត, កំពង់ស្ពឺ បានកែសម្រួលសមាសភាពមន្ត្រីស្រុក និងមន្ត្រីឃុំ សង្កាត់ ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- **ក្រសួងអប់រំ យុវជន និងកីឡា**
    - ចេញសេចក្តីណែនាំ ស្តីពីការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ដល់គ្រប់គ្រឹះស្ថានសិក្សាទាំងអស់ទូទាំងប្រទេស ទាំងសាធារណៈ និងឯកជនឲ្យ ប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៦ ។
    - បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងការងារបញ្ជាប និងរបាយការណ៍ នៅតាមមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ដែលមានចងជាសាខានៅតាមការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ ស្រុក និងគ្រឹះស្ថានសិក្សាគ្រប់កម្រិតសិក្សា ដើម្បីពង្រឹងប្រសិទ្ធភាពការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៅតាមមូលដ្ឋានរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ចេញប្រកាសលេខ១៧៥៩ សអយ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត (ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០១៦)។

## ក.២-កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអនុវត្តច្បាប់ និងគោលនយោបាយ

### ក.២.១. កិច្ចព្រមព្រៀង-សន្ធិសញ្ញា នៃការជួយគ្នាទៅវិញទៅមក៖

- **ក្រសួងយុត្តិធម៌បានចុះហត្ថលេខាលើ៖**
  - សន្ធិសញ្ញាជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"(ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦)
  - សន្ធិសញ្ញាជាមួយប្រទេសរុស្ស៊ីស្តីពី "ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (កំពុងពិភាក្សា)
  - សន្ធិសញ្ញាស្តីពី "បត្យាប័ន"ជាមួយប្រទេសរុស្ស៊ី និងប្រទេសបារាំង(កំពុងពិភាក្សាលើការផ្តល់សច្ចាប័ន)។

### ក.២.១-អនុស្សរណៈនៃការយោគយល់គ្នា

❖ **អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខារួចហើយ**

- **រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងមហាផ្ទៃជាតំណាង និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាមានិតចិន** បានចុះកិច្ចព្រមព្រៀង ស្តីពី "**កិច្ចសហប្រតិបត្តិការ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម ស៊ី ជីនពីន** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន (ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦)។
- **ក្រសួងយុត្តិធម៌ បានចុះ**កិច្ចព្រមពៀងជាមួយបណ្តាប្រទេស ស្តីពី "ការបញ្ជូនទណ្ឌិត" (ប៉ុន្តែរង់ចាំសភាអនុម័ត) រួមមាន៖ប្រទេសអូស្ត្រាលី, ព្រះរាជាណាចក្រថៃ, ប្រទេសឥណ្ឌាសាធារណរដ្ឋសង្គមនិយមវៀតណាម និងប្រទេសរុស្ស៊ី ។
- **រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាតំណាង** បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀង ជាមួយភាគីពាក់ព័ន្ធ ចំនួន៥គឺ៖
  - កិច្ចព្រមព្រៀង (១)ស្តីពី«ការជ្រើសរើសពលករកម្ពុជា» និង (២)ស្តីពី«ការជ្រើសរើសពលករការងារផ្ទះ» រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦)។
  - (៣)អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ស្តីពី«កិច្ចសហប្រតិបត្តិការលើវិស័យការងារ» (ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦)។

- (៤)អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីនស្តីពី«កិច្ចសហប្រតិបត្តិការលើវិស័យការងារ» (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦)។
- (៥)សេចក្តីថ្លែងការណ៍រួម ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ស្តីពី«ការការពារជនទេសន្តរប្រវេសន៍ និងពលករទេសន្តរប្រវេសន៍នៃប្រទេសទាំងពីរ» ។

- **ក្រសួងមហាផ្ទៃ និង**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ជាតំណាង បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការដៃគូនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖
  - អនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពការពារកុមារ (CPU) នៃអង្គការមូលនិធិដើម្បីកុមារកម្ពុជា និងក្រសួងមហាផ្ទៃ ស្តីពី«ការរួមចំណែកដើម្បីមនុស្សធម៌» (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦) ។
  - អនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការអ្នកស្ម័គ្រចិត្តស៊ីវិល GVC ស្តីពី«គម្រោងមីហ្គ្រា-អែកស្សិន៖ ការតស៊ូមតិ ការតាមដាន និងការប្រាស្រ័យទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ដោយមិនមានសុវត្ថិភាពនៅកម្ពុជា» (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦) ។

❖ **អនុស្សរណៈនៃការយោគយល់គ្នាដែលរៀបចំរួច និងត្រៀមចុះហត្ថលេខា**

- **ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសឥណ្ឌា ស្តីពី "ការណែនាំ ដល់គ្រប់ស្ថាប័នតុលាការ និងអយ្យការគ្រប់រាជធានី-ខេត្ត" ។
- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ៖** ត្រៀមពិភាក្សាលើផែនការអនុវត្តកិច្ចព្រមព្រៀង កម្ពុជា-ចិន ស្តីពី «កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ។
- **ក្រុមការងារខេមមីត ៖** រៀបចំផែនការសកម្មភាពអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពី « ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការការពារជនរងគ្រោះ» ជាមួយភាគីថៃសម្រាប់ឆ្នាំ ២០១៦-២០១៨ ។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី «បញ្ហាសុខភាព និងសុវត្ថិភាពការងារ» ជាមួយទីភ្នាក់ងារសុខភាពនិងសុវត្ថិភាពការងាររបស់សាធារណរដ្ឋកូរ៉េ សម្រាប់ឆ្នាំ២០១៧-២០១៩ ។
- **ក្រសួងយុត្តិធម៌៖** ត្រៀមចុះសន្ធិសញ្ញា និងកិច្ចព្រមព្រៀងជាមួយបណ្តា ប្រទេសខាងក្រោម៖
  - ចុះសន្ធិសញ្ញាជាមួយប្រទេសបារាំង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" ។
  - ចុះសន្ធិសញ្ញាជាមួយសាធារណរដ្ឋប្រជាមានិតឡាវ ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" ។
  - សេចក្តីព្រាង កិច្ចព្រមពៀងជាមួយប្រទេសអង់គ្លេស ស្តីពី"ការបញ្ជូនអ្នកទោស" ។

- សេចក្តីព្រាង កិច្ចព្រមព្រៀងជាមួយប្រទេសប៉េរូ ស្តីពី"ការបញ្ជូនអ្នកទោស" ។

## ខ. លើកកម្ពស់ការបង្ការទប់ស្កាត់

កិច្ចខិតខំប្រឹងប្រែងដើម្បីបង្ការ ទប់ស្កាត់បទល្មើសជួញដូរមនុស្ស ដើម្បីលុបបំបាត់រាល់ហានិភ័យកើតមានចំពោះពលរដ្ឋកម្ពុជា និងអាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនស្ស ។ ដោយគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងកម្លាំងពលកម្មទាំងនៅក្នុងប្រទេស និងក្រៅប្រទេស និងរារាំងការធ្វើអន្តោប្រវេសន៍ចូលមកប្រទេសកម្ពុជាដោយខុសច្បាប់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដឹកនាំសម្របសម្រួល និងជំរុញការធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សយ៉ាងសកម្ម ។ ការផ្សព្វផ្សាយអប់រំ បំផុសការយល់ដឹងតាមគ្រប់រូបភាព ត្រូវបានធ្វើឡើងតាមរយៈវេទិកាសាធារណៈ កិច្ចប្រជុំ សិក្ខាសាលា តាមប្រព័ន្ធអប់រំផ្សព្វផ្សាយនានា រួមទាំងវិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្តាញសង្គមយ៉ាងទូលំទូលាយ នៅគ្រប់ទីកន្លែង ដល់មន្ត្រីរាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សាលារៀន និងប្រជាពលរដ្ឋតាមបណ្តាឃុំ សង្កាត់ ភូមិ និងសហគមន៍នានា បានចំនួន**៣០,១៩៩**លើក មានមនុស្សចូលរួមចំនួន**៣,៧៤០,២១១**នាក់ ស្ត្រីចំនួន**១,៦៧៨,២៣០**នាក់ (តិចជាងឆ្នាំ២០១៥ ដែលមានអ្នកចូលរួម**៣,៣៤៦,២៣៧**នាក់ ថយចុះចំនួន**៣៩៣,៩៧៤**នាក់) ស្មើនឹង១១,៧៧% ។

### សកម្មភាពបង្ការទប់ស្កាត់ក្នុងវិស័យអប់រំ៖

ក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលបន្ទុកការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការកសាងធនធានមនុស្សសម្រាប់ការអភិវឌ្ឍន៍ជាតិប្រកបដោយគុណភាព និងតម្រង់ទិសការសិក្សា របស់សិស្សឲ្យចាប់យកមុខវិជ្ជាដែលជាមូលដ្ឋានគ្រឹះសម្រាប់ទីផ្សារការងារ និងការងារដឹកនាំគ្រប់គ្រងសង្គម ។

ក្រៅពីការបង្កើនគុណភាពអប់រំ និងបង្កើនចំនួនសិស្ស និស្សិតឲ្យទទួលបានការសិក្សានៅគ្រប់កម្រិតនៃភូមិសិក្សា តាមរយៈការសម្រិតសម្រាំងកម្មវិធីសិក្សា ការបង្កើនចំនួនគ្រឹះស្ថានសិក្សា នៅគ្រប់កម្រិតឲ្យនៅកៀកជិតសហគមន៍ និងសិស្សានុសិស្ស ដាក់បញ្ចូលការអប់រំវិជ្ជាជីវៈ សីលធម៌រស់នៅ និងបំណិនជីវិត ឲ្យសិស្សបានត្រៀមខ្លួន ក្នុងការរស់នៅជាពលរដ្ឋល្អ និងមានជំនាញគ្រប់គ្រាន់សម្រាប់គុណភាពជីវិត ក្រសួងអប់រំបានបង្កើតកម្មវិធីមួយចំនួន ដើម្បីបង្ការទប់ស្កាត់ការបោះបង់ការសិក្សា និងការប្រថុយប្រថានចំណាកស្រុកប្រកបដោយគ្រោះថ្នាក់ថែមទៀត ។ ក្នុងនោះ**ក្រសួងអប់រំ យុវជន និងកីឡា បាន៖**

- សហការជាមួយក្រសួងមហាផ្ទៃនិងអង្គការនានាចែកបន្តោងសោដល់សិស្ស ចំនួន**៣០០** ដែលមានលេខទូរស័ព្ទទំនាក់ទំនងក្នុងករណីត្រូវការជំនួយបន្ទាន់នៅពេលមានអំពើហិង្សា និងអំពើជួញដូរមនុស្សដែលកើតមានឡើងឬក៏មានបំណងចង់ពិគ្រោះភិភាក្សារកដំណោះស្រាយករណីរឿងផ្សេងៗទៀត។
- បានបិទផ្សព្វផ្សាយផ្ទាំងរូបភាពធំ ដែលទាក់ទងនឹងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកាត់បន្ថយការជួញដូរមនុស្ស សហការផលិតដោយសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងអង្គការយេរកម្ពុជា នៅក្នុងបណ្ណាល័យកម្ពុជា ។

- បានផ្សព្វផ្សាយលេខទូរស័ព្ទជាប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍ របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ និងអង្គការ **LSCW, LICADO, CWCC** និង **WEC** នៅក្នុង បណ្ណាល័យរោងចក្រ ។
- ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អាហារូបករណ៍ដល់សិស្សមធ្យមសិក្សាបឋមភូមិសាធារណៈ កើនដល់ ៧ ៣០៨នាក់ ស្រី ៤ ៣២២នាក់ ផ្តល់អាហារូបករណ៍ ដល់សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈ ដែលកើនដល់ ២ ៦០០នាក់ ស្រី ១ ៥៦០នាក់ ប្រមូលសិស្សដែលបោះបង់ការសិក្សាឲ្យចូលរៀន ឡើងវិញ ១ ៨៨៣នាក់ ស្រី ៨២០នាក់ ផ្តល់អាហារូបករណ៍សម្រាប់សិស្សពូកែ និងសិស្សក្រីក្រ ជាពិសេសស្រី ឲ្យបានយ៉ាងតិច ៦០% នៃចំនួនសិស្សអាហារូបករណ៍ កម្មវិធីបង្កើនប្រាក់ចំណូល បាន៥៤៩នាក់ ស្រី៤០៩នាក់ ផ្តល់ឯកសារណែនាំការអនុវត្តប្រព័ន្ធរំលឹកជាមុនដើម្បីទប់ស្កាត់ការបោះបង់ការសិក្សាដល់សាលាមធ្យមសិក្សាទូទាំងប្រទេស ។
- ក្រសួងមានកម្មវិធីអប់រំសីលធម៌ ជៀសវាងអំពើហិង្សា ការរើសអើង ដោយសហការជាមួយអង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ ផ្តល់កង់៨៤គ្រឿង សម្ភារៈសិក្សាដល់សិស្សក្រីក្រ ៣១៥នាក់ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ។
- បានសហការជាមួយអង្គការទស្សនៈពិភពលោក ធ្វើកម្មវិធីទប់ស្កាត់ការជួញដូរពលកម្មកុមារ ផ្តល់ជាមធ្យោបាយធ្វើដំណើរ ឯកសណ្ឋានសិស្ស បានទទួលការបណ្តុះបណ្តាល ជំនាញងាយៗ នៅតាមមណ្ឌលសិក្សាសហគមន៍ ដើម្បីកាត់បន្ថយចំណាកស្រុករបស់ស្ត្រី និងជនពេញវ័យ បំប៉ននាយកសាលាពីវិធានការកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្សក្នុងខេត្តគោលដៅ គឺខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងសៀមរាប ចំនួន ៧៨នាក់ ស្រី ៨នាក់ ។
- ផ្តល់អនុវិទ្យាល័យ ដោយឈរលើមូលដ្ឋាន សាលាបឋមសិក្សាដែលមានស្រាប់នៅតាមតំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល ដើម្បីបង្កលក្ខណៈងាយស្រួលដល់សិស្សជាពិសេសសិស្សស្រីក្នុងការបន្តការសិក្សា ។

## ខ.១-ការប្រជុំអប់រំផ្សព្វផ្សាយ

សរុបការងារអប់រំផ្សព្វផ្សាយ ឆ្នាំ២០១៦នេះ ក្រសួងស្ថាប័នជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, គ.ខ.ប.ជ និងលេខាធិការដ្ឋាន មន្ទីរ អង្គភាព ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ និងសមត្ថកិច្ចទូទាំងប្រទេស បានសហការជាមួយអង្គការដៃគូដើម្បីធ្វើការផ្សព្វផ្សាយ អប់រំតាមរូបភាពផ្សេងៗ ទៅតាមគោលដៅរៀងៗខ្លួន ។ ដោយឡែក ក្រសួងទេសចរណ៍ បានធ្វើការប្រជុំផ្សព្វផ្សាយដល់ម្ចាស់ និងបុគ្គលិកសណ្ឋាគារទូទាំង២៥ រាជធានី ខេត្ត បាន៥២៤លើក មានអ្នកចូលរួម ២៧៣៥នាក់ ស្រី ២១០៣នាក់ ។ សរុបការប្រជុំផ្សព្វផ្សាយទាំងអស់ បាន បាន**ចំនួន ៣៤៧១លើក មានអ្នកចូលរួមសរុប ២៥៣ ០៩៤ នាក់ ស្រី១៣៣ ៤១៤នាក់** ។

## ខ.២-វេទិកាសាធារណៈ

- **នាយកដ្ឋានកណ្តាលនគរបាលព្រំដែន** បានចូលរួមផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងកម្មវិធីអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋរស់នៅតាមខ្សែបណ្តោយព្រំដែនកម្ពុជា-ថៃ ចំនួន**១១៥**លើក មានអ្នកចូលរួមសរុបចំនួន

**៣,១៣៣**នាក់ (ស្រីចំនួន**១,៧១០**នាក់) ។

- **ក្រសួងកិច្ចការនារី** បានរៀបចំវេទិកាផ្សព្វផ្សាយរួមគ្នានៅតាមតំបន់ជាប់ព្រំដែន កម្ពុជា-វៀតណាម ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅឃុំសំពៅលូន ស្រុកកោះធំ ខេត្តកណ្តាល មានអ្នកចូលរួមចំនួន**៣០០**នាក់ ។

- បានដាក់បញ្ចូលខ្លឹមសារ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាពនិងកលល្បិចជនល្មើស ទៅក្នុងការអប់រំផ្សព្វផ្សាយ និងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន**២៧ ១៤០លើក** មានមនុស្សចូលរួមសរុបចំនួន **៣ ៤៨៦ ៨៧០នាក់** ស្រីចំនួន**១ ៥៤៤ ៩៣៣នាក់** ដែលមានតួលេខក្នុងតារាងខាងក្រោម៖

***តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយនិងវេទិកាគោលនយោបាយភូមិឃុំមានសុវត្ថិភាព ( ទិន្នន័យពីបណ្តារាជធានី-ខេត្ត )***

| ល.រ | ក្រ. ស្ថាប័ន | ការផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួនដង/លើក | សរុបអ្នកចូលរួម | ចំនួនស្ត្រី | ចំនួនដង/លើក | សរុបអ្នកចូលរួម | ចំនួនស្ត្រី |
| ១ | ព្រះសីហនុ | ១៨៨ | ១៦,៦២៦ | ៨,៦២៧ | ៧០ | ៥,៧៣៦ | ១,៩៤៦ |
| ២ | កំពត | ១៨ | ១,៩០១ | ១,០៦៤ | ១០៩ | ៤,២១២ | ១,៦២១ |
| ៣ | កែប | ១១ | ១,៦៦១ | ១,០៤៣ | ២៤២ | ៧៥,៥៧៦ | ៤២,៦៦៥ |
| ៤ | តាកែវ | ៩៣១ | ១២៦,៩១៧ | ៤០,៨០៩ | ៥៣៣ | ២៤,៣៩២ | ៩,៥៩២ |
| ៥ | កណ្តាល | ៤៥២ | ១១១,៨៤២ | ៥៣,៨៥៥ | ៥៤៥ | ៦៨,៨៩៥ | ៣៥,០៩៤ |
| ៦ | ស្វាយរៀង | ១,៣៨៩ | ១៧១,០៣០ | ៥៣,៣៧៨ | ១,៨៩៤ | ១២២,១៤៩ | ៦៤,៦៦៨ |
| ៧ | ព្រៃវែង | ១០ | ៩៨២ | ៧០៩ | ៣៧ | ៧,៤៦៦ | ៤,៣៩១ |
| ៨ | កំពង់ស្ពឺ | ២០០ | ៣៥,៣៦៦ | ១១,៤៦៨ | ១,២២០ | ១៤៣,៦៥៧ | ៦៩,៣៣៤ |
| ៩ | កោះកុង | មិនមានរបាយការណ៍ | | | ៥៨ | ៣,២១៣ | ១,៥៧៥ |
| ១០ | ឧត្តរមានជ័យ | ៤៤ | ៧,៣៤៩ | ២,៨៦៧ | មិនមានរបាយការណ៍ | | |
| ១១ | ប៉ៃលិន | ៣ | ២៥០ | ២២២ | មិនមានរបាយការណ៍ | | |
| ១២ | បាត់ដំបង | ២,៣៨៧ | ២៣៤,១២២ | ១១៦,៦៦៩ | ៧០១ | ៧៥,៤៧៣ | ៣៧,៩៧៩ |
| ១៣ | ពោធិ៍សាត់ | ២,១៧៦ | ៣០៤,៥៧១ | ១៦៩,៥២៣ | ១៧៩ | ១០,៨៩០ | ៥,៥៦៥ |
| ១៤ | កំពង់ឆ្នាំង | ៣,៨៣៨ | ៥២៦,០៣៣ | ៣២០,១៨៦ | ៣,៨៥៤ | ៥២៥,៥៩៧ | ៣០៥,៩០២ |
| ១៥ | ព្រះវិហារ | ២៧៩ | ៦៨,១៧២ | ១៦,៨០១ | ៤៤ | ៣,៤៨៤ | ១,៥៩៨ |
| ១៦ | សៀមរាប | ១៥៦ | ១៤,៩៧៨ | ៩,៧៦៧ | ៣០៩ | ៣៩,៩៦០ | ២១,៥៦៦ |
| ១៧ | កំពង់ធំ | ១៤ | ៣,៥៩១ | ១,៩៧៥ | ១,០៩០ | ១២៣,៨៥៣ | ៥៧,០៤៩ |
| ១៨ | រតនគិរី | ៥៦ | ៤,៣១២ | ១,១២៤ | ១២០ | ១០២,៧៥៦ | ៤,៤៦១ |
| ១៩ | ស្ទឹងត្រែង | ៩ | ៩៤៩ | ៤៥៩ | ៤ | ២៧៣ | ១៣៧ |
| ២០ | ក្រចេះ | ៧០ | ២,២២៣ | ៩១៦ | មិនមានរបាយការណ៍ | | |
| ២១ | កំពង់ចាម | ៤៣៣ | ២៧,៣០៥ | ៧,១២១ | ៤៨៣ | ៤៩,៤០៥ | ១០,៣១០ |
| ២២ | ត្បូងឃ្មុំ | ២៣ | ៩៧៨ | ៦៤២ | ៣៥៤ | ២២,១៧៤ | ១១,៣៤៧ |
| ២៣ | មណ្ឌលគិរី | ២ | ៣៧៩ | ១៨៧ | មិនមានរបាយការណ៍ | | |
| ២៤ | រាជធានីភ្នំពេញ | | មិនមានរបាយការណ៍ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៥ | បន្ទាយមានជ័យ | ៣ | ១៥១ | ៥៤ | ២,៦០២ | ៤១៦,០២១ | ៣៨,៦៦៧ |
| សរុប | | **១២,៦៩២** | **១,៦៦១,៦៨៨** | **៨១៩,៤៦៦** | **១៤,៤៤៨** | **១,៨២៥,១៨២** | **៧២៥,៤៦៧** |
| *សរុបរួមការផ្សព្វផ្សាយថ្នាក់រាជធានី ខេត្ត* | | *២៧,១៤០លើក* | | *៣,៤៨៦,៨៧០នាក់* | | *១,៥៤៤,៩៣៣នាក់* | |

## ខ.៣. យុទ្ធនាការ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ៖

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)បានសហការជាមួយអង្គការដៃគូមួយចំនួន (UNACT, WI/USAID, Cambodia ACTs, Terre des Hommes, IJM, IOM, APLE ...) ផលិតសម្ភារៈផ្សព្វផ្សាយអប់រំ ក្នុងកម្មវិធីយុទ្ធនាការ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួម ប្រមាណ ៣០០០នាក់ ជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ រាជរដ្ឋាភិបាល និងតុលាការ អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជក កម្មករ និយោជិត សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ នឹងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។**
- គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ)ខេត្តចំនួន៩ មានខេត្តបន្ទាយមានជ័យ បាត់ដំបង ,ពោធិ៍សាត់ ,ព្រះវិហារ ,សៀមរាប, កំពង់ចាម ,តាកែវ ,កណ្តាល និងស្វាយរៀង បានសហការជាមួយអង្គការដៃគូ ផលិតសម្ភារៈផ្សព្វផ្សាយអប់រំ ក្នុងកម្មវិធីយុទ្ធនាការ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៦ ដែលមានអ្នកចូលរួម ប្រមាណ៧,៦០៦នាក់ (ស្រី២,៣៣៤នាក់) ជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ភូមិ ឃុំ អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ។

## ខ.៤ ការផលិត និងចែកផ្សាយសម្ភារៈផ្សព្វផ្សាយ

- **គ.ខ.ប.ជ ខេត្តបាត់ដំបង** បានដាក់ស្លាកសញ្ញាហាមឃាត់មិនឲ្យកុមារអាយុក្រោម១៥ឆ្នាំ ធ្វើការនៅតាមឡដុត ស្ថិតក្នុងក្រុងបាត់ដំបង និងស្រុកសង្កែចំនួន**២៦**ឡដុត ក្រោមការឧបត្ថម្ភថវិការបស់គម្រោងបំផុស ចលនាសង្គមប្រឆាំងនឹងពលកម្មកុមារ នៃអង្គការទស្សនពិភពលោក មានចំនួន**០២**ផ្ទាំង ដែលមានខ្លឹមសារ៖
  - រួមគ្នាបញ្ឈប់ពលកម្មកុមារអាយុក្រោម១៥ឆ្នាំ ធ្វើការនៅសិប្បកម្មឡដុត
  - ចូរប្រុងប្រយ័ត្ន និងហាមដាច់ខាតមិនឲ្យកុមារអាយុក្រោម១៥ឆ្នាំធ្វើការនៅទីនេះ
- **ស្នងការខេត្តឧត្តរមានជ័យ** បានចុះបិទប្រកាសច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទតាមគោលដៅក្នុងភូមិសាស្ត្រខេត្តជាប្រចាំ ។
- លើសពីនេះទៅទៀត **អង្គការដៃគូ**មួយចំនួន ក៏បានចូលរួមក្នុងសកម្មភាពអប់រំបង្ការទប់ស្កាត់យ៉ាងសកម្មផងដែរ តាមរយៈការគាំទ្រមកគណៈកម្មាធិការជាតិ គណៈកម្មាធិការខេត្ត និងតាមរយៈការផ្តល់ជំនួយទៅអង្គការដៃគូក្នុងស្រុក ដើម្បីធ្វើសកម្មភាពតាមភូមិ ឃុំ សង្កាត់ ស្រុក នៃខេត្តមួយចំនួន ដែល

បានទៅដល់ប្រជាពលរដ្ឋ រាប់ម៉ឺននាក់បន្ថែមទៀត ។ ក្នុងនោះ មានជាអាទិ៍ ៖ អង្គការ USAID តាមរយៈអង្គការវិនរ៉ក់អន្តរជាតិ(WI) អង្គការបញ្ឈប់ការជួញដូរកុមារ (Cambodia ACTs) អង្គការដែនដីមនុស្ស ហុល្លង់ (Terre des Hommes Netherland) សម្ព័ន្ធអង្គការចាប់ដៃ ជាដើម ដែលអង្គការនីមួយៗ មានដៃគូមួយចំនួនទៀត ដែលបាន និងកំពុងធ្វើសកម្មភាពតាមបណ្ដាខេត្ត ។

## ខ.៥ ការផលិត និងចែកផ្សាយសម្ភារៈផ្សព្វផ្សាយ

សម្ភារៈ ដែលត្រូវចែកផ្សាយទៅតាមកម្មវិធីអប់រំផ្សព្វផ្សាយ ជាពិសេសក្នុងយុទ្ធនាការ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ មាន៖

- អាវដែលភ្ជាប់ដោយសារអប់រំផ្សព្វផ្សាយអប់រំ
- ថង់ព័ត៌មាន ដែលមានសារ និងលេខទូរស័ព្ទទាក់ទងទៅស្ថាប័ន អង្គការ ក្នុងស្រុក និងនៅប្រទេស ស្ថានទូតដែលប្រចាំនៅប្រទេសគោលដៅ
- សៀវភៅទិន្នានុលេខ ដែលមានសារ និងទិន្នន័យស្ដីពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខិតប័ណ្ណដែលមានសារអប់រំអំពីចំណាកស្រុកដោយសុវត្ថិភាព
- បដា ពាក្យស្លោក
- សិល្បៈដែលមានអត្ថន័យអប់រំ
- បទយកការណ៍
- ខ្សែភាពយន្ត រឿងអប់រំខ្លីៗ ជា CD, VCD
- ... ។ល។

## ខ.៦ ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្កើតព័ត៌មានតាមរយៈប្រព័ន្ធអេឡិកត្រូនិកដូចជា៖ ប្រព័ន្ធអ៊ីមែល(Email) ទ្វីតធ័រ(Twitter) ហ្វេសប៊ុក(Facebook) តេលេក្រាម(Telegram) មេស៊ិនជ័រ(Messenger) និងទូរស័ព្ទ(Telephone) ដើម្បីធ្វើការផ្សព្វផ្សាយអំពីសកម្មភាពរបស់គណៈកម្មាធិការជាតិជាសាធារណៈ រហូតដល់អន្តរជាតិ ថែមទៀត ដើម្បីធានានូវភាពងាយស្រួល និងទាន់ពេលវេលា ។
- **ក្រសួងអប់រំ យុវជន និងកីឡា** បានបង្កើត និងដំណើរការប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍តាមប្រព័ន្ធទំនាក់ទំនងសង្គម ក្នុងរង្វង់សាលារៀនមកមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត និងមកពីក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងក្នុងរង្វង់សមាជិកក្រុមការងារអន្តរក្រសួង ស្ថាប័ន ដើម្បីផ្ដល់ព័ត៌មានទាក់ទងសកម្មភាពការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ។
- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** សហការជាមួយចាងហ្វាងផលិតកម្មភាពយន្ត និងក្រុមហ៊ុននាំចេញនាំចូលភាពយន្តឲ្យដំឡើងសារអប់រំ ស្ដីពីផលប៉ះពាល់នៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ និងការជួញដូរផ្លូវភេទ ក្នុងផលិតកម្មខ្សែភាពយន្ត ចម្រៀងកាយវិការ និងចម្រៀងខារ៉ាអូខេ ។
- **មន្ទីរព័ត៌មានខេត្តសៀមរាប** សហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមធ្វើជាវាគ្មិន ក្នុងកម្មវិធី«សន្ទនាមតិ» និងកម្មវិធី«យើងធ្វើបាន» ដើម្បីធ្វើ

ការផ្សព្វផ្សាយ ពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកដោយមិនស្របច្បាប់ ជាពិសេស គឺការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលក្នុងខេត្ត បានចំនួន**៧០**ប្រធានបទ ។

- **ខេត្តកំពត** បានបញ្ចាំងខ្សែភាពយន្តរឿង" **ជើងមេឃនៅឯណា**" បានចំនួន**១០**លើក អ្នកចូលរួមចំនួន**៣៩០**នាក់ (ស្រី**១៩៤**នាក់) ។
- **លេខាធិការដ្ឋាននៃបណ្តាគណៈកម្មាធិការខេត្ត** ផ្សព្វផ្សាយតាមវិទ្យុខេត្ត បានចំនួន**៥២**លើក ក្នុងនោះ៖ (បាត់ដំបង**០៨**លើក, កំពង់ចាម**០២**លើក, រតនគិរី**០២**លើក, សៀមរាប**៤០**លើក) ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កិច្ចការពារជនរងគ្រោះ ឧបាយកលជនល្មើស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព គ្រោះថ្នាក់ផ្សេងៗដោយការធ្វើទេសន្តរប្រវេសន៍ការងារ ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ការការពារសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើកុមារ និងការទប់ស្កាត់អំពើជួញដូរមនុស្ស ។

## ខ.៦ ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍

### ខ.៦.១-ការគ្រប់គ្រងស្ថិតិចំណាកស្រុករបស់ពលរដ្ឋខ្មែរតាមខែនីមួយៗ

យោងតាមស្ថិតិរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានស្រង់ទិន្នន័យអំពីពលរដ្ឋចំណាកស្រុក ក្នុងមូលដ្ឋានទូទាំងប្រទេស បានពិនិត្យឃើញថា ពលរដ្ឋចំណាកស្រុកទៅក្រៅប្រទេសនៅតែបន្តកើតមានឡើង ជាក់ស្តែងក្នុងឆ្នាំ២០១៦នេះ មានដូចតួលេខក្នុងតារាងខាងក្រោម៖



*តារាងតាមដានបច្ចុប្បន្នភាពទេសន្តរប្រវេសន៍របស់ពលរដ្ឋខ្មែរ ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ (ក្នុងនិងក្រៅប្រទេស)*

| ប្រចាំខែ | ឆ្នាំ២០១៤ | | | | ឆ្នាំ២០១៥ | | | | ឆ្នាំ២០១៦ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនរួម | ស្រី | ចំនួនកុមារ | | ចំនួនរួម | ស្រី | ចំនួនកុមារ | | ចំនួនរួម | ស្រី | ចំនួនកុមារ | |
| | | | សរុប | កុមារី | | | សរុប | កុមារី | | | សរុប | កុមារី |
| មករា | ៣៣០,០៣២ | ១៣៧,៣២៧ | ០ | ០ | ២៥០,៤៥០ | ១០៧,៧៨២ | ៨,៣៥៧ | ៣,២០៥ | ៤៩០,៤០៧ | ២១៧,០៣១ | ១២,០០៣ | ៤,៥៨០ |
| កុម្ភៈ | ៣៤៤,៦៤៣ | ១៤៤,៥១២ | ១២,៤៨៤ | ៤,៩០៩ | ២៧០,៤២៧ | ១១៧,៦២៨ | ៩,៣៧៣ | ៣,៤៩៨ | | | | |
| មីនា | ៣៥៩,៦៥៣ | ១៤៨,៤៥៩ | ០ | ០ | ២៧៤,៣៧៣ | ១១៧,៥៧០ | ៩,៥០៦ | ៣,៥៦៩ | ២៩៧,៤៩៦ | ១៣០,១៤០ | ៣,៣៦៦ | ២,០៣២ |
| មេសា | ៣៧៣,៦១៦ | ១៥៤,៦០០ | ១២,៩៤៨ | ៥,០២៥ | ៤១៦,១៧៤ | ១៨៦,៨៤៧ | ៩,៨០៦ | ៣,៦៦០ | ២៩១,០៨៤ | ៦១,៩០៩ | ៦,០៧០ | ២,៣៩១ |
| ឧសភា | ៤០៧,៤៨៩ | ១៣,៨៧១ | ១៣,៨៧១ | ៥,៣៥០ | ៤២៨,៨៤២ | ១៨៨,៤៧១ | ៩,៦៣០ | ៣,៥៦០ | ២៩០,៧២៤ | ១២៨,៩៦៧ | ៥,៦៦៤ | ២,២៤០ |
| មិថុនា | | | | | ៤៣១,៦១៦ | ១៩៤,៤៥៥ | ១០,១៤៧ | ៣,៧៨១ | ២៩៩,២៥៤ | ១៣០,២០២ | ៥,៨១៧ | ២,២៦២ |
| កក្កដា | ២០៧,៥៨២ | ៨៧,២៤៦ | ៧,៥៥៩ | ២,៩៥១ | ៤៣៨,១៦០ | ២០២,១៣៧ | ១០,១០៧ | ៣,៧៣២ | ៣០១,៨០៦ | ១៣៧,៥០០ | ៥,៧៥១ | ២,២២៥ |
| សីហា | ២២៨,៣៧៩ | ៩៤,៦៦៦ | ៧,៩២៣ | ១,៣៩៨ | ៤៥៣,៤៦៣ | ២០០,៣៩៣ | ១០,៨៣៥ | ៣,៧៦៩ | ៣០២,២៩៥ | ១៣៦,៧៦២ | ៥,៨១៣ | ២,២៤៧ |
| កញ្ញា | ២៤៣,៨៩១ | ១០២,០០៤ | ៨,៧៧២ | ៣,៣១៧ | ៤៥៩,៤០៦ | ២០៤,១១៤ | ១០,៨៩៩ | ៣,៧៨៩ | ៣០៩,០៥៦ | ១៤១,៦២១ | ៥,៧៣៥ | ២,២៣០ |
| តុលា | ២៥២,៧៦៥ | ១០៥,៨១៩ | ៩,០២១ | ៣,៣៥៧ | ៤៧២,២០៥ | ២១០,៨១៤ | ១១,៤៣៨ | ៤,០០៦ | ៣១៣,២៨៥ | ១៤១,៦៩៥ | ៦,២០៨ | ២,៣៦៩ |
| វិច្ឆិកា | ២៤១,៣៧៥ | ១០១,៦៤៥ | ៨,៨៤៧ | ៣,៣០៦ | ៤៥០,៨៤៥ | ២០០,៧៦០ | ១១,០៩០ | ៣,៩០៦ | ៣១៥,៦៦៩ | ១៤២,៨៩៨ | ៦,២៧០ | ២,៣៩៨ |
| ធ្នូ | ២៦៨,៧៣២ | ១១៣,៦៩១ | ៩,០៥៨ | ៣,៣៩១ | | | | | ៣១៨,៥៣៣ | ១៤៣,៦០០ | ៦,២៩១ | ២,៤០៣ |

## ក្រាហ្វិកប្រៀបធៀបនៃចំណាកស្រុក (តាមរបាយការណ៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ តាមខែ) ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦




### ៤.៦.២-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសឯកជន

*ស្ថិតិពលករស្របច្បាប់ដែលបានបញ្ជូនចេញ តាមប្រព័ន្ធផ្លូវការ ឬស្របច្បាប់(ក្នុងឆ្នាំ២០១៦)*

ក្នុងការបញ្ជូនពលករទៅបរទេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំណត់ឲ្យទីភ្នាក់ងារជ្រើសរើសនីមួយៗធ្វើការបង្ហាត់ បង្រៀនភាសា បណ្តុះបណ្តាលជំនាញបឋម របៀបរបបធ្វើការងារ ច្បាប់ជាធរមានរបស់ប្រទេសទទួលពលករ របៀបរបប រស់នៅ និងធ្វើការងារ ទំនៀមទម្លាប់ ប្រពៃណីនៃពលរដ្ឋប្រទេសទទួល និងត្រូវរៀបចំឯកសារផ្លូវច្បាប់ ក៏ដូចជាឯកសារបញ្ជាក់អំពីកន្លែងធ្វើការជាក់លាក់មុននឹងបញ្ជូនពលករម្តងលើកៗ ដោយត្រូវនាំពលករទៅដាក់ឲ្យបានដល់ទីកន្លែងធ្វើការពិតប្រាកដ ។

ស្ថិតិបានបង្ហាញថា ឆ្នាំ២០១៦ មានក្រុមហ៊ុនឯកជនចំនួន៦០ បានធ្វើការជ្រើសរើស បញ្ជូន និងគ្រប់គ្រងពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅចំនួន៤ប្រទេស ក្នុងនោះតាមរយៈទីភ្នាក់ងារជ្រើសរើសពលករ និងតាមរយៈប្រព័ន្ធអនុញ្ញាតការងារទៅប្រទេសកូរ៉េ (EPS) របស់រាជរដ្ឋាភិបាល សរុបចំនួន**៣០,៨២៥/២៥,២៦៣**នាក់ មានការកើនឡើង៤,៨៦២នាក់ ស្មើនឹង**១៨.៧២%** (ស្រីចំនួន**១២,១២៥**នាក់) មានដូចខាងក្រោម៖

- ទៅប្រទេសម៉ាឡេស៊ី ចំនួន**១២៣**នាក់ (ស្រី**៩៣**នាក់)
- ទៅប្រទេសថៃ ចំនួន**២១,៦៨២**នាក់ (ស្រី**៩,១៩១**នាក់)
- ទៅប្រទេសជប៉ុន ចំនួន**១,៥៦២**នាក់ (ស្រី**៨៨៦**នាក់)
- ប្រទេសសិង្ហបុរី ចំនួន**៨៧**នាក់ (ស្រី**៨៧**នាក់)
- ទៅប្រទេសកូរ៉េ ចំនួន**៧,៣៧១**នាក់ (ស្រី**១,៨៦៨**នាក់)






តាមរបាយការណ៍ពីអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដែលទទួលបានពីបណ្តាច្រកទ្វារអន្តរជាតិ ទាំង២៤ បានបង្ហាញថាទីភ្នាក់ងារបាននាំចេញពលករចំនួន ៥៩.៧៤៧នាក់ ទៅប្រទេសចំនួន ៦ គឺ ថៃ(៥១១៤៩នាក់ ស្រី ១៥៨នាក់) ម៉ាលេស៊ី (៣៤៣នាក់ ស្រី ២៧១នាក់)កូរ៉េខាងត្បូង (៧០៣៧នាក់ ស្រី១៦០៤នាក់) ជប៉ុន(១១៤៩នាក់ ស្រី៨៧៦នាក់) សិង្ហបុរី (៥៨នាក់ ស្រី៥៦នាក់) និង ប៉ាពូញូហ្គីនេ (១១នាក់ ស្រី០) ។

## ខ.៦.៣-ស្ថានភាពលំហូរជនទេសន្តរប្រវេសន៍ (ខេត្តបន្ទាយមានជ័យ)

តាមរបាយការណ៍ពីគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តបន្ទាយមានជ័យ ឆ្នាំ២០១៦ ក្រុមការងារទទួលជនទេសន្តរប្រវេសន៍បានឲ្យដឹងថា ថៃបានបញ្ជូនពលករត្រឡប់មកប្រទេសកម្ពុជាវិញក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិ សរុបចំនួន**១ ១៥៩ជើង/រថយន្ត** មានពលករខ្មែរចំនួន**៤៩ ៩៨៧**នាក់ ស្រីចំនួន **១៦ ២៦១**នាក់ កុមារ **៤ ២៦៤**នាក់ (កុមារី **១ ៧៤៦**នាក់)។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ មានចំនួន **៥៥ ៦២៦**នាក់ គឺមានការថយចុះចំនួន**៥ ៧៤៦**នាក់ ស្មើនឹង**១០.៣២%** ។ តាមរយៈការសម្ភាសខ្លី បានរកឃើញថា៖

- បានចេញតាមច្រកអន្តរជាតិ **២១ ៤៨៣** នាក់ តាមច្រករបៀង **២៨ ៥០៤** នាក់
- ចេញដោយខ្លួនឯង **២៣ ៣៧៨** នាក់ តាមគេនាំ **២៦ ៦០៩** នាក់
- **<u>បានជាប់ពន្ធនាគារ លើសពី ១ខែ មាន *១ ៧៨៤* នាក់</u>** ។

តាមការសម្ភាសបានឲ្យដឹងថា ពលករខ្លះជាប់ពន្ធនាគារ ពី៤ឆ្នាំ ដល់ ១៥ឆ្នាំ ដោយមូលហេតុ៖ស៊ីឈ្នួលកាន់គ្រឿងញៀន ចូលទៅលួចកាប់ឈើគ្រញូង ស៊ីឈ្នួលដឹករបស់ក្លែងក្លាយ កាន់លិខិតឆ្លងដែនក្លែងបន្លំដែលមេខ្យល់ឲ្យកាន់ ចំណែកអ្នកជាប់ឃុំរយៈពេល២ខែ ភាគច្រើនជាអ្នកគ្មានប័ណ្ណស្នាក់នៅ ។

ក្រុមការងារបានសម្ភាសពលករចំនួន**៣ ០៣៨**នាក់ (ស្រី**១ ១៨៨**នាក់) ដើម្បីពិនិត្យរកអត្តសញ្ញាណជនសង្ស័យនាំមនុស្សឆ្លងដែន តែពុំមានការផ្តល់ព័ត៌មានពីជនសង្ស័យជាមេខ្យល់ឡើយ ។

តាមការសម្ភាសកុមារ**៥៧១**នាក់ (កុមារី **២៣០**នាក់) រកឃើញថា៖

- កុមារ**៣៤៣**នាក់ ទៅតាមឪពុក ម្តាយ ធ្វើការនៅការដ្ឋានសំណង់

- កុមារ**២២៨**នាក់ ទៅតាមបងប្អូន ទៅធ្វើការដកដំឡូង និងធ្វើការនៅការដ្ឋានសំណង់។

ដោយឡែក ពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យ នៅក្នុងឆ្នាំ២០១៦នេះ បានធ្វើចំណាកស្រុកចំនួន**១២៥ ៨២៦**នាក់ (ស្រី **៥៣ ៤៨៩**នាក់, កុមារ **១ ១៨៥**នាក់) បើប្រៀបធៀប នឹងឆ្នាំ២០១៥ ចំនួន **៥៦ ៤៧៤**នាក់ គឺមានការកើនឡើងចំនួន **៦៩ ៣៥២**នាក់ (កើន១២២,៨០%) ក្នុងនោះ៖

- ពលរដ្ឋក្នុងខេត្ត ដែលត្រឡប់មកវិញ មាន **២០ ០៣២**នាក់ (ស្រី **៩ ៣៧៤**នាក់ កុមារ**៣២៩**នាក់) ។

### ខ.៦.៤-ស្ថិតិពលករដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេស តាមច្រកព្រំដែន

**របាយការណ៍ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍** ក្នុងឆ្នាំ២០១៦នេះ តាមបណ្តាច្រកទ្វារអន្តរជាតិ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរចំនួន១៩ប្រទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ មានចំនួន **១១១ ៧៦៦**នាក់ ស្រី **២០ ៨៦៣**នាក់ និងកុមារ**៤ ៨៣២**នាក់ (ច្រើនជាងគេមកពីប្រទេសថៃ **១០២ ២៦៩**នាក់ ម៉ាឡេស៊ី **៥៥២**នាក់ កូរ៉េខាងត្បូង**៤៣៨**នាក់ វៀតណាម**១០៥**នាក់ ចិន**៦៦**នាក់ ឥណ្ឌូនេស៊ី**៤៦**នាក់ និងអាមេរិក**៤២**នាក់) ។

## ខ.៧-ការផ្តល់ភាពស្របច្បាប់ដល់ពលករនៅក្រៅប្រទេសៈ

តាមរបាយការណ៍ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានពលករខ្មែរកំពុងនៅធ្វើការនៅប្រទេស ថៃប្រមាណ ១ ០៦០ ០០០នាក់ ក្នុងនោះ ពលករ ៣៦០ ០០០នាក់ មិនទាន់មានឯកសារស្របច្បាប់នៅឡើយ ។ ក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងសហការជាមួយក្រសួងការងារថៃ ផ្តល់លិខិតឆ្លងដែន លិខិតធ្វើដំណើរ និងប័ណ្ណអនុញ្ញាតការងារ ដើម្បីអាចស្នាក់នៅ និងធ្វើការងារស្របច្បាប់ក្នុងប្រទេសថៃ ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម បានផ្តល់លិខិតធ្វើដំណើរ(ថ្មី) ជូនពលករកម្ពុជាធ្វើការនៅបរទេស ចំនួន ២៣ ៦៩៧ក្បាល និងបោះពុម្ពលិខិតឆ្លងដែនធម្មតា និងលិខិតធ្វើដំណើរពលករទៅប្រទេសថៃ ចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៦ សម្រេចបាន ២៣៤ ៦៥៣ ក្បាល តែបានផ្តល់ហើយ លិខិត ទាំងពីរប្រភេទ បានតែចំនួន ៣៦ ៤៧៨ ក្បាល (១៥.៥៥%) ប៉ុណ្ណោះ ។

## ខ.៨-វិធានការគ្រប់គ្រងជំនាញ

### ខ.៨.១-ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញ

ក្រុមការងារចម្រុះអធិការកិច្ច ហត្ថពលកម្មបរទេស បានចុះត្រួតពិនិត្យសហគ្រាស គ្រឹះស្ថាននានា បានចំនួន៣៥៥៣គោលដៅ មានពលករបរទេសសរុប ចំនួន ២៧ ០៩១នាក់ (ស្រី ៨ ៥៥២នាក់) មាន៨១សញ្ជាតិ ។ បានផាកពិន័យជនបរទេសប្រកបមុខរបរ និងគ្មានប័ណ្ណការងារ ចំនួន១ ៣០៥នាក់ គិតជាប្រាក់ស្មើនឹង ៦៥២ ៥០០ ០០០រៀល ។ តាមរយៈការត្រួតពិនិត្យនេះ បានជម្រុញឲ្យពលករបរទេសជាច្រើន អនុវត្តច្បាប់កម្ពុជា ដោយបានទៅធ្វើប័ណ្ណការងារ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាបន្តបន្ទាប់ ។

នាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចជាសមត្ថកិច្ចខេត្តស្ទឹងត្រែង និងខេត្តកោះកុង បានធ្វើការបង្ការទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសឡាវ និងប្រទេសថៃ ជាបន្តបន្ទាប់ ។

តាមបណ្តាច្រករបៀងនៅខេត្តបាត់ដំបង ដែលជាទីតាំងឈរជើងរបស់កងកម្លាំងនគរបាលវរៈការពារព្រំដែនគោកលេខ៨១៧, ៨១៩, ៨២៣ និងលេខ៣១០ បានធ្វើការទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែល

ព្យាយាមឆ្លងកាត់ព្រំដែនទៅប្រទេសថៃដោយខុសច្បាប់។ ជាមួយគ្នាដែរ នគរបាលប៉ុស្តិ៍បឹងកេងនៃអធិការដ្ឋាននគរបាល នៃខេត្តបន្ទាយមានជ័យ ស្រុកម៉ាឡៃបានសហការជាមួយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងវរៈការពារព្រំដែន ៨១៥ និង៩១១ ចុះទប់ស្កាត់ និងអប់រំណែនាំដល់ពលករបម្រុងធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅប្រទេសថៃដោយមិនមានច្បាប់ត្រឹមត្រូវ ឬតាមរយៈ មេខ្យល់ ។

## តារាងសកម្មភាពបង្ការ និងទប់ស្កាត់

| ល.រ | ឈ្មោះអង្គភាព និងលេខាធិការដ្ឋាន គ.ខ.ប.ជ | សកម្មភាពទប់ស្កាត់ | ចំនួនលើក | ចំនួនរួម | ស្រី | អនីតិជន |
|---|---|---|---|---|---|---|
| ១ | នាយកដ្ឋានកណ្តាលនគរបាលព្រំដែន | ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ។ | ១០០ | ១,០៤៥ | ២៣៧ | ៧៣ |
| ២ | ខេត្តបាត់ដំបង | កងកម្លាំងនគរបាល វរៈការពារព្រំដែន គោកលេខ ៨១៧, ៨១៩, ៨២៣, ៣១០ ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែលត្រៀម ធ្វើចំណាកស្រុក ។ | ០៥ | ២៤ | ១២ | ០០ |
| ៣ | ខេត្តបន្ទាយមានជ័យ | កងកម្លាំងនគរបាលវរៈការពារព្រំដែនគោក លេខ ៨១៥ និង៩១១ ឈរជើងនៅប៉ុស្តិ៍បឹងកេង បានធ្វើការទប់ស្កាត់សកម្មភាព ចំណាកស្រុករបស់ពលករខ្មែរទៅរកការងារធ្វើ ដោយខុសច្បាប់នៅប្រទេសថៃ ។ | ២២ | ៧២៧ | ៣២៧ | ៣៥ |
| ៤ | ខេត្តស្ទឹងត្រែង | ស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការទប់ស្កាត់ពលករ ខ្មែរមកពីខេត្តពោធិ៍សាត់ បម្រុងទៅរកការងារធ្វើដោយខុសច្បាប់នៅប្រទេសឡាវ ។ | ០១ | ១០ | | ០០ |
| ៥ | ខេត្តកោះកុង | សមត្ថកិច្ចខេត្តបានទប់ស្កាត់ពលករខ្មែរមកពីខេត្តកំពង់ចាម និងខេត្តព្រៃវែង ដែលបម្រុងឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។ | ០១ | ៤៩ | ០០ | ០០ |
| *សរុប* | | | *១២៥* | *១,៦១១* | *៤៦៤* | *១០៨* |

## វិធានការបង្ការទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

ឆ្នាំ២០១៦នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមបណ្តាគោលដៅ និងទទួលបានលទ្ធផលដូចខាងក្រោម៖

- **ស្នងការដ្ឋាននគរបាល**ខេត្តតាកែវ, ក្រចេះ, កំពង់ឆ្នាំង, មណ្ឌលគិរី, ព្រះវិហារ, ស្ទឹងត្រែង, កំពត, កណ្តាល, និងខេត្តកោះកុង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសអាជីវកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្មទាំង**៥២៤**គោលដៅ ដល់មនុស្សចំនួន**២,៧៣៥**នាក់ ស្រី**២,១០៣**នាក់។
- ធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទទាំង ២៥រាជធានី-ខេត្ត ចំនួន**៧១**គោលដៅក្នុងនោះអំពើជួញដូរមនុស្សមាន**០៥**គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទមានចំនួន**៦៦**គោលដៅ ហើយត្រូវបានឃ្លាំមើលនិងត្រួតពិនិត្យជាប្រចាំពីអាជ្ញាធរមាន

សមត្ថកិច្ចនៅមូលដ្ឋាន។

- **ស្នងការដ្ឋាននគរបាលខេត្ត៖** ស្វាយរៀង, សៀមរាប, ព្រៃវែង, ឧត្តរមានជ័យ, កំពង់ធំ, កំពង់ឆ្នាំង, កំពង់ស្ពឺ, មណ្ឌលគិរី និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានមុខសញ្ញាអាជីវកម្មផ្លូវភេទ ចំនួន**២៨៣**លើក។
- **នាយកដ្ឋានកណ្តាលនគរបាលព្រំដែន** បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានមុខសញ្ញាឆ្លងដែនខុសច្បាប់នៅតាមព្រំដែនសរុបចំនួន**៦៦០២/៤៨៧៧លើក** កើន**១៧២៥**លើក ក្នុងនោះម្ចាស់ការ **២៩៦១**លើក អង្កេតតាមព្រំដែនកម្ពុជា-ថៃចំនួន**៧៦២**លើក, ព្រំដែនវៀតណាមចំនួន**២១២៦**លើក, និងព្រំដែនឡាវចំនួន**៧៣**លើក ។

## ខ.៧.២ ការបង្ការទប់ស្កាត់ភាពរងគ្រោះតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

ដោយបន្តភារកិច្ចពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកពិនិត្យ និងចុះបញ្ជីបែបបទ នៃការទទួលពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស របស់ក្រសួងមហាផ្ទៃ បានប្រមូលផ្តុំឲ្យមានការចូលរួមទទួលខុសត្រូវ រួមពីអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ តាមដានភាពមិនប្រក្រតីក្នុងការរៀបអាពាហ៍ពិពាហ៍ជាអន្តរជាតិ ដែលអាចបង្កប់គោលដៅទុច្ចរិត និងបង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋ ដោយអំពើរត់ពន្ធ ឬជួញដូរមនុស្ស។ ក្នុងឆ្នាំ២០១៦នេះ អ្នកដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ មានចំនួន**១ ៥៤១**គូ ។ ដោយសារមានការត្រួតពិនិត្យ និងរឹតបន្តឹងឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងប្រព័ន្ធនេះ មិនទាន់មានលេចចេញជាបញ្ហាពាក់ព័ន្ធនឹងការជួញដូរមនុស្ស ឬការជួញដូរផ្លូវភេទនៅឡើយទេ ក៏ប៉ុន្តែមានព័ត៌មាន ស្តីពីភាពរងគ្រោះដោយអំពើហិង្សា និងការលែងលះ ។

ទន្ទឹមនឹងនេះ មានបាតុភាពពាក់ព័ន្ធនឹងការស្វែងរកគូស្រករដោយខុសច្បាប់ នៅក្រៅប្រទេស តាមរយៈមេខ្យល់ ជាពិសេសទៅប្រទេសចិន ដែលនាំឲ្យមានជនរងគ្រោះ ដោយការជួញដូរភេទ ឬរំលោភបំពានផ្លូវភេទ ត្រូវបានបញ្ជូនត្រឡប់ជាបន្តបន្ទាប់ ។

ក្រៅពីនេះយើងក៏បានធ្វើការសាកសួរសុខទុក្ខ ប្រជាពលរដ្ឋខ្មែរដែលរៀបអាពាហ៍ពិពាហ៍ទៅរស់នៅក្រៅប្រទេស ដោយទំនាក់ទំនងផ្ទាល់ តាមរយៈទូរស័ព្ទបានចំនួន**២២៤**លើក។

## ខ.៧.៣ លទ្ធផលនៃកិច្ចសម្ភាសន៍ពលករ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

ក្នុងឆ្នាំ២០១៦នេះ យោងតាមរបាយការណ៍អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា និងស្ថានទូតប្រចាំគោលដៅ បានប្រមូលទិន្នន័យអំពីពលករទេសន្តប្រវេសន៍រងគ្រោះ និងរៀបចំការដើម្បីជួយដល់ពលករទេសន្តប្រវេសន៍ទាំងនោះ ដើម្បីវិលមកប្រទេសវិញ ។

**ទិន្នន័យពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៦ បានជួយសង្គ្រោះ និងធ្វើការសម្រួលមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរក្រៅ

ប្រទេស សរុបចំនួន**៨១៥នាក់** (ក្នុងនោះ ក្រសួងរកឃើញ **ជនសង្ស័យរងគ្រោះដោយការជួញដូរ និងបទល្មើសផ្សេងៗ** មានចំនួន**៣៦៦**នាក់) មានដូចជា៖

- ប្រទេសវៀតណាម ចំនួន**២៣១**នាក់ (នាំទៅរៀបអាពាហ៍ពិពាហ៍នៅចិន០៨នាក់ផ្លូវភេទ**០២**នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន**២៧២**នាក់ (ជួញដូរពលកម្ម**៥៩**នាក់ ផ្លូវភេទ**០១**នាក់)
- ប្រទេសថៃ ចំនួន**១៣៩**នាក់ (រស់នៅនិងធ្វើការខុសច្បាប់**១១០**នាក់ ក្លែងត្រា**០២**នាក់ កាប់ឈើ**២២**នាក់និងបំពានពីថៅកែ**០៥**នាក់)
- ប្រទេសឥណ្ឌូនេស៊ី ចំនួន**៧៨**នាក់ (ពលករខុសច្បាប់**៧៦**នាក់ ស្ត្រីត្រូវគេបោកយកទៅរៀបការ**០១**នាក់ និងកូន**០១**នាក់)
- ប្រទេសចិន ចំនួន**៦៤**នាក់ (រៀបការប្តីចិន**៤១**នាក់ រស់នៅខុសច្បាប់**០៩**នាក់ និងបោកថាយកទៅរៀន**១៤**នាក់)
- ប្រទេសជប៉ុន ចំនួន**១៦**នាក់ (កម្មសិក្សាការី**០៩**នាក់ និងជួញដូរផ្លូវភេទ**០៧**នាក់)
- ប្រទេសសិង្ហបូរី ចំនួន**០៦**នាក់ (ធ្វើជាស្រីខារ៉ាអូខេ**០៣**នាក់ និងបម្រើការផ្ទះ**០៣**នាក់)
- ប្រទេសឡាវ ចំនួន**០២**នាក់ (រៀបការ និងរស់នៅខុសច្បាប់)
- ប្រទេសអូស្ត្រាលី ចំនួន**០១**នាក់ (រស់នៅខុសច្បាប់)
- ប្រទេសអារ៉ាប៊ីសាអូឌីតចំនួន**០១**នាក់ (ធ្វើការខុសច្បាប់)
- *ប្រទេស*រុស្ស៊ី ចំនួន**០២**នាក់ (ធ្វើការខុសច្បាប់)
- ប្រទេសសូម៉ាលី ចំនួន**០៤**នាក់ (ចោរសមុទ្រសូម៉ាលីចាប់ជំរិត)។

**ទិន្នន័យពីអគ្គស្នងការដ្ឋាននគរបាលជាតិ៖**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួល និងសម្ភាសន៍ពលករ ពលការិនីរងគ្រោះ សរុបចំនួន**២៩៨**នាក់ ស្រី**១២៧**នាក់ មកពីប្រទេសមួយចំនួន ដូចខាងក្រោម រកឃើញថា ៖

ស្ថានភាពនៃភាពរងគ្រោះ

| បញ្ជូនពី | សរុប | | នេសាទ | | ការងារផ្ទះ | | រៀបការ | | ពលករទូទៅ | | កូនក្មេង | | បួស | | ស្លាប់ | | មកវិញតាម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | រួម | ស្រី | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ទូត | ទូត+MOI |
| ឥណ្ឌូនេស៊ី | ៧១ | ០ | ៧១ | | | | | | | | | | | | | | | ៧១ |
| ម៉ាឡេស៊ី | ១០០ | ៦២ | ២៩ | | ៦ | ៥៨ | | | ២ | ៤ | ១ | | | | | | | ១០០ |
| ចិន | ៦៣ | ៤៧ | | | | | | ៤២ | ១៦ | ៥ | | | | | | | | ៦៣ |
| អារ៉ាប់ប៊ីសាអូឌីត | ១ | ១ | | | | ១ | | | | | | | | | | | | ១ |
| សូម៉ាលី | ៤ | ០ | ៤ | | | | | | | | | | | | | | | ៤ |
| តៃវ៉ាន់ | ១ | ០ | ១ | | | | | | | | | | | | | | | ១ |
| ថៃ | ៤៣ | ៧ | ១៣ | | | | | | ១០ | ២ | | | ៨ | ៣ | ៥ | ២ | ៤៣ | |
| វៀតណាម | ១៥ | ១០ | ៦ | | | | | ៩ | | | | | | | | | ១៥ | |
| *សរុប* | *២៩៨* | *១២៧* | *១២៤* | *០* | *៦* | *៥៩* | *០* | *៥១* | *២៨* | *១១* | *១* | *០* | *៨* | *៣* | *៥* | *២* | *៥៨* | *២៤០* |

មូលហេតុនៃទេសន្តរប្រវេសន៍

| | សរុបរួម | ខ្លួនឯង | មេខ្យល់ | ក្រុមហ៊ុន | បងប្អូន | មិត្តភក្ត |
|---|---|---|---|---|---|---|
| ឥណ្ឌូនេស៊ី | **៧១** | ៤៦ | | | ៨ | ១៧ |
| ម៉ាឡេស៊ី | **១០០** | ១៩ | ៤១ | ៣៩ | | ១ |
| ចិន | **៦៣** | ៤ | ៥៩ | | | |
| អារ៉ាប់ប៊ីសាអូឌីត | **១** | | ១ | | | |
| សូម៉ាលី | **៤** | | | ៤ | | |
| តៃវ៉ាន់ | **១** | | | ១ | | |
| ថៃ | **៤៣** | ២៣ | ២០ | | | |
| វៀតណាម | **១៥** | | ១០ | | | ៥ |
| *សរុប* | *២៩៨* | *៩២ នាក់* | *១៣១ នាក់* | *៤៤ នាក់* | *៨ នាក់* | *២៣ នាក់* |




***សម្គាល់៖*** *តាមរបាយការណ៍ពីទីចាត់ការ ការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ ពលករកម្ពុជាដែលបានស្លាប់នៅក្នុងទឹកដីថៃដោយគ្រោះថ្នាក់ផ្សេងៗ ត្រូវបានអាជ្ញាធរថៃបញ្ជូនសាកសពមកកម្ពុជា ក្នុងឆ្នាំ២០១៦ មាន ១៧៣លើក មានសព ១៨១ (សពស្ត្រី ៣០) ។*

## គ.៣ ទ្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន១៨ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ, បាត់ដំបង, កំពង់ចាម, កំពង់ឆ្នាំង, កំពង់ធំ, កណ្តាល, មណ្ឌលគិរី, ភ្នំពេញ, ព្រៃវែង, ពោធិ៍សាត់, រតនគិរី, សៀមរាប, ព្រះសីហនុ, ក្រចេះ,ស្វាយរៀង, និងខេត្តតាកែវ។

### គ.១ ការងារអនុវត្តច្បាប់

#### គ.១.១ ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ដោយមានការដឹកនាំ និងកិច្ចសហការសម្របសម្រួលយ៉ាងជិតស្និទ្ធ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយស្ថាប័នអនុវត្តច្បាប់ មានអគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថ អគ្គព្រះរាជអាជ្ញា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងស្ថាប័នតុលាការ បានធ្វើឱ្យការបង្ក្រាបអំពើជួញដូរមនុស្ស និងការផ្តន្ទាទោសជនល្មើសទទួលបានលទ្ធផលល្អគួរជាទីពេញចិត្ត ទាំងបរិមាណ ទាំងគុណភាព ។

ជាទូទៅជោគជ័យនេះ គឺអាស្រ័យដោយមានការផ្លាស់ប្តូរប្រែប្រួលយ៉ាងសំខាន់ផ្នែកសមត្ថកិច្ច ឥរិយាបថ និងការប្តេជ្ញាចិត្តរបស់មន្ត្រីអនុវត្តន៍ច្បាប់ នៅក្នុងនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង និងក្នុងប្រព័ន្ធតុលាការក្នុងរឿងក្តីជួញដូរមនុស្ស ដោយឈរលើមូលដ្ឋាននៃការស៊ើបអង្កេតពីករណីមួយទៅករណីមួយដោយផ្តោតទៅលើទំហំករណី និងបណ្តាញនៃប្រព័ន្ធជួញដូរមនុស្ស ។

ក្នុងឆ្នាំ២០១៦ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយមានកិច្ចសហការជាមួយព្រះរាជអាជ្ញាតាមបណ្តារាជធានី-ខេត្ត សកម្មភាពបង្ក្រាបបានអនុវត្តចំនួន**៩២ករណី** (លើ**១០៥ករណី**បើធៀបនឹងឆ្នាំ២០១៥ ថយចុះ**១៣ករណី**)។ ឃាត់ខ្លួនជនសង្ស័យ និងបញ្ជូនទៅតុលាការបានចំនួន**១១៣/១៤៤**នាក់ (ថយចុះចំនួន**៣១**នាក់) ស្រី**៤៦**នាក់ អនីតិជន**១២**នាក់ ត្រូវបានចាប់ខ្លួន ។ ក្នុងចំនួនជនសង្ស័យដែលជាជនបរទេសចំនួន**០៨**នាក់ មាន**០៧**សញ្ជាតិ៖ អូស្ត្រាលី**០១**នាក់ ឥណ្ឌា**០១**នាក់ ប៉ាគីស្ថាន**០១**នាក់ វៀតណាម**០១**នាក់ ថៃ**០១**នាក់ កូរ៉េ**០១**នាក់ និងហូឡង់**០២**នាក់។

ដោយឡែកជនរងគ្រោះ ដែលសង្គ្រោះបានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបចំនួន**២៩៨/២៩៥នាក់** (កើន**៣**នាក់) ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំចំនួន**៤៧**នាក់ អាយុពី១៥-១ឆ្នាំចំនួន**៤៤**នាក់ អាយុ១៨ឡើងចំនួន**២០៧**នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន**១៦១**នាក់ និងអង្គការដៃគូ ចំនួន**០៧**នាក់ និងគ្រួសារចំនួន**១៣០**នាក់។

### ១. ករណីអំពើជួញដូរមនុស្ស៖

បង្ក្រាបបាន**២៧/៤៧ករណី (ថយចុះ២០ករណី)** ឃាត់ខ្លួនជនសង្ស័យចំនួន**៣៩**នាក់ (ស្រីចំនួន**២១**នាក់) ក្នុងនោះជនបរទេសចំនួន០៣នាក់ សង្គ្រោះជនរងគ្រោះបានចំនួន**១១១**នាក់ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| បទល្មើស | ករណី | ជនសង្ស័យ | បរទេស |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៦ | ៦ | |
| -ការនាំយកចេញមិនស្របច្បាប់ដោយមានគោលដៅ | ១០ | ១៧ | ប៉ាគីស្ថាន១ និងថៃ១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ៧ | ១១ | |
| -អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន | ២ | ២ | |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ១ | ២ | |
| -ការទិញពេស្យាចារកុមារ | ១ | ១ | កូរ៉េ |
| *សរុប* | *២៧ករណី* | *៣៩ នាក់* | *៣ នាក់* |

***បញ្ជីជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលសង្គ្រោះបានក្នុងពេលប្រតិបត្តិការបង្ក្រាប៖***

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ | អាយុ១៨ឆ្នាំឡើង | ការបញ្ជូនជនរងគ្រោះ | |
|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅគ្រួសារ |
| *១១១ នាក់* | *៧ នាក់* | *២៣ នាក់* | *៨១ នាក់* | *៧៤ នាក់* | *៣៧ នាក់* |

**២. អំពើធ្វើអាជីវកម្មផ្លូវភេទ៖** បង្ក្រាបបាន**៦៥/៥៨ករណី (កើន៧ករណី)** ឃាត់ខ្លួនជនសង្ស័យចំនួន**៦៦**នាក់ ស្រី**២៥**នាក់ (អនីតិជន០៩នាក់) ក្នុងនោះជនបរទេស**០៥**នាក់ សញ្ជាតិ៖ (អូស្ត្រាលី**០១**នាក់, វៀតណាម**០១**នាក់, ឥណ្ឌា**០១**នាក់ និងហូឡង់**០២**នាក់) សង្គ្រោះជនរងគ្រោះបានចំនួន**១៨៧**នាក់ ។ ដូចមានតារាងលម្អិតខាងក្រោម៖

***តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ***

| **បទល្មើស** | **ករណី** | **ជនសង្ស័យ** | **បរទេស** |
|---|---|---|---|
| -សញ្ចារកម្ម | ៧ | ១០ | អូស្ត្រាលី១ |
| -សញ្ចារកម្ម (មានអនីតិជន) | ៤ | ៥ | |
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ៦ | ៩ | វៀតណាម១ |
| -សញ្ចារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ) | ៧ | ៨ | |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ៣ | ៤ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ១ | ១ | ហូឡង់១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ១ | ១ | ហូឡង់១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ២៥ | ២៥ (អនីតិជន១០នាក់) | ឥណ្ឌា១ |
| -អំពើអាសប្រឋាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១ (អនីតិជន២នាក់) | |
| *សរុប* | *៦៥ ករណី* | *៧៤ នាក់* | *៥ នាក់* |

***បញ្ជីជនរងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលសង្គ្រោះបានក្នុងពេលប្រតិបត្តិការបង្ក្រាប៖***

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ | អាយុ១៨ឆ្នាំឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| *១៨៧ នាក់* | *៤០ នាក់* | *២១ នាក់* | *១២៦នាក់* | *១២៨ នាក់* | *០៧ នាក់* | *៥២ នាក់* |

**៣.ករណីប្រព្រឹត្តអំពើអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ(យោងតាមរបាយការណ៍របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ)៖**

បង្ក្រាបបាន**០១ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន០៣នាក់ ស្រី០១នាក់ (អូស្ត្រាលី០១នាក់) ក្នុងនោះសង្គ្រោះជនរងគ្រោះបានចំនួន**១២**នាក់ ។ ដូចមានតារាងលម្អិតខាងក្រោម៖

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| បទប្រព្រឹត្តអំពើអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ | ១ | ១២ | ៣ (អ្នស្រ្តាលី១) |
| *សរុប* | *១ករណី* | *១២នាក់* | *៣នាក់* |

## គ.១.២ ការកសាងសំណុំរឿង បណ្តឹងជនសង្ស័យរងគ្រោះ បញ្ជូនទៅតុលាការ

| ល.រ | អំពើ | មាត្រា | ចំនួនករណី | | ចំនួនជនល្មើស | | ចំនួនជនរងគ្រោះ | |
|---|---|---|---|---|---|---|---|---|
| | | | ជួញដូរមនុស្ស | ជួញដូរភេទ | ជួញដូរមនុស្ស | ជួញដូរភេទ | ជួញដូរមនុស្ស | ជួញដូរភេទ |
| ១ | ការនាំយកអនីតិជន ជាអាទីចេញដោយមិនស្របច្បាប់ | ៩* | ៦ | | ២៩ | | ៦ | |
| ២ | ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១០* | ១០ | | ២២ | | ១៧ | |
| ៣ | ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១* | ៧ | | ៣៤ | | ១១ | |
| ៤ | ការជ្រើសរើសដោយមិនស្របច្បាប់ដោយមានគោលដៅ | ១២* | ០ | | ០ | | ០ | |
| ៥ | អំពើលក់ដូរមនុស្សដោយមានគោលដៅ | ១៥* | ០ | | ០ | | ០ | |
| ៦ | អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១៦* | ២ | | ៦ | | ២ | |
| ៧ | ការដឹកជញ្ជូនដោយមានគោលដៅ | ១៧* | ១ | | ១២ | | ២ | |
| ៨ | សញ្ជារកម្ម | ២៦* | | ៧ | | ២៤ | | ១០ |
| ៩ | សញ្ជារកម្ម (មានអនីតិជន) | ២៦* | | ៤ | | ៣៦ | | ៥ |
| ១០ | ស្ពានទម្ងន់ទោសនៃសញ្ជារកម្ម | ២៧* | | ៦ | | ២៨ | | ៩ |
| ១១ | សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ២៨* | | ៧ | | ៤២ | | ៨ |
| ១២ | ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ៣២* | | ៣ | | ១៧ | | ៤ |
| ១៣ | បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ៣៣* | | ០ | | ០ | | ០ |
| ១៤ | ការទិញពេស្យាចារកុមារ | ៣៤* | ១ | | ៨ | | ១ | |
| ១៥ | អំពើអូសទាញពេស្យាចារកុមារ | ៣៥* | ០ | | ០ | | ០ | |
| ១៦ | ការឲ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌ ទាក់ទងទៅនឹងអំពើពេស្យាចារកុមារ | ៣៦* | ០ | | ០ | | ០ | |
| ១៧ | រូបភាព និងសម្ភារៈអាសអាភាស | ៣៩* | | ១ | | ១ | | ១ |
| ១៨ | រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ៤១* | | ១ | | ១ | | ១ |
| ១៩ | អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤១* | | ២៥ | | ២៥ | | ២៥ |
| ២០ | អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤១* | | ១១ | | ១៣ | | ១១ |
| ២១ | កិច្ចសន្យាសម្រាប់អំពើលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | ៤៥* | ០ | | ០ | | ០ | |
| | សរុប | ២១ | ២៧ | ៦៥ | ៣៩ | ៧៤ | ១១១ | ១៨៧ |
| | សរុបរួម | ២១ | ៩២ ករណី | | ១១៣ នាក់ | | ២៩៨ នាក់ | |

តារាងប្រៀបធៀបការបង្ក្រាបបទល្មើសជួញដូរមនុស្ស របស់ក្រុមការងារអនុវត្តច្បាប់

| ល.រ | ឆ្នាំអនុវត្ត | ករណី | សម្គាល់ | ជនសង្ស័យ | សម្គាល់ | ជនរងគ្រោះ | សម្គាល់ |
|---|---|---|---|---|---|---|---|
| ១ | ឆ្នាំ២០១៤ | ៩៥ | ថយ០៤ករណី | ១២៧ | កើន០២នាក់ | ៤១២ | ថយ៨១នាក់ |
| ២ | ឆ្នាំ២០១៥ | ១០៥ | កើន១០ករណី | ១៤៤ | កើន១៧នាក់ | ២៩៥ | ថយ១១៧នាក់ |
| ៣ | ឆ្នាំ២០១៦ | ៩២ | ថយ១៣ករណី | ១១៣ | ថយ៣១នាក់ | ២៩៨ | កើន០៣នាក់ |




### គ.១.៣ ដំណោះស្រាយផ្លូវច្បាប់សម្រាប់ជនរងគ្រោះនៅក្រៅប្រទេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងឆ្នាំ២០១៦នេះ បានដោះស្រាយវិវាទផ្នែកទេសន្តរប្រវេសន៍ចំនួន**២៨**ក្រុមហ៊ុន មាន**៥៤**សំណុំរឿង ក្នុងនោះមានពលករសរុបចំនួន**១៨៧**នាក់ (ស្រី**១២៩**នាក់) ។ បណ្តឹងសះជាចំនួន**១៩**ករណី បណ្តឹងមិនសះជាចំនួន**០**ករណី បណ្តឹងកំពុងដោះស្រាយបន្តមានចំនួន**២១**ករណី និងបណ្តឹងទុកជាមោឃៈមានចំនួន**១៣**ករណី ។

## គ.២ កិច្ចការយុត្តិធម៌

### គ.២.១ លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោស តុលាការរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ។ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

### គ.២.២ ចំណាត់ការរបស់អយ្យការរាជធានី-ខេត្ត

ចំណាត់ការរបស់អយ្យការរាជធានី-ខេត្តរយៈពេល៩ខែ និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ១ឆ្នាំ សរុបមានចំនួន១១៦ករណី ជនរងគ្រោះចំនួន៨៧នាក់ (អនីតិជន ៥៩នាក់) ជនត្រូវចោទមានចំនួន១១៤នាក់ មានអនីតិជន១៧នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន៦៦ករណី, តម្កល់ទុកឥតចាត់ការចំនួន០៩ករណី ជម្រះផ្ទាល់០១ករណី និងកំពុងចាត់ការចំនួន៤០ករណី ដូចមានរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការរាជធានី/ខេត្ត៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | ជម្រះផ្ទាល់ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | |
| ១១៦ | ០៤ | ២៤ | ០២ | ៥៧ | ៩០ | ០៧ | ១៧ | ០ | ៦៦ | ០៩ | ០១ | ៤០ |
| *សរុប* | *២៨* | | *៥៩* | | *៩៧* | | *១៧* | | *១១៦* | | | |

## គ.២.៣ ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្តរយៈពេល៩ខែ និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ១ឆ្នាំ សរុបមានចំនួន៨៤ករណី ជនរងគ្រោះ៩៧នាក់ (អនីតិជន៥០នាក់) ជនត្រូវចោទមានចំនួន១១៣នាក់ (អនីតិជន២២នាក់) នៅក្នុងឃុំចំនួន៤២នាក់ ក្រៅឃុំ៣៨នាក់ និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន១៤ករណី, លើកលែងចោទចំនួន០២ករណី និងកំពុងចាត់ការចំនួន៦៨ករណី ដូចមានរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរ៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | ឃុំខ្លួន | | នៅក្រៅឃុំ | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីជន | | នីតិជន | | អនីជន | | នីតិជន | | អនីជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| ៨៤ | ២៣ | ២៤ | ១០ | ៤០ | ៦១ | ៣០ | ១៥ | ០៧ | | | | | ១៤ | ០២ | ៦៨ |
| សរុប | ៤៧ | | ៥០ | | ៩១ | | ២២ | | ៤២ | | ៣៨ | | ៨៤ | | |

## គ.២.៤ ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ រាជធានី-ខេត្តរយៈពេល៩ខែ និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ១ឆ្នាំ សរុបមានចំនួន១៣៨ករណី ជនរងគ្រោះចំនួន១៥០នាក់ (អនីតិជន៧៧នាក់) ជនជាប់ចោទសរុប១៥៥នាក់ (អនីតិជន០១នាក់) នៅក្នុងឃុំ១០៣នាក់ នៅក្រៅឃុំ៤៨នាក់ ចាត់ការរួចចំនួន១៦ករណី និងកំពុងចាត់ការចំនួន១២២ករណី ដូចមានរាយលម្អិតខាងក្រោម៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះ៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | | ប្រភេទចំណាត់ការ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | | | កំពុងចាត់ការ |
| | | | | | | | | | | | | | | ក្នុងឃុំ | | ក្រៅឃុំ | | |
| ១៣៨ | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | ១២២ |
| | ០៩ | ៦៤ | ០៥ | ៧២ | ១១៣ | ៤១ | ០១ | ០ | ០១ | | | | ១៦ | ៧៤ | ២៩ | ៣៨ | ១០ | |
| សរុប | ៧៣ | | ៧៧ | | ១៥៤ | | ០១ | | ០១ | | | | ១៦ | ១០៣ | | ៤៨ | | |

## គ.២.៥ សម្របសម្រួលការអនុវត្តប្រព័ន្ធយុត្តិធម៌

ក្រាហ្វិកប្រៀបធៀបការផ្តន្ទាទោស ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦




## ឃ.កិច្ចការពារជនរងគ្រោះ ព្រមទាំងសេវាគាំទ្រ

### ឃ.១ ការទទួលជនសង្ស័យរងគ្រោះ

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយបានធ្វើការស្តារនីតិសម្បទាជនរងគ្រោះទៅតាមអង្គការនានា ដើម្បីទទួលការពិនិត្យសុខភាព, ផ្តល់ប្រឹក្សាសម្រាប់ជម្រើស ឬការដោះស្រាយផ្លូវច្បាប់, ផ្តល់ជំនួយសង្គ្រោះបន្ទាន់, ផ្តល់ការស្នាក់នៅ និងអាហារ, ផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបំណិនជីវិត ទើបប្រគល់ឲ្យគ្រួសារវិញ សរុបបានចំនួន**១,៣៦២**នាក់ ស្ត្រីមានចំនួន**៤៦៩**នាក់ (កុមារាចំនួន**៧៥៩**នាក់ កុមារីចំនួន**៥៣០**នាក់) ដូចរាយលម្អិតខាងក្រោម ៖

***តារាងជួយសង្គ្រោះ ផ្តល់សេវា និងស្តារនីតិសម្បទាជនរងគ្រោះ***

| ល.រ | មន្ទីរ និងអង្គការពាក់ព័ន្ធ | ជនរងគ្រោះ | ចំនួនរួម | ស្រី | កុមារ | កុមារី |
|---|---|---|---|---|---|---|
| ១ | មន្ទីរ ស.អ.យ រាជធានីភ្នំពេញ និងអង្គការដៃគូពាក់ព័ន្ធ | -អំពើជួញដូរមនុស្ស | ១៦២ | ១០៤ | ៥៧ | ៥៦ |
| ២ | មន្ទីរ ស.អ.យ សៀមរាប និងអង្គការដៃគូពាក់ព័ន្ធ | -សញ្ញារកម្ម | ៧ | ៧ | ០ | ០ |
| | | -ពេស្យាចារកុមារ | ២ | ២ | ០ | ០ |
| | | -ពេស្យាចារកម្ម | ៨ | ៨ | ០ | ០ |
| | | -អំពើជួញដូរមនុស្ស | ៧ | ៧ | ០ | ០ |
| ៣ | មន្ទីរ ស.អ.យ ស្វាយរៀង និងអង្គការដៃគូពាក់ព័ន្ធ | -អំពើជួញដូរមនុស្ស | ១៥៣ | ២០ | ១០៧ | ៦៣ |
| ៤ | អង្គការអេណាសេរ | -ការរំលោភបំពានផ្លូវភេទ | ២ | ២ | ០ | ០ |
| ៥ | អង្គការក្តីសង្ឃឹម និងយុត្តិធម៌ | -ការរំលោភបំពានផ្លូវភេទ និងកម្លាំងពលកម្ម | ៣១ | ៣១ | ០ | ០ |
| ៦ | អង្គការពន្លកថ្មី | -អំពើរំលោភបំពានផ្លូវភេទ -អំពើអាស | ០៤ | ០ | ០ | ០ |
| ៧ | អង្គការបេសកកម្មទូទាំងពិភពលោក | -អំពើរំលោភបំពានផ្លូវភេទ | ៣ | ៣ | ០ | ០ |

| | | | | | | |
|---|---|---|---|---|---|---|
| | | -អំពើអាស | | | | |
| ៦ | អង្គការបញ្ឈប់ការជួញដូរកុមារ Cambodia ACTs | -ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលម្ម | ៩១១ | ២៦១ | ៥៧៨ | ៣៩៧ |
| ៧ | មណ្ឌលសំចតប៉ោយប៉ែត | -អំពើជួញដូរមនុស្ស | ៦៤ | ២៤ | ១៤ | ៩ |
| | | -កេងប្រវ័ញ្ចកម្លាំងពលកម្ម | ៦ | ០ | ៣ | ៣ |
| | | -ជួញដូរកម្លាំងពលកម្ម | ២ | ០ | ០ | ២ |
| *សរុបចំនួនរួម* | | | *១,៣៦២* | *៤៦៩* | *៧៥៩* | *៥៣០* |

## ឃ.២ កិច្ចការពារកុមារ

គណៈកម្មាធិការជាតិ គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត បានសហការជាមួយមណ្ឌលរដ្ឋ និងមណ្ឌលអង្គការនានាជាដៃគូ ក្នុងឆ្នាំ២០១៦នេះ បានជួយសង្គ្រោះកុមារករណីជួញដូរមនុស្ស, ជួញដូរផ្លូវភេទ, កេងប្រវ័ញ្ចកម្លាំងពលកម្ម និងបានផ្តល់សេវាស្នាក់នៅបណ្តោះអាសន្ន ក្នុងការគ្រប់គ្រង ថែទាំកុមារ ហើយធ្វើសមាហរណកម្មទៅគ្រួសារវិញ សរុបចំនួន**៦៥២**នាក់ (កុមារីចំនួន**៤៤៨**នាក់) ដោយឡែក តាមបណ្តាមណ្ឌលថែទាំជនរងគ្រោះនានា បានទទួល និងថែទាំជនរងគ្រោះ មានដូចតារាងខាងក្រោម៖

*តារាងកុមាររងគ្រោះដែលទទួលការថែទាំតាមមណ្ឌលក្នុងឆ្នាំ២០១៦*

| ល.រ | រាជធានី-ខេត្ត | មណ្ឌលរដ្ឋ/អង្គការទទួលការថែទាំកុមាររងគ្រោះ | កុមារសរុប | កុមារី |
|---|---|---|---|---|
| ១ | មណ្ឌលសំចត ប៉ោយប៉ែត | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិCWCC | ០៦ នាក់ | ០០ នាក់ |
| | | អង្គការតំណក់ទឹក | ០១ នាក់ | ០០ នាក់ |
| | | អង្គការគ្រួសារថ្មី | ០២ នាក់ | ០០ នាក់ |
| | | អង្គការកុមារក្នុងគ្រួសារ | ០១ នាក់ | ០១ នាក់ |
| | | អង្គការ IOM | ០៩ នាក់ | ០៩ នាក់ |
| ២ | ភ្នំពេញ | អង្គការបញ្ឈប់ការជួញដូរកុមារ Cambodia ACTs | ៨៦ នាក់ | ៧៦ នាក់ |
| ៣ | បន្ទាយមានជ័យ | អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិCWCC | ១៨ នាក់ | ១២ នាក់ |
| | | អង្គការHagar | ០១ នាក់ | ០០ នាក់ |
| | | អង្គការបេសកកម្ម ក្តីជំនឿអាស៊ីភ្នំពេញ (FMA) | ០២ នាក់ | ០២ នាក់ |
| | | អង្គការបញ្ឈប់ការជួញដូរកុមារ Cambodia ACTs | ២២៩ នាក់ | ១៧៨ នាក់ |
| | | អង្គការដៃគូ | ០៤ នាក់ | ០២ នាក់ |
| ៤ | កណ្តាល | អង្គការមេត្រីអន្តរជាតិដើម្បីអាស៊ី | ០៨ នាក់ | ០៨ នាក់ |
| | | អង្គការការលែបកម្ពុជា | ០២ នាក់ | ០២ នាក់ |
| | | អង្គការមេត្រីអន្តរជាតិដើម្បីអាស៊ីភ្នំពេញ | ០៧ នាក់ | ០៧ នាក់ |
| ៥ | ស្វាយរៀង | អង្គការនានានៅខេត្តស្វាយរៀង | ១១ នាក់ | ០៦ នាក់ |
| | | អង្គការបញ្ឈប់ការជួញដូរកុមារ Cambodia ACTs | ១៩៧ នាក់ | ១១២ នាក់ |
| ៦ | បាត់ដំបង | អង្គការ HAGAR | ០២ នាក់ | ០២ នាក់ |
| ៧ | ពោធិ៍សាត់ | អង្គការបញ្ឈប់ការជួញដូរកុមារ Cambodia ACTs | ៦៦ នាក់ | ៣១ នាក់ |
| *សរុបកុមារដែលគេរកឃើញថាត្រូវគេជួញដូរ និងទទួលការថែទាំនៅមណ្ឌលអង្គការ* | | | *៦៥២ នាក់* | *៤៤៨ នាក់* |

## ឃ.៣ ការគ្រប់គ្រងជនរងគ្រោះនៅក្នុងមណ្ឌល

**•ខេត្តព្រះសីហនុ**

ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាងបានដាក់បណ្ដាញ ម៉ូតូឌុប និងក្រុមម៉ូតូ កង់បី**១២០**នាក់ ផ្ទះសំណាក់សណ្ឋាគារ២៤កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ**៥៩**នាក់ បណ្ដាញសហគមន៍៥៧នាក់ ផ្នែកភ្នាក់ងារទេសចរណ៍**០២**នាក់ ។

**•ខេត្តកណ្ដាល**

មន្ទីរសង្គមកិច្ចបានចាត់មន្ត្រីបង្គោលថែទាំជំនួសចំពោះកុមារពិនិត្យការអនុវត្តបទដ្ឋានអប្បបរមា ស្ដីពីការថែទាំជំនួសចំពោះកុមារនៅមណ្ឌលកុមារកំព្រាចំនួន៩ នៅមណ្ឌលកុមារកំព្រាបឹងខ្យាង មណ្ឌលផ្ទះក្លារ៉ា មណ្ឌលបុរីកុមារមិត្តភាពកម្ពុជា បារាំង ហុងគ្រី មណ្ឌលកុមារកំព្រាទឹកដីសប្បាយ មណ្ឌលអង្គការការហ្វើសធាល អន្តរជាតិ មណ្ឌលសន្តិភាពស្រែអំពិល មណ្ឌលកុមារកំព្រាភូមិកុមារអេរុណរះ មណ្ឌលកុមារអេម៉ាញូអែល មណ្ឌលកុមារកំព្រាដំណឹងល្អ និងមណ្ឌលអង្គការជីបូឌាហោព (Chiloodia hope) មានកុមារកំព្រាចំនួន**៥៨០**នាក់ ស្រី**២៥៥**នាក់ ។

**•ខេត្តរតនៈគីរី**

មន្ទីរសង្គមកិច្ចខេត្ត បានចុះពិនិត្យការអនុវត្តបទដ្ឋានអប្បរមា ស្ដីពីការថែទាំជំនួស ចំពោះកុមារក្នុងមណ្ឌលកុមារកំព្រា មានកុមារចំនួន**១៥២**នាក់ ស្រី**៦៣**នាក់ ។

**•ខេត្តពោធិ៍សាត់**

មណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ២ និងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ១ សម្រាប់ទទួលជនរងគ្រោះ ជនងាយរងគ្រោះ និងប្រជាពលរដ្ឋទូទៅឲ្យចូលរៀនវិជ្ជាជីវៈ ។

មណ្ឌលកុមារកំព្រាមាន៦ ក្នុងនោះរដ្ឋ១មណ្ឌល អង្គការមាន៥មណ្ឌល និងមណ្ឌលអង្គការកុមារកំព្រានៅក្នុងសហគមន៍មាន៩មណ្ឌល៖

- កុមារនៅមណ្ឌលរដ្ឋមានចំនួន**៤០**នាក់ (ស្រី**២០**នាក់)
- កុមារនៅមណ្ឌលអង្គការមានចំនួន**២៤២**នាក់ (ស្រី**១១៣**នាក់)
- កុមារនៅមណ្ឌលអង្គការក្នុងសហគមន៍មានចំនួន**៧៨**នាក់ (ស្រី**៤១**នាក់)។

## ឃ.៤ សេវាជួយជនរងគ្រោះដែលបានផ្ដល់

មជ្ឈមណ្ឌលសំចតបានសហការជាមួយអង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ(CWCC) ផ្ដល់សម្លៀកបំពាក់សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃដល់ជនរងគ្រោះ និងងាយរងគ្រោះចំនួន**៩៧**នាក់ ក្នុងម្នាក់ៗទទួលបាន (ខោ២ អាវយឺត២ កន្សែងពោះគោ១ ខោលីអូ២ ស្បែកជើងផ្ទាត់១គូ សាប៊ូកក់សក់១ដប ថ្នាំដុសធ្មេញ១ដប ច្រាសដុសធ្មេញ១ដើម សាប៊ូលុច១ដុំ សាប៊ូម្សៅ១កញ្ចប់ និងស្បោងដាក់សម្ភារៈ១) ។

## ឃ.៥ សមាហរណកម្មជនរងគ្រោះ

មន្ទីរ ស.អ.យ រាជធានី-ខេត្ត បានសហការជាមួយអង្គការដៃគូមិនមែនរដ្ឋាភិបាលធ្វើសមាហរណកម្មជនរងគ្រោះវិលត្រឡប់ទៅសហគមន៍វិញចំនួន**៥៨**នាក់ (ស្រី**៥៤**នាក់ កុមារី**៤**នាក់) ក្នុងនោះមានខេត្តសៀមរាប**១៨**នាក់ ខេត្តកណ្ដាល**១៦**នាក់ និងអង្គការសង្គ្រោះជោគវាសនានៅកម្ពុជា**២៤**នាក់ ។

រាជធានីភ្នំពេញបានទទួលជនអនាថាមិនស្ម័គ្រចិត្ត សរុបចំនួន**១,៩០៤**នាក់ (ស្រី**៨៦៦**នាក់) បានធ្វើការពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះទៅមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ ដើម្បីអប់រំណែនាំបណ្តុះបណ្តាលរយៈពេលខ្លី និងសមាហរណកម្ម ទៅសហគមន៍វិញចំនួន**១,៦០៣**នាក់ (ស្រី**៧១០**នាក់) ។

## III. ការលើកកម្ពស់សមត្ថភាព

### ក.ក្នុងប្រទេស

### ក.១ បណ្តុះបណ្តាល

ក្នុងឆ្នាំ២០១៦នេះ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ក្រសួងកិច្ចការនារី ក្រសួងទេសចរណ៍ និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានរួមសហការជាមួយអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាព គ្រូបង្គោល មន្រ្តីអនុវត្តច្បាប់ សមាជិក គ.រ.ប.ជ និងមន្ត្រីលេខាធិការដ្ឋានគ.រ/ខ.ប.ជ បាន២៩វគ្គ និងមានសិក្ខាកាមចូលរួម ១.១២៦នាក់ (ស្រី ៤៩៧នាក់) ស្តីពីជំនាញពាក់ព័ន្ធនឹងច្បាប់ និងការបង្ក្រាបអំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ។

លើសពីនេះទៅទៀត អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក៏ដូចជាលេខាធិការដ្ឋានរាជធានី-ខេត្តចំនួន ១៣(គឺខេត្ត កំពត បាត់ដំបង កំពង់ស្ពឺ ស្វាយរៀង កណ្តាល កំពង់ឆ្នាំង កំពង់ចាម ក្រចេះ ព្រះសីហនុ ព្រៃវែង រតនគីរី ពោធិសាត់ និងតាកែវ) បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងដៃគូ បណ្តុះបណ្តាលដល់សិក្ខាកាមជាមួយក្រុមប្រឹក្សាឃុំ មន្ត្រីថ្នាក់មូលដ្ឋាន មន្ត្រីលេខាធិការដ្ឋានខេត្ត ជនបង្គោល គ្រូបង្គោលណែនាំតម្រង់ទិសមុនចេញដំណើរ មន្ត្រីអនុវត្តន៍ច្បាប់ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអង្គការ និងប្រតិបត្តិករទេសចរណ៍ នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ បាន៧៥វគ្គ មានសិក្ខាកាមចូលរួមចំនួន ៣.៦៣៥នាក់ ក្នុងនោះ មានស្ត្រី ១.៧៨៦នាក់ ។

**សរុបវគ្គបណ្តុះបណ្តាលក្នុងឆ្នាំ២០១៦ មានចំនួន១០៤វគ្គ សរុបសិក្ខាកាមចូលរួមចំនួន៤,៧៦១នាក់ ស្រី២,២៨៣នាក់ ។ (ឧបសម្ព័ន្ធ១)**

### ក.២ សិក្ខាសាលា

ក្នុងឆ្នាំ២០១៦ មានសិក្ខាសាលាសំខាន់ៗ ដែលដឹកនាំដោយ**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (**គ.ជ.ប.ជ**)គឺ៖

(១) សិក្ខាសាលាស្តីពី« ***ការគ្រប់គ្រងលំហូរមិនប្រក្រតីនៃពលករទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន*** » នៅសាលាខេត្តបន្ទាយមានជ័យ ដែលប្រមូលផ្តុំសមាសភាពសំខាន់ៗ ក្នុងនោះ មាន ថ្នាក់ដឹកនាំក្រសួងជាសមាជិកគណៈកម្មាធិការជាតិ គ.ជ.ប.ជ ថ្នាក់ដឹកនាំខេត្តជាប់ព្រំដែនចំនួន ៧ ថ្នាក់ដឹកនាំអង្គភាពឈរជើងតាមខ្សែបន្ទាត់ព្រំដែន ថ្នាក់ដឹកនាំស្រុក និងឃុំសង្កាត់ជាប់ព្រំដែន និងអង្គការដៃគូពាក់ព័ន្ធសរុបចំនួន ១៩៣នាក់(ស្រី២៣នាក់) ។ ខេត្តពាក់ព័ន្ធទាំង៧ គឺ ខេត្តបន្ទាយមានជ័យ,ខេត្តប៉ៃលិន, ខេត្តព្រះវិហារ,ខេត្តឧត្តរមានជ័យ,ខេត្តកោះកុង,ខេត្តបាត់ដំបង, ខេត្តពោធិ៍សាត់ និងថ្នាក់ដឹកនាំ រួមនឹងជំនាញពីថ្នាក់ជាតិ ។

(២) សិក្ខាសាលាពិគ្រោះយោបល់ស្ដីពី «***ការលើកកម្ពស់ការអនុវត្តច្បាប់ដើម្បីយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស***» នៅរាជធានីភ្នំពេញ ក្នុងនោះមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍, អគ្គនាយក នៃអគ្គនាយកដ្ឋានអយ្យការ, លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌, អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ, ចៅក្រម ព្រះរាជអាជ្ញារាជធានី/ខេត្ត មន្ត្រីជាន់ខ្ពស់ ពីក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធផ្នែកច្បាប់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ សរុបចំនួន**១៥៩**នាក់ ស្រី**៤៧**នាក់ ។

ក្រៅពីនេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក៏ដូចជាលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃបណ្តាខេត្ត (គ.ខ.ប.ជ) បានរៀបចំសិក្ខាសាលាផ្តោតលើប្រធានបទសំខាន់ៗ ដែលជាកិច្ចការអាទិភាពទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបបានចំនួន**៣៨**លើក មានអ្នកចូលរួមចំនួន**២,៨៦៩**នាក់ ស្រីចំនួន**១,០៩៨**នាក់ រួមមាន៖

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ៖សិក្ខាសាលា ស្តីពី«***ប្រព័ន្ធនៃការជ្រើសរើសពលករ ទៅធ្វើការនៅព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអ៊ូឌីត***» ។
- **ក្រសួងអប់រំ យុវជន និងកីឡា៖ ធ្វើសិក្ខាសាលា ចំនួន១១លើក** សរុបអ្នកចូលរួមចំនួន**១,៥៨២**នាក់ ស្រី**៦៣១**នាក់ក្នុងនោះ៖
  - សិក្ខាសាលាដោយក្រសួងអប់រំយុវជន និងកីឡាផ្ទាល់ ០៤លើក ក្នុង០៤ខេត្ត គឺខេត្តកំពត, ឧត្តរមានជ័យ, រតនគិរី និងខេត្តតាកែវ ស្តីពី«***ក្របខណ្ឌច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស***» ដែលមានសិក្ខាកាមចូលរួមជាបុគ្គលិកអប់រំចំនួន**៣២៦**នាក់ ស្រី**៥៧**នាក់ ។
  - សហការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ ធ្វើសិក្ខាសាលា បែបបណ្តុះបណ្តាល ស្តីពី«***ការពង្រឹងប្រសិទ្ធភាពការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលើកកម្ពស់បរិស្ថានល្អ អនាម័យ ស្អាតនៅតាមគ្រឹះស្ថានសិក្សា***» ដែលបានដំណើរការនៅមជ្ឈមណ្ឌលគរុកោសល្យ ចំនួន០៧ រាជធានី-ខេត្តគឺ ខេត្តតាកែវ, កណ្តាល, ព្រៃវែង, បាត់ដំបង, កំពង់ឆ្នាំង, កំពង់ចាម និងរាជធានីភ្នំពេញ ដែលមានសមាសភាពចូលរួមជាបុគ្គលិកអប់រំ និងគ្រូបង្រៀនចំនួន**៥០៦**នាក់ ស្រី**១៩២**នាក់ និងគរុសិស្ស**៧៥០**នាក់ ស្រី**៣៨២**នាក់ សិក្ខាកាមសរុបចូលរួមចំនួន**១,២៥៦**នាក់ ស្រី**៥៧៤**នាក់ ។
- **ក្រសួងទេសចរណ៍** បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលចំនួន**០៤**លើក ស្តីពី"***សុវត្ថិភាពកុមារក្នុង វិស័យទេសចរណ៍ ជូនផ្នែកឯកជននៃវិស័យទេសចរណ៍***" ចំនួន០៤ខេត្ត គឺខេត្តកំពត (៦២នាក់ ស្រី២៦នាក់) ខេត្តត្បូងឃ្មុំ (៥៧នាក់ ស្រី ២៤នាក់) ខេត្តកំពង់ចាម (៧១នាក់ ស្រី៣២នាក់) ខេត្តបន្ទាយមានជ័យ (៧៦នាក់ ស្រី៣៥នាក់) សរុប មានសិក្ខាកាមចូលរួមចំនួន**២៦៦**នាក់ ស្រី**១១៧**នាក់ ។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រៀបចំសិក្ខាសាលា ស្តីពី«***សកម្មភាពពាក់ព័ន្ធពលកម្មកុមារ***» សិក្ខាកាមចូលរួមចំនួន**២២**នាក់ ស្រី**១៦**នាក់ ។

- **ខេត្តស្វាយរៀង** បានរៀបចំសិក្ខាសាលា ស្តីពី« ***ការប្រយុទ្ធប្រឆាំងពលកម្មកុមារ***» នៅថ្នាក់ខេត្ត មានសិក្ខាកាមចូលរួមចំនួន**២១**នាក់ ស្រី**០៨**នាក់ ។
- **ខេត្តតាកែវ** សិក្ខាសាលាចំនួន**០៧**លើក សរុបចំនួន**៣៦៥**នាក់ ស្រីចំនួន**១៦០**នាក់៖
  - បានរៀបចំសិក្ខាសាលា ភូមិ/ឃុំមានសុវត្ថិភាព ស្តីពី« ***វិធានការទប់ស្កាត់ និងការពារប្រឆាំងអំពើជួញដូរមនុស្ស***» ចំនួន**០២**លើក មានអ្នកចូលរួមចំនួន**១០៥**នាក់ ស្រី**៤៧**នាក់ គាំទ្រដោយអង្គការ VCAO ។
  - រៀបចំសិក្ខាសាលាបណ្តាញភូមិឃុំសុវត្ថិភាព ចំនួន**០៥**លើក ស្តីពី« ***វិធានការទប់ស្កាត់ និងការពារប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព***» មានអ្នកចូលរួមចំនួន **២៦០**នាក់ ស្រី**១១៣**នាក់ គាំទ្រដោយអង្គការវ៉ាយស៊ីអេអូ ។
- **ខេត្តបាត់ដំបង សិក្ខាសាលា** ចំនួន**០៨**លើក សរុបចំនួន**៣៣២**នាក់ ស្រីចំនួន**១០៥**នាក់៖
  - សហការជាមួយអង្គការទស្សនៈពិភពលោក រៀបចំសិក្ខាសាលាថ្នាក់ខេត្ត ស្តីពី « ***ការឆ្លុះបញ្ចាំងលទ្ធផលអនុវត្តគម្រោង និងការរៀបចំផែនការបន្តដើម្បីចូលរួមទប់ស្កាត់និងលុបបំបាត់ពលកម្មកុមារ*** » មានអ្នកចូលរួមចំនួន**៤៨**នាក់។
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ ១៩០ របស់រាជរដ្ឋាភិបាល និងប្រកាសបំពេញបន្ថែមចំនួន០៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី« ***ការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន***» បានចំនួន**០៥**ស្រុក (ស្រុកសង្កែ, បាណន់, ថ្មគោល ឯកភ្នំ និងក្រុងបាត់ដំបង) អ្នកចូលរួមសរុប**២០១**នាក់ ស្រីចំនួន**៧៧**នាក់ និង ) ធ្វើនៅសាលាស្រុកមោងឬស្សីគឺបន្ថែមខ្លឹមសារពាក់ព័ន្ធនឹងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដោយមានអ្នកចូលរួមសរុបចំនួន**៤១**នាក់ ស្រី**១២**នាក់ ឧបត្ថម្ភដោយ អង្គការទស្សនៈពិភពលោក World Vision និងគម្រោងត្រីកោណរបស់អង្គការអន្តរជាតិខាងការងារ(ILO-Triangle) ។
  - សិក្ខាសាលា ស្តីពី« ***ផែនការសកម្មភាពជាតិ ស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ(២០១៦-២០១៧***)» ដែលមានអ្នក ចូលរួមសរុបចំនួន**៤២**នាក់ ស្រី**១៦**នាក់ ឧបត្ថម្ភដោយអង្គការទស្សនៈពិភពលោក ធ្វើនៅសណ្ឋាគារខេមរាបាត់ដំបង ។

## ក.៣. ការសម្របសម្រួលកិច្ចប្រជុំ

ការងារដឹកនាំសម្របសម្រួល ផ្ទៃក្នុងស្ថាប័ន អន្តរស្ថាប័ន និងជាមួយទីភ្នាក់ងារអន្តរជាតិ ឆ្នាំ២០១៦នេះ សរុបបានចំនួន**៥៧៦**លើក៖ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន **១៩៦**លើក ក្រសួងអប់រំ យុវជន និងកីឡាចំនួន**០៧**លើក, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន**៣៨**លើក, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន**០៣**លើក ក្រសួងកិច្ចការនារីចំនួន**៣០**លើក, ក្រសួងយុត្តិធម៌ចំនួន**១៣**លើក, នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន**០៣**លើក និងដោយលេខាធិការដ្ឋានរាជធានី/ខេត្ត ចំនួន**២៨៦**លើក ។ (ឧបសម្ព័ន្ធ២)

## ខ.ក្រៅប្រទេស

### ខ.១ ការចូលរួមកិច្ចប្រជុំ

**ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ គណៈកម្មាធិការជាតិ (គ.ជ.ប.ជ) ក៏ដូចជាក្រសួង ចំនួន ០៥ (ក្រសួងកិច្ចការនារី/COMMIT, ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំយុវជន និងកីឡា អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ) និង លេខាធិការដ្ឋានខេត្តចំនួន ០៦(ព្រះវិហារ ស្វាយរៀង ប៉ៃលិន កណ្តាល កំពង់ធំ ព្រះវិហារ) បានបញ្ជូនមន្ត្រីជំនាញពាក់ព័ន្ធទៅចូលរួមប្រជុំពិភាក្សាជាមួយ បណ្តាប្រទេសក្នុងតំបន់ ដើម្បីជម្រុញកិច្ចសហការ និងផ្លាស់ប្តូរ បទពិសោធន៍ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបកិច្ចប្រជុំមានចំនួន ៣៨លើក និងជួបប្រជុំជាមួយតំណាងប្រទេសមិនតិចជាង ៥០ ។**

#### តារាងកិច្ចសហប្រតិបត្តិការអន្តរជាតិ

| ក្រសួង/ស្ថាប័ន | សកម្មភាពកិច្ចសហប្រតិបត្តិការ |
|---|---|
| **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** | - ចាត់បញ្ជូនលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដឹកនាំមន្ត្រីជំនាញបីរូបទៀត ទៅចូលរួមកិច្ចប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (Bali Process Ministerial Conference on People Smuggling, Trafficking in Persons and Related Crimes) ដែលសហការរៀបចំដោយរដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី និងរដ្ឋមន្ត្រីការបរទេសអូស្ត្រាលី នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី មានប្រតិភូចូលរួមចំនួន **៣០០**នាក់ មកពី**៤៨**ប្រទេស។<br>- បញ្ជូនប្រធានក្រុមជំនួយបច្ចេកទេសកិច្ចសហប្រតិបត្តិការអន្តរជាតិ ចូលរួម**០៧**លើកៈ<br>o ចូលរួមកិច្ចប្រជុំលើកទី១២ ក្រុមការងារ (SOMTC) ទទួលបន្ទុកអំពើជួញដូរមនុស្សដែលបានប្រព្រឹត្តទៅនៅប្រទេសភីលីពីន។<br>o ចូលរួមកិច្ចប្រជុំគណៈកម្មាធិការនាយកនៃគម្រោងលើកទីពីរ កម្មវិធីទីIIស្តីពីការគ្រប់គ្រងទេសន្តរប្រវេសន៍ និងការគ្រប់គ្រងព្រំដែនរបស់សហគមន៍អឺរ៉ុប និងអាស៊ាន នៅទីក្រុងហ្សាការតា។<br>o ចូលរួមសន្និបាតអន្តរជាតិ ស្តីពីការលុបបំបាត់មនោគមវិជ្ជាជ្រុលនិយម និងការប្រយុទ្ធប្រឆាំងនឹងលទ្ធិជ្រុលនិយមប្រកបដោយហិង្សា នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។<br>o សន្និសីទអាស៊ាន ស្តីពីអំពើជួញដូរមនុស្ស និងពលកម្មបែបបង្ខិតបង្ខំ នៅក្នុងឧស្សាហកម្មនេសាទ ដែលប្រព្រឹត្តទៅនៅក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី មានសមាសភាពចូលរួម**៦០**នាក់ មកពីប្រទេសជាសមាជិកអាស៊ានមានៈ(កម្ពុជា, ភូមា, ឥណ្ឌូនេស៊ី, ថៃ, ប្រ៊ុយណេ, ហ្វីលីពីន, សឹង្ហបូរី និងវៀតណាម) អវត្តមានប្រទេសឡាវ។<br>o ចូលរួមប្រជុំឧត្តមមន្ត្រីអាស៊ានលើកទី១៦ (SOMTC) និងបណ្តាកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនទៀត នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ |
| **ក្រសួងកិច្ចការនារី** | - ចូលរួមកិច្ចប្រជុំទំនាក់ទំនងសង្គម ស្តីពីអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងផែនការសកម្មភាព (Socialization of ACTIP and APA) នៅទីក្រុង ម៉ានីល ប្រទេសហ្វីលីពីន។<br>- ក្រុមការងារ ខមមីតកម្ពុជា បានចូលរួមកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ (Regional COMMIT Taskrorce Meeting) និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលគម្រោង នៅទីក្រុងបាងកក ប្រទេសថៃ។ |

| | |
|---|---|
| | - មន្ត្រីជំនាញបានចូលរួមប្រជុំការងារខមមីតថ្នាក់តំបន់ និងបន្តកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១១ ដែលមានសមាសភាពចូលរួមចំនួន១១នាក់ នៅទីក្រុងវៀងចាន់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានីតុឡាវ ។ |
| **ក្រសួងការងារ និងបណ្តុះបណ្តាវិជ្ជាជីវៈ** | - ចាត់បញ្ជូនក្រុមការងារទៅធ្វើទស្សនកិច្ចសិក្សានៅសាធារណៈរដ្ឋលីបង់ បានសិក្សាស្វែយល់អំពីទីផ្សារការងារ បានរកឃើញអំពីភាពអំណោយផលល្អសម្រាប់ពលករកម្ពុជា ។<br>- រៀបចំកិច្ចប្រជុំតុមូលរវាងមន្ត្រីជាន់ខ្ពស់កម្ពុជា និងហ្វីលីពីន ដើម្បីចែករំលែកបទពិសោធន៍ទាក់ទងនឹងពលករទេសន្តរប្រវេសន៍ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋហ្វីលីពីន ស្តីពីការការពារពលករទេសន្តរប្រវេសន៍ នៃប្រទេសទាំងពីរនៅបរទេសដោយតំណាងក្រសួងការបរទេសនៃប្រទេសទាំងពីរ ។<br>- ពង្រឹងការអនុវត្ត អនុស្សរណៈនៃការយោគយល់គ្នារវាងកម្ពុជា និងប្រទេសទទួលពលករមួយ ចំនួនដូចជា ប្រទេសថៃ សាធារណៈរដ្ឋកូរ៉េ ប្រទេសជប៉ុន និងអារ៉ាប់ប៊ីសាអូឌីត ត្រូវបានពង្រឹងការ អនុវត្តបង្កើតប្រសិទ្ធភាពនៃការការពារ និងលើកកម្ពស់សិទ្ធិពលករជាបន្តបន្ទាប់។<br>- ប្រជុំក្រុមការងារបច្ចេកទេសកម្ពុជា-ថៃ ដើម្បីពិភាក្សាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការនៃវិស័យការងារ និងកិច្ចព្រមព្រៀង ស្តីពីការប្រើប្រាស់កម្លាំងពលកម្ម។<br>- ពិភាក្សា និងត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ជាមួយប្រទេសហ្វីលីពីន ។<br>- ប្រជុំជាមួយគណៈប្រតិភូរដ្ឋកាតានៅរាជធានីភ្នំពេញ ស្តីពីការពិនិត្យលើលក្ខខណ្ឌការងារមួយចំនួនទាក់ទងដល់ការគ្រប់គ្រង និងបញ្ជូនពលករកម្ពុជាទៅធ្វើការនៅរដ្ឋកាតា ។<br>- ពិភាក្សាជាមួយភាគីម៉ាឡេស៊ីពីរលើកដើម្បីពិនិត្យ និងរៀបចំនីតិវិធីប្រតិបត្តិការពិសេស (Special Operation of Procedure) សម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស បញ្ជូន និងការគ្រប់គ្រងពលករ ។<br>- ដឹកនាំគណៈប្រតិភូអន្តរជាតិក្រសួងទៅចូលរួមកិច្ចប្រជុំទ្វេភាគីលើកទី១រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ដើម្បីរៀបចំផែនការសកម្មភាពតំណាក់កាលទី១ ២០១៦-២០១៨សម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ នៅទីក្រុងបាងកក ប្រទេសថៃ ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - ចូលរួមកិច្ចប្រជុំទ្វេភាគី ស្តីពីការរៀបចំសេចក្តីព្រាងផែនការសកម្មភាព អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ។<br>- ចូលរួមកិច្ចប្រជុំពិភាក្សា កែសម្រួលខ្លឹមសារឯកសារណែនាំ ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។ |
| **ក្រសួងអប់រំ យុវជននិងកីឡា** | - ចូលរួមកិច្ចប្រជុំជាមួយប្រតិភូប្រទេសស្រីលង្កា ដឹកនាំដោយលោកជំទាវរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងសន្តិសុខសង្គម ស្តីពីទិសដៅទប់ស្កាត់អំពើជួញដូរមនុស្សនៅក្នុងតំបន់។ |

| | |
|---|---|
| | - ចូលរួមកិច្ចប្រជុំពិភាក្សាការងារ ស្តីពីបញ្ហាការជួញដូរមនុស្ស ប្រចាំឆ្នាំថ្នាក់តំបន់របស់ការងារស្តារទំនាក់ទំនងគ្រួសារ ជាលទ្ធផល កាកបាទក្រហមកម្ពុជា និងកាកបាទក្រហមថៃ បានសហការគ្នាលើការងារគ្រប់គ្រងទិន្នន័យជនចំណាកស្រុកកម្ពុជា-ថៃ មានការឧបត្ថម្ភជំនួយបច្ចេកទេស និងថវិកាដោយអង្គការ អាយ ស៊ី អរ ស៊ី។ |
| **អគ្គស្នងការរដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** | - ប្រជុំរវាងនគរបាលប្រទេសវៀតណាម និងនគរបាលកម្ពុជា ស្តីកិច្ចសហប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើស និងសន្តិសុខសណ្តាប់ធ្នាប់តាមព្រំដែន (ខេត្តស្វាយរៀង)។<br>- ប្រជុំស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅតំបន់អាស៊ីអាគ្នេយ៍ និងក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការស៊ើបអង្កេតលើករណីកេងប្រវ័ញ្ចផ្លូវភេទ ដូចជាការធ្វើពេស្យាកម្ម ការថតរូបភាពអាសអាភាស និងការជួញដូរមនុស្ស (នៅប្រទេសជប៉ុន)។<br>- ប្រជុំស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (នៅប្រទេសថៃ)។<br>- ប្រជុំស្តីពីការស្រាវជ្រាវថ្នាក់ជាតិអំពើហិង្សាលើកុមារ (នៅប្រទេសចិន)។<br>- ប្រជុំស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស និងការជួយសង្គ្រោះមនុស្សដោយអំពើជួញដូរ (នៅប្រទេសថៃ)។<br>- ប្រជុំស្តីពីការប្រយុទ្ធប្រឆាំងអន្តោប្រវេសន៍ខុសច្បាប់ បទល្មើសព្រហ្មទណ្ឌ ការក្លែងបន្លំតាមប្រព័ន្ធទូរគមនាគមន៍ និងបទល្មើសអំពើជួញដូរមនុស្ស (នៅប្រទេសចិន)។ |
| **ខេត្តព្រះវិហារ** | - ចូលរួមកិច្ចប្រជុំជាមួយប្រទេសថៃចំនួន**១១**លើក និងប្រទេសឡាវបានចំនួន**០៣**លើក ស្តីពីកិច្ចសហប្រតិបត្តិការការការពារសន្តិសុខនៅតាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដើម្បីស្វែងរកការងារធ្វើនៅក្រៅប្រទេស និងការពាក់ព័ន្ធអំពើជួញដូរមនុស្សការឆ្លងដែនខុសច្បាប់។ |
| **ខេត្តស្វាយរៀង** | - សហការជាមួយអង្គការសន្តិសេនាដឹកនាំប្រតិភូ ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន**១៥**នាក់ ស្រី**០៧**នាក់ ទៅខេត្តតៃនិញប្រទេសវៀតណាម ដើម្បីពិភាក្សាពីគ្រោះយោបល់លើការងារសំខាន់៖<br>o ការរៀបចំ និងបង្កើតការងារការពារ និងជួយកុមារឆ្លងដែន<br>o ពិភាក្សាលើភារកិច្ច និងទទួលការខុសត្រូវរបស់ក្រុមការងារនៃខេត្តនីមួយៗ<br>o ដំណើរការនៃកិច្ចប្រជុំរបស់ក្រុមការងាររវាងខេត្តទាំង៣។<br>- សហប្រតិបត្តិការជាមួយនគរបាលខេត្តឡុងអានប្រទេសវៀតណាម បានធ្វើការប្រជុំស្តីពីការបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងការពារសន្តិសុខសណ្តាប់ធ្នាប់ព្រំដែនរវាងកម្ពុជា-វៀតណាមលើកទី**១៣** មានអ្នកចូលរួមចំនួន**៤៣**នាក់ ស្រីចំនួន**០២**នាក់។ |
| **ខេត្តប៉ៃលិន** | - សហការជាមួយអាជ្ញាធរថៃជួយសម្រួលដល់ក្រុមហ៊ុន CATM ASIA MANPOWER COOPERATION CO.LTD & SOK-LEAP METREY CO.LTD ដែលបានបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសថៃចំនួន**២៣**លើក មានពលករ ចំនួន**៦៦៨**នាក់ ស្រីចំនួន**២៨៦**នាក់។ |
| **ខេត្តកណ្តាល** | - ប្រតិភូខេត្តចំនួន១៥នាក់ ដឹកនាំដោយលោកជំទាវ សួស សារ៉ាម អភិបាលរងខេត្ត និងជាប្រធានសមាគមនារី ទៅចូលរួមប្រជុំបូកសរុបកិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម ខេត្តអាងយាង ស្តីពី |

| | |
|---|---|
| | ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានវត្តមានចូលរួមខេត្តកណ្តាល ខេត្តតាកែវ និងសហព័ន្ធនារីវៀតណាម សរុបចំនួន៧០នាក់ ស្រី៥៨នាក់។ |
| **ខេត្តកំពង់ធំ** | - ជួបពិភាក្សាជាមួយអគ្គរដ្ឋទូតអាមេរិក ពិភាក្សាអំពីវិស័យសុខាភិបាល និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តមប្រធាន នៃគណៈអភិបាលខេត្ត នៅសាលាខេត្ត។ |
| **ខេត្តតាកែវ** | - ឯកឧត្តមប្រធាន នៃគណៈអភិបាលខេត្ត អញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបវាយតម្លៃលទ្ធផលការងារប្រចាំ ឆមាសទី១ ឆ្នាំ២០១៦ និងលើកទិសដៅប្រចាំឆមាសទី២ ឆ្នាំ២០១៦ រវាងខេត្តតាកែវ នៃព្រះរាជាណាចក្រកម្ពុជា និងខេត្តអានយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម អនុវត្តបានយ៉ាងល្អ តាមផែនការកិច្ចសហប្រតិបត្តិការ សហការទប់ស្កាត់រាល់បទល្មើសដូចជា ៖ ការរត់ពន្ធ ការជួញដូរ គ្រឿងញៀន អាវុធជាតិផ្ទុះ ការជួញដូរមនុស្ស និងការឆ្លងដែនខុសច្បាប់ជាដើម។<br>- ចូលរួមប្រជុំទ្វេភាគី ស្តីពីការធ្វើសមាហរណកម្មដោយការជួញដូរមនុស្សរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម នៅខេត្តព្រះសីហនុ។ |

## ខ.២. ការចូលរួមសិក្ខាសាលាអន្តរជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
  - បញ្ជូនមន្ត្រីជំនាញចូលរួមអង្គសិក្ខាសាលាអាស៊ាន ស្តីពីការកែលម្អការគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន និងការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ សំដៅចាត់វិធានការការដោះស្រាយទេសន្តប្រវេសន៍មិនប្រក្រតី (ខុសច្បាប់) នៅទីក្រុងម៉ានិល ប្រទេសហ្វីលីពីន និង
  - ចូលរួមអង្គសិក្ខាសាលាអាស៊ានបូក៣ ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មផ្នែកបច្ចេកវិទ្យា នៅប្រទេសសឹង្ហបូរី។
- **ក្រសួងកិច្ចការនារី**
  - បញ្ជូនមន្ត្រីជំនាញចំនួន២រូប ចូលរួមសិក្ខាសាលា ស្តីពីការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមរយៈការកសាងជីវិតថ្មី ៖ ការចែករំលែកបទពិសោធន៍ជាមួយប្រទេសក្នុងមហាអនុតំបន់មេគង្គនៅក្រុងបាងកក ប្រទេសថៃឡងដ៍ ក្រោមការឧបត្ថម្ភពីគម្រោងអង្គការ JICA ដែលមានការចូលរួមពីតំណាងប្រទេសនៃមហាអនុតំបន់មេគង្គទាំង៦ ប្រទេសជប៉ុន និងអ្នកជំនាញអង្គការ JICA មានចំនួនសរុប១០០នាក់ ស្រី៦៣នាក់ ។
  - ក្រុមការងារខមមីត កម្ពុជាចំនួន៣រូប និងអង្គការ២រូប (UN-ACT. CCPCR) បានចូលរួមសិក្ខាសាលា ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងយន្តការបញ្ជូន នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ ។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនមន្ត្រីចំនួន០៩រូប ចូលរួមសិក្ខាសាលាថ្នាក់តំបន់លើកទី៤ ដើម្បីពិភាក្សា និងជំរុញការអនុវត្តកម្មវិធី AAPIP ពាក់ព័ន្ធកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងបួន កម្ពុជា ថៃ មីយ៉ាន់ម៉ា និងឥណ្ឌូនេស៊ី (ប្រទេសមីយ៉ាន់ម៉ា)។

## ខ.៣ ការចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោក

ជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី«*ស្ត្រី និងភាពជាអ្នកដឹកនាំ*» នៅប្រទេសសឹង្ហបូរី។

- ក្រសួងកិច្ចការនារី មន្ត្រីជំនាញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី «*ការកសាងសមត្ថភាពមន្ត្រីជួយជនរងគ្រោះដោយអំពើហិង្សាលើស្ត្រី*» នៅប្រទេសកូរ៉េតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកូរ៉េ(KOICA) ។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន **បញ្ជូនមន្ត្រីចំនួន០៥រូប ចូលរួមវគ្គបណ្តុះបណ្តាលចំនួន០៣លើក៖**
  - ស្តីពី «*វគ្គបំប៉នជំនាញការងារដឹកនាំថ្នាក់ដឹកនាំនាយកដ្ឋាន ស្នងការដ្ឋាន និងការិយាល័យ*»(ប្រទេសវៀតណាម០២រូប។
  - ស្តីពី «*ភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីនៅក្នុងការអនុវត្តច្បាប់*» (ប្រទេសថៃ០២រូប)។
  - ស្តីពី«*ជំនាញស៊ើបអង្កេតសម្រាប់មន្ត្រីស៊ើបអង្កេតផ្នែករត់ពន្ធមនុស្ស*»(ប្រទេសឥណ្ឌូនេស៊ី០១រូប)

## IV. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើងតាមរយៈ៖

- របាយការណ៍ ខែ ត្រីមាស ឆមាស ១០ខែ និងឆ្នាំពីបណ្តាខេត្ត និងក្រុមការងារ
- ការចុះតាមដានការអនុវត្តដោយផ្ទាល់ ដែលធ្វើឡើងដោយ មន្ត្រីអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ តាមខេត្តមួយចំនួន ពាក់ព័ន្ធនឹងការអនុវត្តការងាររបស់លេខាធិការដ្ឋានខេត្ត (សៀមរាប កណ្តាល បន្ទាយមានជ័យ ស្វាយរៀង)
- ការចុះតាមដានការអនុវត្តការងារមន្ត្រីនគរបាលយុត្តិធម៌របស់អគ្គស្នងការដ្ឋាននគរបាលជាតិក្នុងពេលប្រតិបត្តិការ
- ការវាយតម្លៃពាក់កណ្តាលអណត្តិនៃផែនការជាតិ (២០១៤-២០១៦)គាំទ្រដោយអង្គការវិនរ៉ក់

នៅក្នុងឆ្នាំ២០១៦ នេះ ការសិក្សាស្រាវជ្រាវ ស្តីពីឱកាសទីផ្សារការងារ ត្រូវបានធ្វើឡើងដោយមានការគាំទ្រ និងសហការពី អង្គការ បញ្ឈប់អំពើជួញដូរកុមារ (**Cambodia ACTs**) ដែលលទ្ធផលនៃការស្រាវជ្រាវនេះ បានដាក់បង្ហាញក្នុងសិក្ខាសាលាម្តងរួចមកហើយ ដើម្បីប្រមូលធាតុចូលបន្ថែមទៀត ។ គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្កើតឱកាសការងារក្នុងស្រុក ដែលពលករអាចរកបាននៅក្នុងស្រុក ជាជាងការប្រថុយប្រថាននឹងគ្រោះថ្នាក់ ស្វែងរកការងារនៅក្រៅប្រទេស ។

## IV. សន្និដ្ឋាន និង វាយតម្លៃ

### ក. ចំណុចខ្លាំង៖

ផ្អែកលើរបាយការណ៍ នៃការបង្ក្រាបជាក់ស្តែង របស់កម្លាំងសមត្ថកិច្ច ទាំងនគរបាល ទាំងកងរាជអាវុធហត្ថ បានបង្ហាញថា បទល្មើសជួញដូរមនុស្សក្នុងឆ្នាំ២០១៦នេះធៀបទៅនឹងការបង្ក្រាបសរុបក្នុងឆ្នាំ២០១៥ បានថយចុះ ១៣ករណី ក្នុងនោះ បទល្មើសជួញដូរមនុស្ស បានថយចុះ២០ករណី និង

បទល្មើសជួញដូរ ផ្លូវភេទបានកើនឡើង០៧ករណី ។ សរុបមក លទ្ធផលសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំនេះ បានបង្ហាញពីការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល និងរដ្ឋបាលគ្រប់ថ្នាក់ កងកម្លាំងគ្រប់ប្រភេទ ព្រមទាំងដៃគូទាំងអស់ ដែលបានសហការគ្នាកាន់តែល្អប្រសើរ អាចទប់ស្កាត់បាននូវសន្ទុះនៃការធ្វើចំណាកស្រុក ការបោះបង់ការសិក្សារបស់យុវសិស្ស និងភាពប្រថុយប្រថានក្នុងការរកការងារនៅក្រៅប្រទេសតាមមេខ្យល់ ។ ការទទួលបានពត៌មាន និងការយល់ដឹងស្តីពីគុណសម្បត្តិ និងគុណវិបត្តិនៃចំណាកស្រុក កលល្បិច ជនល្មើស និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ត្រូវបានពង្រីកទៅដល់មូលដ្ឋាន និងតាមបណ្តាមុខសញ្ញាដែលងាយរងគ្រោះ ជាពិសេសយុវវ័យក្នុងនិងក្រៅសាលារៀន និងសហគមន៍ដែលមានអ្នកធ្វើចំណាកស្រុក ។ ជនរងគ្រោះដែលបានរកឃើញ ត្រូវបានទទួលនូវការយកចិត្តទុកដាក់ ក្នុងការផ្តល់សេវាអប់រំបំណិនជីវិត ជំនាញ និងមុខរបរ និងការថែទាំអប់រំ ពីមន្ទីរស្ថាប័ន និងអង្គការដៃគូបានយ៉ាងល្អប្រសើរ ។ ការអនុវត្តច្បាប់ក៏ត្រូវបានពង្រឹង និងបានធ្វើការស៊ើបអង្កេត និងអនុវត្តនីតិវិធីច្បាប់យ៉ាងហ្មត់ចត់ ។

លទ្ធផលខាងលើនេះ អាចទទួលបាន អាស្រ័យដោយៈ

១. គោលនយោបាយកំណែទម្រង់ជាតិ គ្រប់វិស័យរបស់រាជរដ្ឋាភិបាល បានពង្រីកឱកាសឲ្យប្រជាពលរដ្ឋរាប់លាននាក់មានការងារធ្វើ និងមានមុខរបរ បង្កើនប្រាក់ចំណូល លើកកម្ពស់ជីវភាពបានយ៉ាងល្អប្រសើរ ។

២. គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព នៅតែជាកម្លាំងចលករដ៏សំខាន់បំផុតក្នុងការបំផុសការចូលរួមពីគ្រប់សមាសភាពនៅមូលដ្ឋានដើម្បីការពារសន្តិសុខ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងរួមចំណែកអនុវត្តសកម្មភាពបង្ការ ទប់ស្កាត់ភាពរងគ្រោះ ពង្រឹងការអនុវត្តច្បាប់ និងជួយជនរងគ្រោះ បានល្អប្រសើរ ។

៣. គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ (២០១៥-២០២៥) និងគោលនយោបាយស្តីពី ទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា (ខែធ្នូ ឆ្នាំ២០១៤) ព្រមទាំងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន បានបង្កើននូវកាលានុវត្តភាពនៃការរកការងារក្នុងប្រទេស និងនៅក្រៅប្រទេសដោយស្របច្បាប់ និងកាត់បន្ថយហានិភ័យរបស់ពលករនៅក្រៅប្រទេស ។

៤. គោលនយោបាយគ្រប់គ្រងអន្តោប្រវេសន៍ ក៏ជាចំណែកមួយក្នុងការទប់ស្កាត់ការហូរចូលនៃជនបរទេសខុសច្បាប់ មកធ្វើការងារក្នុងប្រទេសកម្ពុជា ដែលអាចជាកត្តារុញច្រានឲ្យពលករខ្មែរចេញទៅរកការងារក្រៅប្រទេសជំនួសវិញ ។

៥. រាជរដ្ឋាភិបាល ក៏បានព្យាយាមស្វែងរកកិច្ចសហប្រតិបត្តិការជាមួយប្រទេសរីកចម្រើននានា ដើម្បីបញ្ជូនពលករកម្ពុជាដែលមានបំណងទៅធ្វើការក្រៅប្រទេសដោយស្របច្បាប់ បានរាប់ម៉ឺននាក់ ។

៦. រាជរដ្ឋាភិបាល ក៏បានដោះស្រាយភាពស្របច្បាប់ជូនពលករដែលបាន និងកំពុងតែចូល និងស្នាក់នៅធ្វើការងារក្នុងប្រទេសជិតខាងដោយមិនត្រឹមត្រូវតាមច្បាប់ ដើម្បីឲ្យពលករទាំងនោះមានសិទ្ធិស្របច្បាប់ សុវត្ថិភាពនៅកន្លែងការងារ និង ទទួលបានផលប្រយោជន៍ពេញលេញ បានរាប់ម៉ឺននាក់ ។

៧. រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ ចំពោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ និងផ្តន្ទាទោសជនល្មើស ។

៨. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ ព្រមទាំងបានបង្កើតនូវបទដ្ឋានគតិយុត្តមួយចំនួនទៀត ដើម្បីបំពេញបន្ថែម និងសម្រួលដល់ការអនុវត្តឲ្យរឹតតែមានប្រសិទ្ធភាពទ្វេឡើងថែមទៀត ។

៩. បានធ្វើកិច្ចព្រមព្រៀងសន្ធិសញ្ញាជំនួយទៅវិញទៅមក ក្នុងវិស័យព្រហ្មទណ្ឌ ជាមួយប្រទេស ចំនួន០៤ (វៀតណាម ឡាវ រុស្ស៊ី អង់គ្លេស និងពេរូ) សន្ធិសញ្ញា ស្តីពីបត្យាប័នជាមួយប្រទេសចំនួន០៧ (ថៃ ឡាវ វៀតណាម ចិន កូរ៉េ បារាំង និងរុស្ស៊ី) បានធ្វើកិច្ចព្រមព្រៀង ស្តីពីការផ្ទេរទណ្ឌិតជាមួយប្រទេស ចំនួន ០៧ (ថៃ វៀតណាម អូស្ត្រាលី ឥណ្ឌា រុស្ស៊ី អង់គ្លេស និងពេរូ) ។

១០. របៀបរបបការងារ និងទំនាក់ទំនងសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ត្រូវបានពង្រឹង និងពង្រីកយ៉ាងទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួមតែមួយ ។

១១. មានយុទ្ធសាស្ត្រទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ បង្ក្រាប ការផ្តន្ទាទោសជនល្មើស និងការការពារជនរងគ្រោះ ដោយមានការកំណត់អត្តសញ្ញាណជនរងគ្រោះកាន់តែជាក់លាក់ និងការផ្តល់សេវាស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍ ។

១២. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអនុវត្តតួនាទីដ៏សំខាន់ ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងសម្របសម្រួលជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ និងបានជំរុញការអនុវត្តច្បាប់ បទដ្ឋាន និងភារកិច្ចនៃបណ្តាក្រសួង ស្ថាប័ន អង្គភាព និងដៃគូ ក្នុងរចនាសម្ព័ន្ធគណៈកម្មាធិការជាតិ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យ៉ាងសកម្ម និងទទួលប្រសិទ្ធភាពខ្ពស់ ។

១៣. ជំនាញសមត្ថកិច្ច ឥរិយាបថ និងការប្តេជ្ញាចិត្តរបស់មន្ត្រីអនុវត្តន៍ច្បាប់ មានការប្រែប្រួលប្រសើរឡើងនៅក្នុងនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង និងក្នុងប្រព័ន្ធតុលាការក្នុងរឿងក្តីជួញដូរមនុស្ស ដោយ ផ្តោតទៅលើទំហំករណី និងបណ្តាញនៃប្រព័ន្ធបទល្មើសជួញដូរមនុស្ស ។

១៤. ភាគីពាក់ព័ន្ធ ដែលជាកម្លាំងចម្រុះពហុវិស័យទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានរួមគ្នាជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប សម្រាប់ការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ជាងមុន ។

## ខ.ចំណុចសេសសល់ និងបញ្ហាប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងមន្ត្រីអនុវត្តគ្រប់ថ្នាក់ក្នុងរចនាសម្ព័ន្ធ គ.ជ.ប.ជ របាក់តទទួលបានលទ្ធផលដូចខាងលើ ក៏នៅមានចំណុចសេសសល់និងប្រឈមមួយចំនួនដែលចាំបាច់ត្រូវយកចិត្តទុកដាក់ កែលម្អ និងដោះស្រាយ ៖

១. សន្ទុះនៃលំហូរចំណាកស្រុក ឬទេសន្តរប្រវេសន៍នៅតែបន្ត តែការគ្រប់គ្រង នៅមិនទាន់បានល្អ ទិន្នន័យពលករចេញ និងចូល មិនទាន់ត្រូវបានបែងចែកឲ្យបានជាក់លាក់ អំពីអ្នកដែលបានចេញចូលច្រើនដង ធ្វើឲ្យទិន្នន័យមិនទាន់សុក្រឹតនៅឡើយ

២. ប្រព័ន្ធតាមដានត្រួតពិនិត្យស្ថានភាព និងទិន្នន័យជាក់លាក់ ពាក់ព័ន្ធនឹងពលករកម្ពុជានៅក្រៅប្រទេស មិនទាន់រឹងមាំ

៣. ការព្យាយាមចូលទៅប្រទេសដទៃដើម្បីស្វែងរកការងារ និងរបៀបរស់នៅ មិនស្របច្បាប់ ទោះជាប្រទេសណាក៏ដោយ គឺប្រឈមនឹងការអនុវត្តច្បាប់ និងការកេងប្រវ័ញ្ចកម្រិតខ្ពស់ ។ ជាក់ស្តែង ការចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន បញ្ជូនត្រឡប់ ឬចាប់ដាក់ពន្ធនាគារ ផាកពិន័យ ឬត្រូវដាក់ទណ្ឌកម្ម គ្រប់រូបភាព ។

៤. ពលករខ្មែរមួយចំនួន នៅតែត្រូវបានគេក្លែងអត្តសញ្ញាណ និងបញ្ជូនទៅនេសាទខុសច្បាប់ និងជួញដូរទៅប្រទេសដទៃទៀត ។ **ទន្ទឹមនឹងនេះ ក៏មានលេចចេញនូវសញ្ញាណនៃបទល្មើសថ្មីៗទៀត ដែលត្រូវបន្តយកចិត្តទុកដាក់ ។**

៥. ចំនួនអ្នកជាប់ពន្ធនាគារនៅក្រៅប្រទេស មានចំនួនច្រើន ហើយត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញជាបន្តបន្ទាប់ ព្រមជាមួយនឹងជនរងគ្រោះ ដែលបានកើនឡើងជាបន្តបន្ទាប់ និងខ្វះមណ្ឌលស្តារនីតិសម្បទារដ្ឋ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

៦. ទោះបីមានការផ្សព្វផ្សាយទូលំទូលាយ តាមគ្រប់មធ្យោបាយយ៉ាងណា ក៏ប្រជាពលរដ្ឋមួយចំនួន នៅតែជឿតាមការអូសទាញរបស់មេខ្យល់ ប្រថុយប្រថាននឹងភាពខុសច្បាប់ ទាំងការចេញទៅរកការងារ ទាំងការរៀបអាពាហ៍ពិពាហ៍ទៅ ឬនៅក្រៅប្រទេស ទាំងការពរពោះជំនួស ។ល។ ថ្មីៗនេះ ក៏មានការកើនឡើងនូវសេវាកំសាន្តសប្បាយដែលបង្កប់នូវសេវាផ្លូវភេទ (ពេស្យាកម្ម) ដែលជាប្រភពនៃអំពើជួញដូរមនុស្ស ជួញដូរផ្លូវភេទ និងបទល្មើសផ្សេងៗទៀត ។

៧. ក្រសួង មន្ទីរ ស្ថាប័នមួយចំនួន នៅមិនទាន់ឲ្យតម្លៃលើសារៈសំខាន់នៃកិច្ចសហការ និងមិនទាន់បានឆ្លើយតបទៅនឹងចំណុចខ្វះចន្លោះ នៃសេចក្តីត្រូវការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការផ្តល់សេវាជូនជនរងគ្រោះ ជាដើម ។

៨. រាជធានី/ខេត្ត ដែលមានការផ្លាស់ប្តូរសមាសភាព លេខាធិការដ្ឋាន ឬក្រុមការងារ មិនទាន់មានការចាត់តាំងច្បាស់លាស់ ធ្វើឲ្យការអនុវត្ត និងការតាមដានការងារ មានកម្រិត ។

៩. មិនទាន់មានការរឹតបន្តឹង ឬវិធានការចំពោះក្រុមហ៊ុនដែលមិនបានគោរពគោលការណ៍ តាមច្បាប់កំណត់ ដោយបានបង្កឲ្យមានភាពរងគ្រោះដល់ពលករ ហើយមិនមានដំណោះស្រាយច្បាស់លាស់ ធ្វើឲ្យមានភាពថ្នាំងថ្នាក់ពីពលករ ឬគ្រួសារពលកររងគ្រោះ ។

១០. ក្រុមកិច្ចការយុត្តិធម៌ ជាផ្នែកមួយដ៏សំខាន់ ក្នុងការបំពេញបន្ថែមក្របខណ្ឌច្បាប់ និងកិច្ចសហការប្រតិបត្តិការ ផ្នែកលក្ខណៈអន្តរជាតិ ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងនោះយើងពិនិត្យឃើញថានៅមានចំណុចខ្វះចន្លោះមួយចំនួន ដូចជា កិច្ចសហប្រតិបត្តិការ ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ការផ្តន្ទាទោស ការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រៅប្រទេស ដែលជាកង្វល់ និងចាត់ថាជាកិច្ចការ អាទិភាព ដែលត្រូវបំពេញបន្ថែមឲ្យបាន ។

១១. ការអនុវត្តបទដ្ឋានច្បាប់ពាក់ព័ន្ធមួយចំនួន នៅមិនទាន់បានពង្រឹង ដែលនាំឲ្យកើតនូវបទល្មើសមួយចំនួន ក្នុងពេលចន្លោះប្រហោង ។

## VI. ទិសដៅ ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ៖ (១)ការពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ (២) ការលើកកម្ពស់ការបង្ការ ទប់ស្កាត់ (៣) ការពង្រឹងយុត្តិធម៌ព្រហ្មទណ្ឌ (៤) ការលើកកម្ពស់កិច្ចការពារជនរងគ្រោះ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាពក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា មានជាអាទិ៍ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ ការជួញដូរ និងដកហូតសរីរាង្គ ការជួញដូរ និងរត់ពន្ធទារក និងកុមារ ឆ្លងដែន ការជួញដូរពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ...ជាដើម និង ដើម្បីពង្រឹងរបៀបរបបការងារក្នុងរចនាសម្ព័ន្ធឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅសំខាន់ៗជាគន្លឹះ ដូចខាងក្រោម ៖

១. រួមគ្នាបន្តជំរុញការអនុវត្តកាន់តែខ្លាំងក្លា៖
- គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍
- អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និង
- វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

២. រួមគ្នាបន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីពហុភាគីទាំងឡាយដែលមានស្រាប់ និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

៤. ផ្សព្វផ្សាយរបាយការណ៍ ឆ្នាំ២០១៦ ទិសដៅឆ្នាំ២០១៧ និងលទ្ធផលនៃការវាយតម្លៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរៀបចំកែលម្អសកម្មភាពបន្តទៅឆ្នាំ ២០១៧-២០១៨ ។

៣. រចនាសម្ព័ន្ធគ្រប់ថ្នាក់ នៃគ.ជ.ប.ជ និង គ.រ/ខ.ប.ជ៖ សម្របសម្រួលពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែកគ្រប់វិស័យ និងរវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធអង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជនដើម្បីបង្កើតសកម្មភាព អនុវត្តយុទ្ធសាស្ត្រទាំងបួនដែលបានគ្រោងទុកក្នុងផែនការជាតិ ផែនការក្រុមរបស់ការងារទាំង០៦ និងផែនការរាជធានី/ខេត្តទាំង២៥ និងរួមគ្នាបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

៥. ក្រុមការងារបង្ការទប់ស្កាត់ និងគ្រប់ស្ថាប័ន៖ បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធានដើម្បីលើកកម្ពស់ការយល់ដឹងជាសកលអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតឲ្យបានទូលំទូលាយ ដល់គ្រប់មុខសញ្ញាប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុងសាលារៀន និងក្រៅសាលារៀន និងក្រុមជនដែលងាយរងគ្រោះ។

៦. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ៖

- ជួបប្រជុំទ្វេភាគី ជាមួយក្រសួងសន្តិសុខសាធារណៈចិន ដើម្បីរៀបចំផែនការអនុវត្តកិច្ចព្រមព្រៀង
- ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា
- ជំរុញការពិភាក្សាជាមួយប្រទេសពាក់ព័ន្ធដទៃទៀត ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ ។
- ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ពលការិនីបម្រើការតាមផ្ទះ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូននិងប្រទេសទទួលប្រកបដោយសមធម៌។
- ជំរុញការអនុវត្តច្បាប់គោលនយោបាយ និងបទដ្ឋានគតិយុត្តនានាទៅតាមមុខសញ្ញា នៃក្រសួងស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៩. ក្រុមការងារការពារជនរងគ្រោះ៖

- ពិនិត្យលទ្ធភាពក្នុងការផ្តល់សេវាជូនជនរងគ្រោះតាមមណ្ឌលថែទាំជនរងគ្រោះ របស់អង្គការដៃគូ និងតាមសហគមន៍
- បន្តរៀបចំមណ្ឌលរដ្ឋ សម្រាប់ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបញ្ជូនមកពីក្រៅប្រទេស
- បន្តបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងទាំងចុះតាមដានការអនុវត្ត។

១២. ក្រុមការងារអនុវត្តច្បាប់៖

- ជំរុញ និងលើកកម្ពស់ការស៊ើបអង្កេត ស្រាវជ្រាវរកមុខសញ្ញាជនល្មើស និងបណ្តាញឧក្រិដ្ឋជន ដែលបាន និងកំពុងតែធ្វើសកម្មភាពតាមគ្រប់វិធី ដើម្បីកេងចំណេញពិអំពើជួញដូរមនុស្សគ្រប់រូបភាព
- បន្តពង្រឹងការអនុវត្តបទបញ្ជា និងវិធានការនានា ឲ្យបានម៉ឺងមាត់ សំដៅបង្ក្រាបបទល្មើសជួញដូរមនុស្សទាន់សភាពការណ៍ និងសង្គ្រោះជនរងគ្រោះទាន់ពេលវេលា
- តាមដានសកម្មភាពមុខសញ្ញា ដែលសង្ស័យ និងមានវិធានការ
- សហការជាមួយតុលាការ ក្នុងការផ្តល់ភស្តុតាងដាក់បន្ទុកជនល្មើស ដើម្បីយុត្តិធម៌ជនរងគ្រោះ ។

១១. ក្រុមការងារកិច្ចការយុត្តិធម៌៖

- ជំរុញការស្នើសុំការអនុម័តច្បាប់ប្រឆាំងអំពើរត់ពន្ធមនុស្ស
- ជម្រុញការរៀបចំច្បាប់ស្តីពីការពពោះជំនួស
- ជំរុញការផ្តន្ទាទោសជនល្មើសដោយអំពើជួញដូរមនុស្ស តាមតុលាការរាជធានី ខេត្ត
- ជំរុញការប្រមូលទិន្នន័យនៃការផ្តន្ទាទោសជនល្មើស និងបន្តពិភាក្សា ស្តីពី «ការពង្រឹងការអនុវត្តច្បាប់ ដើម្បីយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស »
- ជំរុញការរៀបចំ ការចុះហត្ថលេខា និងការអនុវត្តសន្ធិសញ្ញាជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ សន្ធិសញ្ញាបត្យាប័ន និងកិច្ចព្រមព្រៀងការផ្ទេរទណ្ឌិត
- ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមកក្នុងវិស័យ យុត្តិធម៌ព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ ។

១២. ក្រុមការងារទេសន្តរប្រវេសន៍ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖

- សិក្សាលទ្ធផលនៃការស្រាវជ្រាវ អំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុង និងក្រៅប្រទេស ស្វែងយល់ពីកត្តារុញច្រាន កត្តាអូសទាញ និងរៀបចំផែនការបង្ការទប់ស្កាត់ចំណាកស្រុកដែលប្រថុយប្រថាន ។
- ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។
- បន្តរៀបចំវិធានការ «គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី» (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋម ន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **និងជាប្រធាន** គ.ជ.ប.ជ) ។

១៤. អគ្គលេខាធិការដ្ឋាន គ្រប់ថ្នាក់ ក្នុងរចនាសម្ព័ន្ធ គ.ជ.ប.ជ បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល និង ពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីជំនាញពាក់ព័ន្ធគ្រប់ផ្នែក ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

១៦. រួមគ្នាបន្តគាំទ្រ និងពង្រឹងការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ
"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"
-ឯកឧត្តម លោកជំទាវប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

## *តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**<br>- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ (ខេត្តបាត់ដំបង សរុប**២០**នាក់ ស្រី**០១**នាក់)<br>- ការពង្រឹងសមត្ថភាព ស្តីពីសុវត្ថិភាពទេសន្តប្រវេសន៍ និងយន្តការឆ្លើយតបអំពើជួញដូរមនុស្ស (ខេត្តស្វាយរៀង ព្រៃវែង **០២**វគ្គ សរុប**៥០**នាក់ ស្រី**១២**នាក់)<br>- គ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប (ក្រសួងមហាផ្ទៃ សរុប**៣៥**នាក់ ស្រី**០៨**នាក់)<br>- ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប (ខេត្តកណ្តាល, សៀមរាប បន្ទាយមានជ័យ **០៣**វគ្គ សរុប**២០៩**នាក់ ស្រី**៧០**នាក់ និងអង្គការដៃនដីមនុស្សហូឡង់ធ្វើនៅរាជធានីភ្នំពេញ និងខេត្តកំពង់ចាម **០២**វគ្គ សរុប**៦៤**នាក់ ស្រី**១៩**នាក់)សហការជាមួយអង្គការវិនរ៉ក់អន្តរជាតិ (WI) , សម្ព័ន្ធអង្គការកម្ពុជាបញ្ឈប់ការជួញដូរកុមារ (Cambodia ACTs), អង្គការដៃនដីមនុស្ស ហុល្លង់ (Terre des Hommes), អង្គការ UNACT | ០៩ | ៣៧៨ | ១១០ |
| ២ | **ក្រសួងកិច្ចការនារី**<br>- ស្តីពីច្បាប់និងឯកសារក្បួននីតិវិធីប្រតិបត្តិការរបស់ភ្នាក់ងារនគរបាលយុត្តិធម៌<br>- ស្តីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា | ០៦ | ២៥២ | ២១៥ |
| ៣ | **ក្រសួងទេសចរណ៍**<br>- ស្តីពីសុវត្ថិភាពក្នុងវិស័យទេសចរណ៍ដល់ម្ចាស់សណ្ឋាគារ បុគ្គលិកសណ្ឋាគារទូទាំងរាជធានី ខេត្ត | ៥២៤ | ២៦៦ | ១១៧ |
| ៤ | **អគ្គស្នងការដ្ឋាននគរបាលជាតិ (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)**<br>- ស្តីពីការងារស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស<br>- ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ<br>- ស្តីពីការប្រឆាំងបទល្មើសទេចរណ៍ផ្លូវភេទតាមប្រព័ន្ធបច្ចេកទេស<br>- ស្តីពីព័ត៌មានអ៊ិនធឺណេត និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ | ១០ | ២៣០ | ៥៥ |

| | | | | |
|---|---|---|---|---|
| | - ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងផលប៉ះពាល់ចំពោះកុមារ និងការស៊ើបអង្កេតមូលដ្ឋាន<br>- ស្តីពីបច្ចេកទេសសួរចម្លើយ<br>- ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ<br>- ស្តីពីការសម្ភាសកុមារ<br>- ស្តីពីបច្ចេកទេសសម្ភាសន៍សាក្សីជនរងគ្រោះ និងជន សង្ស័យ<br>- ស្តីពីមន្ត្រីនគរបាលយុត្តិធម៌ | | | |
| ៥ | **ខេត្តកំពត** ស្តីពីការបង្ការទប់ស្កាត់អពើជួញដូរមនុស្ស | ០១ | ១១៤ | ១២ |
| ៦ | **ខេត្តបាត់ដំបង**<br>- ច្បាប់"**ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ** " (សរុប**៧៥**នាក់ លេខាធិការ នៃគណៈកម្មាធិការ (គ.ខ.ប.ជ) ខេត្ត សហការជាមួយអង្គការទស្សនៈពិភពលោក)<br>- ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព (សរុប**៥០**នាក់ ស្រី**៣១**នាក់ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សហការជាមួយអង្គការទស្សនៈពិភពលោក)<br>- ស្តីពីការទទួលបណ្តឹង និងមូលដ្ឋានឆ្លើយតបដំបូង ចំពោះជនល្មើស( សរុប**៤០**នាក់ ស្រី**០៣**នាក់ ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការការពារកុមារCPU)<br>- ច្បាប់"ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម<br>- ផ្លូវភេទ (**០២**វគ្គ សរុប**២៧៥**នាក់ ស្រី**១៧៣**នាក់ មន្ទីរកិច្ចការនារីខេត្ត និងសហការជាមួយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាLAC) | ០៥ | ៤៤០ | ២០៧ |
| ៧ | **ខេត្តកំពង់ស្ពឺ** ស្តីពីវិធីសាស្ត្រ ក្នុងការសម្របសម្រួល ការបញ្ជ្រាបយេនឌ័រ ការជួញដូរមនុស្ស | ០១ | ៦០ | ៦០ |
| ៨ | **ខេត្តស្វាយរៀង**<br>- ស្តីពីកិច្ចការពារកុមារ និងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ (**០២**វគ្គ សរុប**៦០**នាក់ ស្រី**២៨**នាក់ សហការជាមួយអង្គការ Child Fund)<br>- ស្តីពីទំនាក់ទំនង និងការផ្លាស់ប្តូរអាកប្បកិរិយា ក្នុងការធ្វើចំណាកស្រុក ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងក្រោយធ្វើសមាហរណកម្មវិញ **០៨**វគ្គ សរុប**២១១**នាក់ ស្រី**៩៩**នាក់ សហការជាមួយអង្គការIOM)<br>- ស្តីពីច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុប**៣៩**នាក់) | ១៣ | ៣៧១ | ១៦៤ |

| | | | | |
|---|---|---|---|---|
| | - ស្តីពីការចូលរួមចំណែកទទួលខុសត្រូវក្នុងការលុបបំបាត់អំពើទាសភាព និងជួញដូរមនុស្ស **០២**វគ្គ សរុប**៦១**នាក់ ស្រី**៣៧**នាក់ សហការជាមួយអង្គការIOM) | | | |
| ៩ | **ខេត្តកណ្តាល** ស្តីពីវិធីសាស្ត្រក្នុងការសម្របសម្រួល ការបញ្ជ្រាបយេនឌ័រ ការជួញដូរមនុស្ស | ០២ | ១០៩ | ៧១ |
| ១០ | **ខេត្តកំពង់ឆ្នាំង** ស្តីពីគោលគំនិតយេនឌ័រ កិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស | ១៩ | ៥៨៧ | ៣១៧ |
| ១១ | **ខេត្តកំពង់ចាម** ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស | ១ | ៤៦ | ២៥ |
| ១២ | **ខេត្តក្រចេះ** ស្តីពីការរំលោភបំពានលើកុមារ និងសិទ្ធិកុមារ | ០៣ | ២៧៣ | ២៤២ |
| ១៣ | **ខេត្តព្រះសីហនុ** ស្តីពីការទប់ស្កាត់អំពើជួញដូរ មនុស្ស និងកិច្ចការពារស្ត្រី និងកុមារ | ០១ | ៦១ | ២០ |
| ១៤ | **ខេត្តព្រៃវែង** ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព | ០៥ | ១០២ | ១២ |
| ១៥ | **ខេត្តរតនគិរី**<br>- ស្តីពីតួនាទីភារកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាល (សរុប**១២៧**នាក់ ស្រី**១៥**នាក់)<br>- ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌសរុប**១១**នាក់<br>- ស្តីពីសិទ្ធិទាំង៤របស់កុមារ (**០២**វគ្គ សរុប**១៣០**នាក់ ស្រី**៤៦**នាក់ មន្ទីរសង្គមកិច្ចខេត្ត)<br>- ស្តីពីសុខភាព និងសុវត្ថិភាពការងារដល់កម្មករនិយោជិក (**០៣**វគ្គ សរុប**២៥០**នាក់)<br>- ស្តីពីការផ្លាស់ប្តូរយោបល់លើផែនការសកម្មភាពទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍ និងការមានផ្ទៃពោះនៅវ័យជំទង់ (សរុប**៧៩**នាក់ ស្រី**៥៨**នាក់ មន្ទីរកិច្ចការនារីខេត្ត សហការ ជាមួយអង្គការ UNICEF)<br>- ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា (សរុប**៤៤**នាក់ ស្រី**៣៨**នាក់ មន្ទីរកិច្ចការនារីខេត្ត)<br>- ស្តីពីការធ្វើរបា<br>- យការណ៍ និងការសរសេរកំណត់ហេតុ (សរុប**៣៩**នាក់ មន្ទីរកិច្ចការនារីខេត្ត) | ០៩ | ៦៦៩ | ១៥៧ |
| ១៦ | **ខេត្តពោធិ៍សាត់**<br>- ស្តីពីពលកម្មកុមារ, ប្រព័ន្ធតាមដានកុមារ (សរុប**២១២**នាក់ ស្រី**៩១**នាក់ អង្គការវឌ្ឍនភាព)<br>- ស្តីពីការការពារកុមារ និងបច្ចេកទេសក្នុងការសម្ភាសកុមារ | ០២ | ២៥០ | ៩៧ |

| | | | | |
|---|---|---|---|---|
| | វងគ្រោះ និងកុមាររងការកេងប្រវ័ញ្ចពលកម្ម (សរុប**៣៨**នាក់ ស្រី**០៦**នាក់ អង្គការCOCD) | | | |
| **១៧** | **ខេត្តតាកែវ**<br>- ស្តីពីការការពារកុមារ ទប់ស្កាត់ការប្រើប្រាស់អំពើហិង្សាលើកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព (សរុប៦៨នាក់ ស្រី៥៦នាក់ មន្ទីរកិច្ចការនារីខេត្ត សហការជាមួយអង្គការទស្សនៈពិភពលោក)<br>- ស្តីពីកិច្ចការពារកុមារពីការជួញដូរ និងសិទ្ធិកុមារ **០៨**វគ្គ សរុប**៣៧៥**នាក់ ស្រី**២៦២**នាក់ មន្ទីរកិច្ចការនារីខេត្ត សហការជាមួយអង្គការទស្សនៈពិភពលោក)<br>- ស្តីពីជំនាញវិជ្ជាជីវៈ **០២**វគ្គ សរុប**៦០**នាក់ ស្រី**៣៨**នាក់ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត)<br>- ស្តីពីការត្រៀមលក្ខណៈក្នុងការស្វែងរកការងារធ្វើ **០២**វគ្គ សរុប**៥០**នាក់ ស្រី**៣៣**នាក់ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត) | **១៣** | **៥៥៣** | **៣៨៩** |
| | *សរុប* | *១០៨វគ្គ* | *៤,៧៦១នាក់* | *២,២៨៣នាក់* |

# ឧបសម្ព័ន្ធ២

## *តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហការ*

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| **គណៈកម្មាធិការជាតិគ.ជ.ប.ជ** | - សន្និបាតបូកសរុបលទ្ធផលការងារប្រចាំ ឆ្នាំ២០១៥ និងទិសដៅអនុវត្តឆ្នាំ២០១៦ របស់ គ.ជ.ប.ជ និងពិធីប្រកាសដាក់ឲ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅសាលប្រជុំក្រសួងមហាផ្ទៃ អគារ ទ ។<br>- ប្រជុំបូកសរុបរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទីស្តីការ ក្រសួងមហាផ្ទៃ។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពីកិច្ចប្រជុំដកបទពិសោធន៍លើការងារគ្រប់គ្រងលំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ នៅសាលាខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពចូលរួមសរុបជាង **២០០**នាក់។<br>- បានអញ្ជើញចូលរួមប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការកែសម្រួលអនុស្សរណៈរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីបង្កើត និងដំណើរការគណៈកម្មការរួមគ្នាកម្ពុជា-អាមេរិក សម្រាប់ការធ្វើមាតុភូមិនិវត្តន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>- បានដឹកនាំរៀបចំប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៦ នៅសាលមហោស្រពកោះពេជ្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ និងមានភ្ញៀវចូលរួម ប្រមាណបីពាន់នាក់ ។<br>- បានដឹកនាំរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡា ហោម ស ខេង** នាយករដ្ឋមន្ត្រីស្តីទី និងជាប្រធាន គ.ជ.ប.ជ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ដែលមានសមាសភាពចូលរួមប្រមាណ១៥០នាក់ ។ |
| **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** | ❖ បានសម្របសម្រួលសរុប១៩០លើក<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លើរបាយការណ៍ថ្នាក់ជាតិពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្នាំ២០១៦។<br>- ទទួលជួបក្រុមការពារកុមារ ពីអង្គការ Unicef ពិភាក្សាអំពីការជួញដូរកុមារតាមប្រព័ន្ធអ៊ីនធឺណែត។<br>- ចូលរួមក្នុងកម្មវិធីការថ្លែងអំណរគុណសម្រាប់ភាពជាដៃគូ ក្នុងការប្រយុទ្ធប្រឆាំងអំពើធ្វើអាជីវកម្មផ្លូវភេទលើអនីតិជនក្នុងប្រទេសកម្ពុជា ចាប់ពីឆ្នាំ២០០៣ ដល់២០១៦ រៀបចំដោយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)។ |

| | |
|---|---|
| | - ចូលរួមជំនួបរវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃ គ.ជ.ប.ជ ជាមួយប្រតិភូអង្គការបេសកកម្មអន្តរជាតិ (IJM) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅទៅស្តីការក្រសួងមហាផ្ទៃ។<br>- ជួបប្រជុំពិភាក្សាដកស្រង់បទពិសោធន៍ការងារប្រឆាំងអំពើជួញដូរមនុស្ស រវាង គ.ជ.ប.ជ ជាមួយគណៈប្រតិភូជាន់ខ្ពស់ ប្រទេសនេប៉ាល់ដែលដឹកនាំដោយ លោកជំទាវ Radhika Aryal រដ្ឋលេខាធិការក្រសួងស្ត្រី កុមារ និងសុខុមាលភាពសង្គម។<br>- ជួបពិភាក្សាជាមួយអ្នកតាមដានខាងក្រៅ លោក Adam Novak មកពីសហគមន៍អឺរ៉ុប ស្តីពីការងារទេសន្តរប្រវេសន៍ និងគម្រោង MIGRA-SAFE នៅសាលVIP ក្រសួងមហាផ្ទៃ។<br>- ដឹកនាំរៀបចំកិច្ចប្រជុំ ទ្វេភាគីចិន-កម្ពុជា ដែលគណៈប្រតិភូចិនដឹកនាំដោយ លោក ឆេន ស៊ីគូ អគ្គនាយករង នៃអគ្គនាយកដ្ឋានស៊ើបអង្កេត របស់ក្រសួងសន្តិសុខសាធារណៈ ដើម្បីពិភាក្សាសម្រេចលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប ។<br>- អញ្ជើញជាគណៈអធិបតី ក្នុងពិធីបិទសន្និបាតបូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំ ឆ្នាំ២០១៥ និងលើកទិសដៅការងារ ឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តកំពង់ធំ។<br>- អញ្ជើញជាអធិបតីភាព ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តព្រះវិហារ។<br>- អញ្ជើញជាអធិបតីភាពក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអន្តរក្រសួង និងអង្គការដៃគូ ស្តីពីការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរនិងចិន ដើម្បីពិនិត្យកែសម្រួលលើកិច្ចព្រមព្រៀងរវាងកម្ពុជា-ចិន ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស (ចំនួន០៨លើក)។<br>- ដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន៣៣លើក។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអន្តរក្រសួង និងអង្គការដៃគូ ស្តីពីអន្តរាគមន៍រវាងអ្នកសុំកូន និងស្ត្រីពពោះ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន០៤លើក។<br>- ដឹកនាំកិច្ចប្រជុំពិនិត្យរបាយការណ៍ឆ្នាំតាមក្រុមជំនួយកិច្ចការទាំង៦ របស់អគ្គលេខាធិការដ្ឋានឡើងវិញ ដោយធ្វើការកែតម្រូវ និងផ្ទៀងផ្ទាត់ទិន្នន័យនៃលទ្ធផលត្រឹមត្រូវដែលប្រមូលបានពីស្ថាប័នជំនាញដែលពាក់ព័ន្ធក្រុមនីមួយៗ ជាលើកចុងក្រោយ ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ឆ្នាំរួមរបស់ គ.ជ.ប.ជ។<br>- អញ្ជើញជាអធិបតីភាព ក្នុងពីធីផ្សព្វផ្សាយគោលនយោបាយអប់រំ កំណែទម្រង់វិស័យអប់រំ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនាគតយុវជននៅវិទ្យាល័យព្រះបាទសុរាម្រឹត ក្រុងកំពង់ឆ្នាំង និងនៅវិទ្យាល័យសីហមុនី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។<br>- អញ្ជើញចូលរួមក្នុងកិច្ចប្រជុំស្តីពីថវិកាឆ្លើយតបនឹងយេនឌ័រ ដែលមានសមាសភាពមកពីគ្រប់ បណ្តាក្រសួង-ស្ថាប័នចំនួន១៨២នាក់។<br>- អញ្ជើញចូលរួមធ្វើជាវាគ្មិនពិសេសក្នុងវេទិកាអ្នកស្តាប់វិទ្យុអាស៊ីសេរី ពិភាក្សាលើប្រធានបទ យន្តការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ និងអំពើជួញដូរមនុស្ស។ |

| | |
|---|---|
| | - ដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីការងាររបស់ក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ជួបពិភាក្សាការងារជាមួយ លោក Oliver Ching លេខាជាន់ខ្ពស់ផ្នែក កិច្ចការនយោបាយ នៃស្ថានទូតសាំងហ្គាពួរ ប្រចាំកម្ពុជា ស្តីពីគំនិតផ្តួចផ្តើមរបស់កម្ពុជា លើវិធានការបង្ការទប់ស្កាត់ ការការពារ និងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលត្រូវដាក់បញ្ចូលក្នុងរបៀបវារៈកិច្ចប្រជុំកោះបាលី ប្រទេសឥណ្ឌូនេស៊ី នៅក្រសួងមហាផ្ទៃ។<br>- ជួបពិភាក្សាការងារជាមួយលោក ស៊ីមម៉ុន ហ្វីលលូស ភារៈធារីរបស់ស្ថានទូតអូស្ត្រាលី ប្រចាំកម្ពុជា ស្តីពីសេចក្តីព្រាងឯកសារពាក់ព័ន្ធក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកោះបាលី ប្រទេសឥណ្ឌូនេស៊ីនៅក្រសួងមហាផ្ទៃ។<br>- អញ្ជើញជាអធិបតី ក្នុងពិធីប្រជុំផ្សព្វផ្សាយលទ្ធផលប្រឡងប្រណាំងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពឆ្នាំ២០១៥ និងទិសដៅអនុវត្តឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ នៅស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង។ និងបានអញ្ជើញទៅជួបសំណេះសំណាល ជាមួយបងប្អូនប្រជាការពារភូមិ-ឃុំ នៅសាលាស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ស្តីពីទេសន្តរប្រវេសន៍ និងអំពើជួញដូរ មនុស្ស។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុង របស់ក្រុមការងារជំនាញទាំង៦ ស្តីពីជម្រើសសកម្មភាពអាទិភាពសម្រាប់ការអនុវត្តក្នុងឆ្នាំ២០១៦ គ.ជ.ប.ជ។<br>- ជួបពិភាក្សាការងារជាមួយ លោកវេជ្ជបណ្ឌិត លូល មេកូណេន ប្រធានបេសកកម្មអង្គការ IOM ប្រចាំកម្ពុជា ស្តីពីការបើកវគ្គបណ្តុះបណ្តាលផ្នែកចិត្តសាស្ត្រសង្គម និងការត្រៀមខ្លួនរបស់សហគមន៍ សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការដៃគូសហប្រតិបត្តិការ ស្តីពីកិច្ចការងារស្រាវជ្រាវអំពីការពិនិត្យទីផ្សារ និងឱកាសការងាររបស់ពលករចំណាកស្រុក។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នារវាងកម្ពុជា-ឥណ្ឌា ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពចូលរួមមកពីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម(០២លើក)។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអន្តរក្រសួង និងអង្គការដៃគូពាក់ព័ន្ធ ស្តីអំពីគោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប (១០លើក)។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយនាយក និងក្រុមការងារអង្គការ IJM ប្រចាំកម្ពុជា ស្តីពីផែនការសកម្មភាពជាតិ គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការ IOM ស្តីពីការរៀបចំផែនការ សម្រាប់កិច្ចប្រជុំរវាងប្រទេសបញ្ជូន និងប្រទេសទទួល ដែលមាន ៤ប្រទេសគឺ កម្ពុជា ថៃ ភូមា និងឡាវ។<br>- លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតី ក្នុងពិធីសម្ពោធគម្រោង លើកកម្ពស់សិទ្ធិកុមារក្នុងអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា ដែលរៀបចំដោយអង្គការ Save the Children នៅសណ្ឋាគារ Imperial Garden Villa។ |

- ដឹកនាំកិច្ចប្រជុំជាមួយលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ)ខេត្តបន្ទាយមានជ័យ នៅសាលាខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងតាមដានសកម្មភាពការងារ និងពិនិត្យស្ថានភាពប្រែប្រួលនៃលំហូរទេសន្តរប្រវេសន៍ ការគ្រប់គ្រងការបញ្ជូនចេញ-ចូល ការទទួលជនរងគ្រោះ និងស្ថានភាពមណ្ឌលសំចត និងមណ្ឌលដៃគូពាក់ព័ន្ធ និងបានទៅធ្វើទស្សនកិច្ចនៅមណ្ឌលសំចតប៉ោយប៉ែត។ បន្ទាប់មកគណៈប្រតិភូបានជួបប្រជុំជាមួយមន្ត្រីមានសមត្ថកិច្ចនៅ ស្នាក់ការច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្នុងគោលបំណងស្តាប់របាយការណ៍ និងស្វាបស្ទង់ ស្ថានភាពអន្តោប្រវេសន៍ចេញ-ចូល និងបញ្ជូនត្រឡប់នូវពលករកម្ពុជាតាមច្រកទ្វារអន្តរជាតិ និងច្រករបៀងនានា។
- អញ្ជើញជាអធិបតីក្នុងវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្សខេត្តកំពង់ឆ្នាំង មានអ្នកចូលរួមប្រមាណ៥០០នាក់។
- ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការពិនិត្យលើផែនការនៃការចុះស្រាវជ្រាវអំពីពលករចំណាកស្រុកជាមួយអង្គការដៃគូអភិវឌ្ឍន៍រួមមាន Winrock, OI និង Cambidia Acts។
- ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យពិភាក្សា និងកែតម្រូវតារាងតាមដាន សន្ទស្សន៍អនុវត្តផែនការថ្នាក់ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៤-២០១៨ ជាមួយអង្គការដៃគូអភិវឌ្ឍន៍រួមមាន Winrock, GVC, Chab Dai និង Cambidia Acts។
- ចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ត្រីមាសទី១ របស់ក្រុមជំនួយកិច្ចការទាំងប្រាំមួយ ឡើងវិញមុននឹងដាក់បញ្ចូលទៅក្នុងរបាយការណ៍ត្រីមាសទី១ ថ្នាក់ជាតិ និងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០១៦ របស់ក្រុមនីមួយៗ។
- អញ្ជើញចូលរួមប្រជុំពិគ្រោះរវាងគណៈកម្មការការពារកុមារថ្នាក់ជាតិ និងបណ្តាញអង្គការសង្គមស៊ីវិល (CSO Consortium) រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។
- ប្រជុំពិភាក្សាផ្ទៃក្នុងការរៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្តរបស់ក្រុមជំនួយកិច្ចការទាំង៦ ដោយអនុលោមតាមផែនការថ្នាក់ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស២០១៤-២០១៨។
- ចូលរួមសិក្ខាសាលាជាមួយអង្គការពលកម្មអន្តរជាតិ IOM ស្តីពីការផ្លាស់ប្តូរឥរិយាបថ។
- ចូលរួមប្រកាសសមាសភាពក្រុមមារងារការពារជនរងគ្រោះ នៅក្រសួងសង្គមកិច្ច។
- ចុះបេសកកម្មទៅស្រុកម៉ាឡៃ ត្រួតពិនិត្យឯកសារក្លែងក្លាយ ដែលក្រុមហ៊ុនបានផ្តល់ឲ្យពលករ។
- ចូលរួមសិក្ខាសាលា ស្តីពីការលប់បំបាត់រាល់ទម្រង់ការរើសអើង ចំពោះស្ត្រីពិការ ដែលរៀបចំដោយក្រសួងកិច្ចការនារី នៅសណ្ឋាគារកាំបូឌីយ៉ាណា។
- ពិភាក្សាការងារ ការធ្វើផែនការលម្អិត ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- តាមដានសកម្មភាពការងារ និងប្រមូលរបាយការណ៍ពាក់ព័ន្ធនិងការងារអនុវត្តច្បាប់ ដែលដឹកនាំដោយអគ្គស្នងការនគរបាលជាតិ។
- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីមធ្យោបាយទាក់ទង ដើម្បីអភិវឌ្ឍផែនការយុទ្ធសាស្ត្រក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ចូលរួមអង្គប្រជុំលើកទី៣០ នៃប្រធានអង្គភាពឯកទេសប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ានដែលមានប្រទេសជាសមាជិកចំនួន៦ រួមមានប្រ៊ុយណេ កម្ពុជា ហ្វីលីពីន សឹង្ហបូរី ថៃ និងវៀតណាម តំណាងអគ្គលេខាធិការដ្ឋានអាស៊ាន និងតំណាងគម្រោង AAPTIP នៅសណ្ឋាគារ សុខាឡេស៊ីដង់ភ្នំពេញ។

| | |
|---|---|
| | - ដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីបច្ចុប្បន្នភាពការងាររបស់ គ.ជ.ប.ជ។<br>- អញ្ជើញជាគណៈអធិបតីក្នុងមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។<br>- ក្នុងនាមជាប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយប្រកាស ស្តីពីការកែសម្រួលសមាសភាពក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ។<br>- ដឹកនាំកិច្ចប្រជុំ ស្តីពីរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីនគរបាល និងមន្ត្រីរាជការស៊ីវិលចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញចូលរួមមិទ្ទិញខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ០១មិថុនា ឆ្នាំ២០១៦ ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។<br>- ចូលរួមកិច្ចប្រជុំនៅអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ជាមួយអង្គការដៃគូដែលពាក់ព័ន្ធការជួយធ្វើមាតុភូមិនិវត្តន៍ពលករខ្មែរនៅបរទេស ដែលរួមមាន១០អង្គការមាន៖ IJM, CENTRAL LICADO, LSCW, Caritas Cambodia, CCPCR, WI, ADHOC, SP និង LIM។<br>- សហការគ្នារៀបចំមេរៀន សម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។<br>- ចូលរួមកិច្ចប្រជុំ និងស្តាប់បទបង្ហាញរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការផ្តល់សេវាកម្មផ្សេងៗ ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយអង្គការ IOM។<br>- ចូលរួមកិច្ចប្រជុំពិនិត្យទៅលើយុទ្ធសាស្ត្រ (BBC Strategy) ការផ្លាស់ប្តូរផ្នត់គំនិត ដើម្បីបង្ការ ទប់ស្កាត់ពីភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយ UN-ACT។<br>- ចូលរួមប្រជុំពិភាក្សានៅអង្គការ IOM ស្តីពីការត្រៀមទទួលពលករខ្មែរ ដែលអាជ្ញាធរឥណ្ឌូនេស៊ី នឹងបញ្ជូនមកកម្ពុជាវិញក្នុងពេលឆាប់ៗ។<br>- ចូលរួមកិច្ចប្រជុំ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ របស់ក្រុមការងារអនុវត្តន៍ច្បាប់ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។<br>- អញ្ជើញជាវាគ្មិនក្នុងកម្មវិធីពិភាក្សាតុមូល ស្តីពីតួនាទីគណៈកម្មការការពារកុមារថ្នាក់ជាតិ នៅស្ថានីយ៍ ទូរទស្សន៍ និងវិទ្យុជាតិកម្ពុជា។<br>- ចូលរួមប្រជុំ ស្តីពីសមិទ្ធផលរបស់ AAPTIP ប្រចាំប្រទេសកម្ពុជា នៅក្រសួងយុត្តិធម៌។<br>- ចូលរួមប្រជុំនៅក្រសួងការបរទេស ជាមួយសហគមន៍អឺរ៉ុប ស្តីពីការផ្តល់ជំនួយ និងសិទ្ធិមនុស្ស នៅកម្ពុជា។<br>- អញ្ជើញជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាលជាមួយបងប្អូនញាតិមិត្ត របស់ពលករ ដែលកំពុងរង់ចាំពលករចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ និងកំពុងបានជួយសង្គ្រោះពីប្រទេសឥណ្ឌូនេស៊ី ហើយបញ្ជូនត្រឡប់មកស្រុកកំណើតវិញមានចំនួន១៨នាក់ ពិធីនេះប្រព្រឹត្តទៅនៅខេត្តសៀមរាប។ |

| | |
|---|---|
| | - អញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីរដ្ឋបាល និងកម្លាំងមានសមត្ថកិច្ចថ្នាក់ក្រោមជាតិចំនួន ២ស្រុកគឺ (ពារាំង និងស៊ីធរកណ្ដាល) ខេត្តព្រៃវែង ដើម្បីស្វែងយល់ពីស្ថានភាពប្រជាពលរដ្ឋ ដែលធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។ ឆ្លៀតឱកាសនោះ លោកជំទាវបានអញ្ជើញជួប សួរសុខទុក្ខ និងពិនិត្យពីស្ថានភាព របស់បងប្អូនព្រជាពលរដ្ឋ ជាពលករចំណាកស្រុកដែលទើប បញ្ជូនមកពីប្រទេសឥណ្ឌូនេស៊ី។<br>- អញ្ជើញជួបប្រជុំពិភាក្សាជាមួយតំណាងស្ថានទូតឥណ្ឌា ស្តីពីការរៀបចំអនុស្សរណៈរវាងកម្ពុជា-ឥណ្ឌា ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលប្រជុំក្រសួងមហាផ្ទៃ។<br>- អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្ដីពីការពង្រឹងកិច្ចសហការ រវាងមន្ត្រីសង្គមកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការជួយសង្គ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសៀមរាបថោន។<br>- ដឹកនាំកិច្ចប្រជុំអន្តរក្រសួងពិភាក្សារៀបចំមេរៀនសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។<br>- អញ្ជើញជាអធិបតីភាពក្នុងការធ្វើបទបង្ហាញរបស់វិទ្យាស្ថានបើកទូលាយ ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីមូលហេតុ និងមធ្យោបាយក្នុងការធ្វើចំណាកស្រុកដើម្បីស្វែងរកការងាររបស់ពលករមានជំនាញទាប និងពលករគ្មានជំនាញក្នុងប្រទេស។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំកម្មវិធីសម្រាប់ប្រជុំ "ដកបទពិសោធន៍ការងារគ្រប់គ្រង លំហូរមិនប្រក្រតីនៃពលករឆ្លងកាត់ព្រំដែន" ដែលមានគម្រោងធ្វើនៅខេត្តបន្ទាយមានជ័យ។<br>- ទទួលជួបសំណេះសំណាលសំដែងការស្វាគមន៍ លោក មែខល ហ្វ្រី មន្ត្រីផ្នែកនយោបាយរបស់ស្ថានទូតសហរដ្ឋអាមេរិក បានដំឡើងចំណាត់ថ្នាក់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពី"លេខ២កំពុងឃ្លាំមើល" មកកាន់លេខ២ក្នុងឆ្នាំ២០១៦នេះ។<br>- អញ្ជើញជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងសេចក្តីថ្លែងការណ៍ស្តីពីការពង្រឹងការឆ្លើយតបនឹងវិបត្តិទេសន្តរប្រវេសន៍ និងការជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញជួបពិភាក្សាការងារ ជាមួយលេខាទទួលបន្ទុកផ្នែកអន្តោប្រវេសន៍ របស់ស្ថានទូតអូស្ត្រាលីប្រចាំ កម្ពុជាចំនួន០២រូប លោកស្រី ភីឡា ដេវីដសាន់ និង លោក អាជុន ប៊ីសេន ស្តីពី Bali Process on Business នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ចំនួន០៥លើក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ ស្តីពីការធ្វើមូលដ្ឋានីយកម្មគោលដៅទី៥ និងគោលដៅផ្សេងទៀត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (គ.អ.ច) ២០១៦-២០៣០ នៅទីស្តីការក្រសួងកិច្ចការនារី។<br>- ក្នុងនាមជាអនុប្រធានសមាគមន៍នារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះ សំណាលជាមួយបងប្អូនមន្ត្រីរាជការជានារីថ្នាក់ខេត្ត នៅខេត្តបន្ទាយមានជ័យ។ |

| | |
|---|---|
| | - អញ្ជើញជាតំណាងក្រសួងមហាផ្ទៃ ក្នុងពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់ រវាងអង្គការ ការពារកុមារ នៃអង្គការមូលនិធិដើម្បីកុមារកម្ពុជា (CPU) និង ក្រសួងមហាផ្ទៃ ស្ដីពីការរួមចំណែកដើម្បីមនុស្សធម៌ នៅទីស្ដីការក្រសួងមហាផ្ទៃ។<br>- អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា ស្ដីពីការដោះស្រាយអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណេត ដែលរៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅសណ្ឋាគារសាន់វ៉េ។<br>- អញ្ជើញចូលរួមពិធីប្រកាសផ្ទេរភារកិច្ច តែងតាំងមុខតំណែង និងបំពាក់ឋានន្តរស័ក្តិ ជូននាយនគរបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ។<br>- ប្រជុំពិភាក្សា និងឯកភាពគ្នាក្នុងក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ដើម្បីរៀបចំផែនការចុះស្រាវជ្រាវ អង្កេតមើល និងស្វែងយល់ពីលំហូរពលករឆ្លងកាត់ព្រំដែនតាមច្រករបៀងស្មុគស្មាញ នៅក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យចំនួន៦ច្រក (ច្រករបៀង៤ និងច្រកអន្តរជាតិ២) ជាជំហានដំបូង។<br>- ដឹកនាំកិច្ចប្រជុំ ស្ដីពីការចាត់វិធានការនៃលំហូរពលករឆ្លងដែន និងការអនុវត្តជំនាញនៃក្រុមជំនួយកិច្ចការទាំង៦ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ នៅទីស្ដីការ គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចប្រជុំអន្តរក្រសួងត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគីចិន-កម្ពុជា ដើម្បីពិភាក្សាសម្រេចលើកិច្ចព្រមព្រៀង ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជទទួលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូខេត្តចាំងស៊ីប្រទេសចិន ដែលអញ្ជើញមកបំពេញទស្សនកិច្ច នៅកម្ពុជា ដើម្បីចែករំលែកនូវបទពិសោធន៍ការងារទៅវិញទៅមក ជំរុញឲ្យកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានភាពកាន់តែល្អប្រសើរ នៅទីស្ដីការក្រសួងមហាផ្ទៃ។<br>- ជួបប្រជុំពិភាក្សាការងារជាមួយអង្គការ Winrock នៅទីស្ដីការ គ.ជ.ប.ជ។ និងនៅពេលរសៀលបានទទួលជួបពិភាក្សាការងារជាមួយលោក William A.Heidt ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ក្នុងគោលបំណងដកស្រង់បទពិសោធន៍ការងារ ស្ដីពីការអនុវត្តផែន ការយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៦ នៅទីស្ដីការ គ.ជ.ប.ជ ។<br>- ដឹកនាំរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង គ.ជ.ប.ជ ជាមួយអង្គការអ្នកស្ម័គ្រចិត្តស៊ីវិល (GVC) ស្ដីពីគម្រោង Migra-Action ការតស៊ូមតិ ការតាមដាន និងការប្រាស្រ័យទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ ដោយមិនសុវត្ថិភាពនៅកម្ពុជា នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ជួបប្រជុំជាមួយអ្នកច្បាប់អាមេរិក ស្ដីពីច្បាប់ហិង្សានៅកន្លែងធ្វើការ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ចូលរួមប្រជុំ ស្ដីពីកិច្ចពិភាក្សាការពារគម្រោងថវិកាកម្រិតថ្នាក់ដឹកនាំប្រជុំឆ្នាំ២០១៧ គ.ជ.ប.ជ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។<br>- អញ្ជើញជាវាគ្មិន ក្នុងសន្និសីទស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបទបង្ហាញអំពីមេរៀនយល់ដឹងពីអំពើជួញដូរមនុស្ស រៀបចំដោយអង្គការMaritan's Purse នៅសណ្ឋាគារហ៊ីម៉ាវ៉ារី។<br>- អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំអំពីតួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ |

- អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ ស្តីពីការរៀបចំវិធានការគ្រប់គ្រងលំហូរមិនប្រក្រតីនៃពលករឆ្លងកាត់ព្រំដែន នៅសាលប្រជុំ គ.ជ.ប.ជ។
- អញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គ បិទវគ្គ និងជាគ្រូឧទ្ទេសនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលមានរយៈពេល៤ថ្ងៃ រៀបចំដោយ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។
- អញ្ជើញជាវាគ្មិន ក្នុងកិច្ចពិភាក្សាជំនាញស្តីពីការប្រយុទ្ធប្រឆាំង អំពើកេងប្រវ័ញ្ច និងអំពើរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ដើម្បីឲ្យអ៊ីនធឺណេតជាកន្លែងដែលកាន់តែមានសុវត្ថិភាព រៀបចំដោយអង្គការ APLE នៅសណ្ឋាគារ InterContinental។
- អញ្ជើញជាគណៈអធិបតី ក្នុងពិធីធ្វើបទបង្ហាញរបាយការណ៍ស្រាវជ្រាវអំពីលំអាន និងការអនុវត្តនៃការធ្វើចំណាកស្រុកក្នុងប្រទេសសម្រាប់និយោជិត ដែលមានកម្រិតទាប និងគ្មានជំនាញនៅប្រទេសកម្ពុជា រៀបចំដោយវិទ្យាស្ថានបើកទូលាយ នៅសណ្ឋាគារកាំបូឌីយ៉ាណា។
- អញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គ បិទវគ្គ និងជាគ្រូឧទ្ទេសនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប ដែលមាន រយៈពេល៣ថ្ងៃ រៀបចំដោយ គ.ជ.ប.ជ នៅសាលាខេត្តកណ្តាល។
- អញ្ជើញជាអធិបតីក្នុងវេទិកា សំឡេងអតីតជនរងគ្រោះដោយអំពើជួញដូរមនុស្សរៀបចំដោយអង្គការ WINROCK International នៅសណ្ឋាគារប៉ាវ៉ាឌី ខេត្តសៀមរាប។
- អញ្ជើញជាគណៈអធិបតីក្នុងសិក្ខាសាលា ស្តីពីការធ្វើបទបង្ហាញអំពី អនុស្សរណៈនៃការយោគយល់គ្នា រវាងកម្ពុជា-ចិន នៅសណ្ឋាគារកាំបូឌីយ៉ាណា។
- អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ នៅទីស្តីការក្រសួងសង្គមកិច្ច។
- ចូលរួមកិច្ចពិភាក្សា ស្តីពីអំពើកេងប្រវ័ញ្ចផ្លូវភេទ និងអំពើរំលោភបំពានលើកុមារ តាមប្រព័ន្ធវិទ្យាសាស្ត្រ។
- ចូលរួមសិក្ខាសាលាប្រចាំឆ្នាំ ស្តីពីការពិនិត្យការអនុវត្តគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា និងអភិវឌ្ឍន៍ផែនការសកម្មភាពសម្រាប់អនុវត្ត ឆ្នាំ២០១៧ នៅសណ្ឋាគារ Imperial Garden ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមកិច្ចសហការជាមួយគម្រោង ILO-Triangle។
- បញ្ជូនមន្ត្រី ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ជំនាញស្វែងរកការគាំទ្រមតិ លើបញ្ហាយេនឌ័រ និងពិការភាព នៅខេត្តព្រះសីហនុ ។
- អញ្ជើញជួបសំណេះសំណាលជាមួយតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពី "ការសិក្សាអំពីផលប៉ះពាល់នៃទេសន្តរប្រវេសន៍ចំពោះកុមារដែលធ្វើឡើងដោយអង្គការ UNICEF" នៅសាលប្រជុំគ.ជ.ប.ជ។
- អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស និងជាគណៈកម្មការវាយតម្លៃក្នុងទិវាភាពជាអ្នកដឹកនាំ ក្រោមប្រធានបទ "ភាពជាអ្នកបន្តវេន" នៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន(CJCC)។
- អញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាលើឯកសារពាក់ព័ន្ធ ដល់កិច្ចសហប្រតិបត្តិការ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណៈរដ្ឋប្រជាមានិត

| | |
|---|---|
| | ចិន ស្តីពី "កិច្ចព្រមព្រៀងលើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ស៊ី ជិនពីង ប្រធានាធិបតីនៃសាធារណៈរដ្ឋប្រជាមានិតចិន នៅវិមានសន្តិភាព។<br>- ដឹកនាំកិច្ចប្រជុំត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការផ្តល់សំណាងដល់ជនរងគ្រោះ នីតិវិធីជំនួយផ្នែកច្បាប់ និងការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស ដើម្បីដាក់ចូលទៅក្នុងសិក្ខាសាលាថ្នាក់ជាតិ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមការងារចំពោះកិច្ច ពិភាក្សាលើ អនុក្រឹត្យស្តីពីជនភៀសខ្លួន និងកែសម្រួលលើអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាល សហរដ្ឋអាមេរិក ស្តីពី "ការបង្កើត និងកិច្ចប្រតិបត្តិការរបស់គណៈកម្មការរួមធ្វើមាតុភូមិនិវត្តន៍ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០០២" នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- អញ្ជើញជាអធិបតី និងវាគ្មិនក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ដែលវគ្គនេះឧបត្ថម្ភ និងរៀបចំដោយអង្គការដៃនដីមនុស្សហូឡង់ និងសម្របសម្រួលដោយ គ.ជ.ប.ជ នៅសណ្ឋាគារអាស៊ីធូន(Asia Tune) មានសិក្ខាកាមចូលរួមសរុប ២៥នាក់ (ស្រី៨នាក់)។<br>- ដឹកនាំកិច្ចប្រជុំត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (ចំនួន០៥លើក)។<br>- អញ្ជើញជាអធិបតីនៅក្នុងពិធីបើក និងជាគ្រូឧទ្ទេសនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលាខេត្តបន្ទាយមានជ័យ។<br>- អញ្ជើញចូលរួមសំណេះណាលស្វែងយល់អំពីការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សនៅកម្ពុជា រវាងតំណាងស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ជាមួយលោកជំទាវ ជូ ប៊ុនអេង អនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញចូលរួមប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការផ្តល់សំណាងដល់ជនរងគ្រោះ នីតិវិធីជំនួយផ្នែកច្បាប់ និងការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស ដើម្បីដាក់ចូលទៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ដែលនឹងប្រព្រឹត្ត ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ចូលរួមសិក្ខាសាលាប្រចាំឆ្នាំ ស្តីពីការពិនិត្យការអនុវត្តគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា និងអភិវឌ្ឍន៍ផែនការសកម្មភាពសម្រាប់ អនុវត្តឆ្នាំ២០១៧ នៅសណ្ឋាគារ Imperial Garden ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមកិច្ចសហការជាមួយគម្រោង ILO-Triangle។<br>- អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយជនរងគ្រោះជាបុរសចំនួន០៤នាក់ ត្រូវបានចោរសមុទ្រប្លន់នៅប្រទេសសូម៉ាលី និងក្រុមគ្រួសាររបស់ពួកគាត់ នៅទីតាំងអង្គការការីតាសកម្ពុជា។ |

| | |
|---|---|
| | - ដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំលើកទី៧ របស់ក្រុមការងារបច្ចេកទេសកម្ពុជា នៃកម្មវិធីអូស្ត្រាលី-អាស៊ី ដើម្បីប្រឆាំងការជួញដូរមនុស្ស នៅសណ្ឋាគារ កាំបូឌីយ៉ាណា។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាឆ្លងរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទរយៈពេល ១០ខែ "គិតពីថ្ងៃទី០១ ខែមករា ដល់ទី៣១ ខែតុលា ឆ្នាំ២០១៦" នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- អញ្ជើញជាគណៈអធិបតីក្នុងពិធីបើកសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ ដែលមានសិក្ខាកាមជាគ្រូឧទ្ទេស និង គរុសិស្សចូលរួមសរុប២០០នាក់។<br>- អញ្ជើញជាគណៈអធិបតីក្នុងពិធីបើកសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលាគរុកោសល្យខេត្តកណ្តាល ដែលមានសិក្ខាកាមជាគ្រូឧទ្ទេស និងគរុសិស្សចូលរួមសរុប១០៥នាក់។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីករណីអំពើធ្វើជាអន្តរការីនៃអំពើពពោះ និងសុំឲ្យផ្តល់ឯកសារដោយទុច្ចរិត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញជាអធិបតី និងជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប នៅខេត្តសៀមរាប។<br>- ចូលរួមប្រជុំពិភាក្សា ការកំណត់យកវិធានការឆ្លើយតបនឹងសេវា ពពោះបង្កើតកូនជំនួសគេ នៅទីស្តីការក្រសួងកិច្ចការនារី។<br>- ចូលរួមវគ្គផ្សព្វផ្សាយ ស្តីពីយុត្តិធម៌អនីតិជន ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាង ប្រកាសស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ រៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការ UN-WOMEN នៅសណ្ឋាគារភ្នំពេញ។<br>- ចូលរួមកិច្ចប្រជុំ ស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុករបស់កុមារ នៅទីស្តីការក្រសួងសង្គមកិច្ច នៅទីស្តីការក្រសួងសង្គមកិច្ច។<br>- អញ្ជើញជាវាគ្មិនក្នុង សិក្ខាសាលាថ្នាក់តំបន់ AICHR ស្តីពីការពង្រឹងផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សំដៅធានាអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ ACTIP និង APA នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>- អញ្ជើញជាគណៈអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្តីពីការបង្ការទប់ ស្កាត់អំពើជួញដូរមនុស្ស នៅសាកលវិទ្យាល័យបាត់ដំបង ខេត្តបាត់ដំបង ដែលមានសិក្ខាកាមជាគ្រូឧទ្ទេស និងគរុសិស្ស និស្សិតចូលរួមសរុបប្រមាណ ៤០០នាក់។<br>- អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្តីពីដំណោះស្រាយសំណងរដ្ឋប្បវេណីដល់ជនរងគ្រោះដោយអំពើរំលោភបំពាន និងអំពើកេងប្រវ័ញ្ចផ្លូវភេទ រៀបចំដោយអង្គការ ICRP និង APLE នៅសណ្ឋាគារសាន់វ៉េ។ |

| | |
|---|---|
| | - អញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលា ផ្សព្វផ្សាយលទ្ធផលរបាយការណ៍ជាតិលើកទី៤ និងទី៥ លើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ CEDAW និងអនុសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានកិត្តិយស នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី រៀបចំដោយអគ្គលេខាធិការដ្ឋាន អចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅសាលាខេត្តកំពង់ឆ្នាំង។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សារៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញជាអធិបតីក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៦ នៅខេត្តកំពង់ស្ពឺ ពោធិ៍សាត់ សៀមរាប និងខេត្តស្វាយរៀង ។<br>- អញ្ជើញជាគណៈអធិបតីក្នុងពិធីបើកសិក្ខាសាលា ស្តីពីការបង្ការទប់ ស្កាត់អំពើជួញដូរមនុស្ស នៅសាលាគរុកោសល្យវិក្រឹត្យការ ខេត្តព្រៃវែង ដែលមានសិក្ខាកាមជាគ្រូឧទ្ទេស និងគរុសិស្ស និស្សិត ចូលរួមសរុបប្រមាណ ២០០នាក់។<br>- អញ្ជើញជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីភាពជា អ្នកដឹកនាំគំរូក្នុងទស្សនៈសុចរិតភាព និងអភិបាលកិច្ចល្អ នៅសាលាអភិបាលកិច្ចក្រសួងមហាផ្ទៃ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៤០នាក់។<br>- អញ្ជើញជាគណៈអធិបតី និងជាគ្រូឧទ្ទេសក្នុងសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការពង្រឹងប្រសិទ្ធភាពបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការលើកកម្ពស់បរិស្ថានល្អ អនាម័យស្អាតនៅតាមគ្រឹះស្ថានសិក្សា នៅវិទ្យាល័យព្រះបាទសុរាម្រឹត ខេត្តកំពង់ឆ្នាំង។<br>- អញ្ជើញសំណេះសំណាលការងារ និងជូនពរឆ្នាំថ្មី ជាមួយមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទាំងអស់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញជាអធិបតីបើកកម្មវិធីវេទិការអាជ្ញាធរ និងកម្មករ ស្តីអំពីទីក្រុងមានសុវត្ថិភាពសម្រាប់ស្ត្រី និងលុបបំបាត់អំពើហិង្សាលើស្ត្រី នៅភោជនីយដ្ឋានខ្មែរសូរិន្ទ ភ្នំពេញ។<br>- អញ្ជើញជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម។<br>- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ លើលទ្ធផលនៃការសិក្សាស្រាវជ្រាវ ស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកមកលើកុមារ។<br>- ចូលរួមសិក្ខាសាលា ស្តីពីការកម្ពស់កំពស់ការយល់ដឹងស្តីពីបទប្បញ្ញត្តិ និងប្រកាសទាក់ទងនឹងលក្ខខណ្ឌការងារសម្រាប់កម្មករការងារផ្ទះ រៀបចំដោយក្រសួងការងារ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី។<br>- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាតិដើម្បីកុមារ ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកមកលើកុមារ នៅទីស្តីការ ក្រសួងសង្គមកិច្ច។<br>- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីផែនការសកម្មភាពសម្រាប់អនុវត្ត គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៧ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារភ្នំពេញ។ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | ❖ បានសម្របសម្រួលសរុប០៧លើក |

| | |
|---|---|
| | - ដឹកនាំប្រជុំ សម្របសម្រួលក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន០២លើក រៀបចំផែនការសកម្មភាពបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ២០១៥-២០១៨។<br>- រៀបចំប្រជុំក្រុមការងារផ្ទៃក្នុង កំណត់ទិសដៅភារកិច្ចបញ្ជ្រាបគោលការណ៍បង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៅតាមគ្រឹះស្ថានសិក្សានៅគ្រប់រាជធានី-ខេត្ត ខណ្ឌ ស្រុក នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។<br>- ចូលរួមពិភាក្សាតុមូលវិទ្យុ FM102 ក្នុងកម្មវិធីកុមារ និងពលកម្ម ប្រធានបទ"ប្រយុទ្ធប្រឆាំងពលកម្មកុមារក្នុងវិស័យជលផល"។<br>- ចូលរួមសន្និបាតបូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦។<br>- រៀបចំប្រជុំពិភាក្សាជាមួយអង្គការ វីនរ៉ក់ ក្រោមអធិបតីភាព សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្តោតលើគម្រោងថ្មី និងត្រៀមលក្ខណៈដើម្បីចុះ អនុស្សរណៈ នៃការយោគយល់គ្នា លើកិច្ចសហប្រតិបត្តិការ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងក្រសួងអប់រំ និងអង្គការវីនរ៉ុក ក្រោមរូបភាពនៃក្រុមការងារបង្ការ ទប់ស្កាត់។<br>- សហការជាមួយអង្គការ ILO-Triangle ប្រជុំប្រឹក្សាគម្រោង ILO-Triangle ជំហានទី២ សម្រាប់អនុវត្ត៥ឆ្នាំ (២០១៦-២០២០) នៅប្រទេសកម្ពុជា ស្តីពីការងារទេសន្តរប្រវេសន៍។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | ❖ បានចូលរួមសម្របសម្រួលសរុប៣៨លើក<br>- បច្ចុប្បន្នភាព ការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ។<br>- ចូលរួមកិច្ចប្រជុំបូកសរុបការងាររបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។<br>- កិច្ចប្រជុំក្រុមអ្នកធ្វើការងារពាក់ព័ន្ធ និងការប្រឆាំងអំពើជួញដូរមនុស្សលើកទី១សម្រាប់ ឆ្នាំ២០១៦។<br>- សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃធ្វើជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាល គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីការការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានសិក្ខាមសរុបចំនួន៣៥នាក់។<br>- សន្និបាតបូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទិសដៅឆ្នាំ២០១៦ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។<br>- ជាគ្រូឧទ្ទេស និងចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការងារសមាហរណកម្ម និងតាមដាន ក្រុមជនរងគ្រោះដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។<br>- ជាអធិបតីភាព ពិធីប្រកាសផ្សព្វផ្សាយការគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប។<br>- កិច្ចប្រជុំក្រុមការងារបច្ចេកទេសអនុវត្តកម្មវិធី AAPTIP លើកទី៥ នៅក្រសួងយុត្តិធម៌។<br>- កិច្ចប្រជុំឆ្លងសេចក្តីព្រាងផែនការសកម្មភាព បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ឆ្នាំ២០១៥-២០១៨ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។ |

| | |
|---|---|
| | - ក្នុងពិធីផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍកុមារតូចឆ្នាំ២០១៦-២០១៨ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។<br>- កិច្ចប្រជុំការងារបច្ចេកទេស ដើម្បីជួយដល់ គ.ជ.ប.ជ ដោះស្រាយអំពីបញ្ហាជនអនាថា។<br>- សម្ភាស និងសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ស្តីពីបពិសោធន៍ទាក់ទងស្ថានភាពការជួញដូរមនុស្ស និងពលករចំណាកស្រុក។<br>- កិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ពិនិត្យលើសេចក្តីព្រាងប្រកាសថ្មី របស់មណ្ឌលសំចប៉ោយប៉ែត និងប្រជុំពិភាក្សាបញ្ហាប្រឈម របស់មណ្ឌលសំចតប៉ោយប៉ែត នៅទីស្តីការក្រសួង។<br>- សិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហការរវាងមន្ត្រីសង្គមកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបើកវគ្គបណ្តុះបណ្តាល ស្តីពី(បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមណ្ឌល) និង(ឧបករណ៍ត្រួតពិនិត្យ ការវាយតម្លៃ ការអនុវត្តគោលនយោបល់ និងបទដ្ឋាន អប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស)នៅក្រុងសៀមរាប។<br>- ប្រជុំពិភាក្សាជាមួយអង្គការជំណក់ទឹក ដើម្បីរកវិធីសាស្ត្រដោះស្រាយទីកន្លែង សម្រាប់ធ្វើការសម្ភាសកំណត់អត្តសញ្ញាណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងចំណោមនីរទេសជនដែលអាជ្ញាធរថៃបានបញ្ជូនមក។<br>- កិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស លើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៧ នៅក្រសួងសេដ្ឋកិច្ច និងហិរិញ្ញវត្ថុ។<br>- កិច្ចពិភាក្សាកែសម្រួលខ្លឹមសារឯកសារណែនាំ ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។<br>- ប្រជុំត្រួតពិនិត្យការងារប្រចាំឆមាសទី១របស់អង្គភាពនីមួយៗ។<br>- ចូលរួមកិច្ចប្រជុំលើកទី១ ស្តីពីការពិនិត្យលើឯកសារបណ្តុះបណ្តាលបទដ្ឋានអប្បបរមាអំពីការប្រឹក្សា យោបល់ជាមូលដ្ឋានដល់ស្ត្រី និងកុមារជាជនរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រ។<br>- កិច្ចប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងបូកសរុបការងារឆមាសទី១ និងទិសដៅបន្ត។<br>- កិច្ចប្រជុំលើកទី១ក្រុមការងារទេសន្តប្រវេសន៍។<br>- កិច្ចប្រជុំប្រចាំខែលើកទី៨២ ឆ្នាំ២០១៦ របស់ ក.ជ.ក.រ ដើម្បីពិនិត្យ និងពិភាក្សាពីលទ្ធផលការងារ(សមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ និងលើកទិសដៅអនុវត្តបន្តរបស់ក្រុមការងារ។<br>- ចែករំលែកព័ត៌មានអំពីទស្សនវិស័យ និងសកម្មភាពការងារដែលក្រសួងបានអនុវត្តពាក់ព័ន្ធ នឹងអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារ ក្នុងកិច្ចពិភាក្សាដោះស្រាយអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រព័ន្ធអ៊ីនធឺណេត។<br>- កិច្ចប្រជុំ ស្តីពីការចុះប្រមូលទិន្នន័យនៃអង្កេតថ្នាក់ជាតិ និងស្រាវជ្រាវអភិវឌ្ឍន៍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា របស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។<br>- កិច្ចប្រជុំ និងអមដំណើរគណៈប្រតិភូនៃសាធារណៈរដ្ឋប្រជាមានិតចិនអញ្ជើញមកធ្វើទស្សនកិច្ចសិក្សានៅកម្ពុជា។<br>- កិច្ចប្រជុំពាក់ព័ន្ធនឹងសំណើសុំចុះកិច្ចព្រមព្រៀងគម្រោងបន្តសម្រាប់ ឆ្នាំ២០១៦-២០១៨ របស់អង្គការមូលនិធិហាកាអន្តរជាតិ។ |

| | |
|---|---|
| | - កិច្ចប្រជុំពិភាក្សាលើឯកសារបណ្តុះបណ្តាលគ្រូឧទ្ទេស ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងផែនការបណ្តុះបណ្តាល។<br>- រៀបចំបណ្តុះបណ្តាល ស្តីពី (បទដ្ឋានអប្បបរមាសម្រាប់ថៃទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមណ្ឌល) និង (ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស) ដែលមានអ្នកចូលរួមសរុបចំនួន៦៥នាក់ (ស្រីចំនួន៣១នាក់) ក្នុងនោះមកពីបណ្តាមន្ទីរ ស.អ.យ ២៥រាជធានីខេត្ត និងអង្គការពាក់ព័ន្ធចូលរួមចំនួន១៧នាក់ នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង។<br>- សហការជាមួយអង្គការចាប់ដៃគូ ចូលរួមជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាលលើប្រធានបទ ស្តីពីនីតិវិធី សមាហរណកម្មជនរងគ្រោះទៅកាន់សហគមន៍វិញ ដែលមានអ្នកចូលរួមសរុបចំនួន១៩១នាក់ (ស្រី១១២នាក់) និងមានអង្គការចូលរួមចំនួន៣១អង្គការ។<br>- កិច្ចប្រជុំ ស្តីពីលំហូរមិនប្រក្រតីនៃពលករឆ្លងដែន នៅខេត្តបន្ទាយមានជ័យ។<br>- កិច្ចប្រជុំផ្តល់យោបល់លើសំណើសូចនាករ នៃក្របខណ្ឌយុទ្ធសាស្ត្រ សម្រាប់វិស័យសុខមាលភាពសង្គម និងការអភិវឌ្ឍឆ្នាំ២០១៦-២០២០។<br>- ប្រជុំបន្តអំពីការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការងារអនុវត្តច្បាប់ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រជុំពិភាក្សាករណីអង្គការ Project Change Intirnational (PIC) ស្នើសុំលិខិតគាំទ្រ គម្រោងកម្មវិធី ដើម្បីចុះអនុស្សរណៈ នៃការយោគយល់គ្នា នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។<br>- ប្រជុំក្រុមការងារអន្តរក្រសួងរៀបចំតាក់តែងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ នឹងការអនុវត្តច្បាប់យុត្តិធម៌អនីតិជនដើម្បីផ្សព្វផ្សាយអំពីសមាសភាព តួនាទី ភារកិច្ច និងរៀបចំផែនការសកម្ម ភាពរបស់ក្រុមការងារ។<br>- ប្រជុំពិភាក្សាលទ្ធផលការងារតាមដានអនុគណៈកម្មការ ក្នុងការរៀបចំប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ២០១៦ ដែលនឹងធ្វើនៅកោះពេជ្រចំនួន០២លើក។<br>- ប្រជុំពិភាក្សាលើការរៀបចំបំពេញតារាងម៉ាទ្រីស នៃផែនការសកម្មភាព២០១៦-២០១៨ នៃគោលនយោបាយជាតិប្រជាជន២០១៦-២០៣០។<br>- ប្រជុំជាមួយអង្គការ JICA ស្តីពី Request Cooperation for the Survey Mission for the Project on Capacity Development on Assisting Victims of Trafficking in the Greater Mekong Sub-Regional Countries (implemented in the Mekong Region)។ |
| **ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ** | ❖ បានចូលរួមសម្របសម្រួលសរុប០៣លើក<br>- សហការជាមួយអង្គការ ILO-Triangle រៀបចំប្រជុំប្រឹក្សាគម្រោងរបស់ ILO-Triangle ជំហានទី២ សម្រាប់អនុវត្តបន្តរយៈពេល៥ឆ្នាំ នៅប្រទេសកម្ពុជា ស្តីពីទេសន្តរប្រវេសន៍ការងារ។<br>- រៀបចំកិច្ចប្រជុំ ស្តីពីការណែនាំ ការគ្រប់គ្រង និងការពង្រឹងលើការអនុវត្តការងាររបស់ទីភ្នាក់ងារជ្រើសរើសឯកជន។ |

| | |
|---|---|
| | - រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសកម្ពុជា-ថៃ ដើម្បីពិភាក្សាលើការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការនៃវិស័យការងារ (Labour Cooperation) និងកិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់កម្លាំងពលកម្ម (Employment of Workers)។ |
| **ក្រសួងកិច្ចការនារី** | ❖ បានចូលរួមសម្របសម្រួលសរុប៣០លើក<br>- ប្រជុំ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន១២លើក។<br>- ប្រជុំពិភាក្សា ស្តីពីការរៀបចំវេទិកាប្រកួតប្រជែងយុវជន ខមមីត កម្ពុជា ក្រោមការរៀបចំ និងកិច្ចសហការ រវាងក្រសួងសង្គមកិច្ច និងអង្គការ World Vision។<br>- ប្រជុំលេខាធិការដ្ឋាន នៃក្រុមការងារសហប្រតិបត្តិការអន្តរជាតិ គ.ជ.ប.ជ ចំនួន០៥លើក និងប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិនៃ គ.ជ.ប.ជ ចំនួន០៣លើក ។<br>- រៀបចំប្រជុំពិភាក្សាជួយសមាជិក ខមមីត កម្ពុជា ដើម្បីពិនិត្យ និងសុំយោបល់លើការរៀបចំសេចក្តីព្រាងចុងក្រោយ នៃសមាជិកក្រុមការងារខមមីត កម្ពុជាថ្មី ដើម្បីដាក់ជូន សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពិនិត្យ និងចុះហត្ថលេខា។<br>- សហការរៀបចំកិច្ចប្រជុំពិក្សាចំនួន០៣លើក រវាងក្រុមការងារដែលដឹកនាំដោយ លោកជំទាវ សាន្ត អុណា រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី និងលោកជំទាវ ខៀវ បូរី រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច ព្រមទាំងមានការចូលរួមពីអង្គការដៃគូ ដើម្បីពិភាក្សាអំពីឯកសារត្រៀមសមាសភាពគណៈកម្មការកណ្តាល អនុគណៈកម្មការសម្រាប់រៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម នៅខែតុលា ឆ្នាំ ២០១៦ នៅខេត្តព្រះសីហនុ ដើម្បីពិនិត្យឡើងវិញកិច្ចព្រមព្រៀង នីតិវិធីប្រតិបត្តិបទដ្ឋាន(SOP) និងពិភាក្សារៀបចំផែនការសកម្មភាពរួម ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្លងដែន។<br>- ជួបពិគ្រោះយោបល់ចំនួន០៨លើក ជាមួយអង្គការ KOKUN កូរ៉េ, អង្គការ UNODC, USAID, ក្រុមការងារមកពីទីស្តីការគណៈរដ្ឋមន្ត្រី, CWCC, UNACT និងមជ្ឈមណ្ឌលអាមេរិកាំងសម្រាប់ការងារអន្តរជាតិ ស្តីពីបញ្ញត្តិច្បាប់ និងគោលនយោបាយ ។ |
| **ក្រសួងយុត្តិធម៌** | ❖ បានសម្របសម្រួលសរុប១៣លើក<br>- ប្រជុំជាមួយគម្រោង AAPTIP រៀងរាល់បីខែម្តងដើម្បីធ្វើបច្ចុប្បន្នភាពរបស់គម្រោងដែលបាន សហការជាមួយក្រសួងយុត្តិធម៌។<br>- រៀបចំកិច្ចប្រជុំពិភាក្សាចំនួន០២លើក លើសេចក្តីព្រាងសន្ធិសញ្ញា ស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ។<br>- សហការជាមួយ AAPTIP ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលក្នុងរឿងក្តីជួញដូរមនុស្សដែលមានការចូលរួមពីមន្ត្រីក្រសួងយុត្តិធម៌។<br>- សហការជាមួយ AAPTIP ព្រះរាជអាជ្ញា និងមេធាវី ដែលមកពីប្រទេសថៃ និងសហរដ្ឋអាមេរិកក្នុងការរៀបចំវគ្គបណ្តុះបណ្តាលផ្តល់ចំណេះដឹងដល់មន្ត្រីក្រសួងយុត្តិធម៌អំពីនីតិវិធីនៃការធ្វើ និងការឆ្លើយតបសំណើសុំជំនួយនានាក្នុងវិស័យព្រហ្មទណ្ឌ។<br>- គម្រោង AAPTIP សហការជាមួយក្រសួងយុត្តិធម៌ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលកម្មវិធីស្តីពីកិច្ចការការពារសាក្សី និងជនរងគ្រោះក្នុងបទល្មើសអំពើជួញដូរមនុស្ស ដល់ចៅក្រម ព្រះរាជអាជ្ញា។<br>- ប្រជុំត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ ស្តីពីការបង្ក្រាបអំពើរត់ពន្ធមនុស្ស ចំនួន០២លើក។ |

| | |
|---|---|
| | - សហការជាមួយ AAPTIP ក្នុងការរៀបចំប្រជុំសេចក្តីព្រាងច្បាប់ ស្តីពីជំនួយទៅវិញទៅមកក្នុងវិស័យ ព្រហ្មទណ្ឌក្នុងរឿងក្តីជួញដូរមនុស្ស។<br>- ចូលរួមប្រជុំរបស់ AAPTIP លើកទី៧ ស្តីពីការធ្វើបច្ចុប្បន្នភាពរបស់គម្រោង និងការលើកទិសដៅការងារ និងភាពប្រឈម។<br>- សហការជាមួយ AAPTIP និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការក្នុងការពិនិត្យ និងកែសម្រួលសៀវភៅមេរៀន ស្តីពីការជួញដូរមនុស្សសម្រាប់ព្រះរាជអាជ្ញាឯកទេស ដោយបានប្រជុំ និងបើកវគ្គបណ្តុះបណ្តាល ជាច្រើនលើក ។<br>- សហការជាមួយ AAPTIP សម្របសម្រួលឲ្យមានកិច្ចប្រជុំរវាងចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ និងខេត្តសៀមរាប សម្រាប់ធ្វើជាតុលាការគំរូពាក់ព័ន្ធនឹងសំណុំរឿងក្តីអំពើជួញដូរមនុស្ស ។<br>- សហការជាមួយ AAPTIP ចាត់ឲ្យព្រះរាជអាជ្ញាចូលរួមកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការឆ្លងដែនរវាងកម្ពុជា វៀតណាម ភូមា និងឥណ្ឌូណេស៊ី ។ |
| **អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** | ❖ បានសម្របសម្រួល០៣លើក ដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន<br>- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ(FBI.AIM SWAT)បើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីជំនាញប្រឆាំងការជួញដូរមនុស្សចំនួន០៥វគ្គ ក្នុងនោះ (វគ្គយុទ្ធវិធីប្រតិបត្តិការនៃការប្រើប្រាស់អាវុធ, ការប្រឆាំងបទល្មើសទេសចរណ៍ផ្លូវភេទតាមប្រព័ន្ធបច្ចេកវិទ្យា, ព័ត៌មានវិទ្យាអ៊ិនធឺណែត និងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ, បំប៉នជំនាញ ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងផលប៉ះពាល់ចំពោះកុមារ និងការស៊ើបអង្កេតមូលដ្ឋាន, និងវគ្គបច្ចេកទេសសួរចម្លើយ។<br>- ចូលរួមវគ្គបណ្តុះបណ្តាល និងបំប៉នជំនាញ ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងការស៊ើបអង្កេតពីផលប៉ះពាល់ចំពោះកុមារ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌។<br>- ចាត់បញ្ជូនមន្ត្រីនគរបាលជាតិចំនួន០៤រូប ចូលរួមវគ្គបណ្តុះបណ្តាល សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (នៅសណ្ឋាគារសាន់វ៉េ)។<br>- ចាត់បញ្ជូនមន្ត្រីនគរបាលជាតិ០១រូប ចូលរៀនវគ្គបំប៉នមន្ត្រីស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល (នៅសាលាបណ្ឌិត្យសភានគរបាលជាតិកម្ពុជា)។ |

*លេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ខេត្ត បានសម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សសរុបចំនួន**២៨៦លើក** មានដូចខាងក្រោម៖*

| | |
|---|---|
| *រាជធានីភ្នំពេញ* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**០១ លើក** |
| *ខេត្តកោះកុង* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**០២ លើក** |
| *ខេត្តប៉ៃលិន* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**០៥ លើក** |
| *ខេត្តបន្ទាយមានជ័យ* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**១៨ លើក** |
| *ខេត្តបាត់ដំបង* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**២៥ លើក** |
| *ខេត្តសៀមរាប* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**៤៦ លើក** |
| *ខេត្តព្រះវិហារ* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**០៨ លើក** |
| *ខេត្តរតនគិរី* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**០១ លើក** |
| *ខេត្តឧត្តរមានជ័យ* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**១៨ លើក** |

| | |
|---|---|
| *ខេត្តប៉ៃលិន* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**១១ លើក** |
| *ខេត្តកណ្តាល* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**៤៥ លើក** |
| *ខេត្តកំពង់ធំ* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**២១ លើក** |
| ខេត្តតាកែវ | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន១៦ លើក |
| *ខេត្តកំពត* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**០៤ លើក** |
| *ខេត្តកំពង់ស្ពឺ* | សម្របសម្រួលកិច្ចប្រជុំ និងការងារផ្សេងៗដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចំនួន**០៥ លើក** |
